# ថ្ងៃទី០១ ខែ មីនា ឆ្នាំ២០២៣

## សមត្ថកិច្ចស្រាវជ្រាវ
## តាមបណ្តឹង Hotline រកឃើញជនជាតិឥណ្ឌូនេស៊ី២៨នាក់ ដែលស្នើសុំត្រឡប់ទៅផ្ទះវិញ

https://freshnewsasia.com/index.php/en/localnews/279862-2023-02-28-09-43-10.html 2023-02-28 04:43pm

**(ព្រះសីហនុ)៖** ជនជាតិឥណ្ឌូនេស៊ី ២៨នាក់ ត្រូវបានសមត្ថកិច្ចកម្ពុជា អន្តរាគមស្វែងរកឃើញ បន្ទាប់ពីមានបណ្តឹងតាមប្រព័ន្ធ Hotline ថាមានការបង្ខាំង។ ប៉ុន្តែបន្ទាប់ពីសាកសួរ សមត្ថកិច្ចបានរកឃើញថា ករណីនេះមិនមែនជាការបង្ខាំងទេ ប៉ុន្តែពួកគេលាឈប់ពីការងារ និងស្នើត្រឡប់ទៅផ្ទះវិញ។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ថាឱ្យដឹងថា ការអន្តរាគមន៍ស្វែងរកជនជាតិឥណ្ឌូនេស៊ីទាំងនោះ ធ្វើឡើងចាប់ពីថ្ងៃទី១៧ ដល់២៤ ខែកុម្ភៈ ឆ្នាំ២០២៣ បន្ទាប់ពីសមត្ថកិច្ចទទួលបានពាក្យបណ្តឹងចំនួន ២ករណី ដោយក្នុងនោះចំនួន២៧នាក់ នៅខេត្តពោធិ៍សាត់ និង១នាក់ នៅខេត្តឧត្តរមានជ័យ។ លោកអះអាងថា ចំពោះករណីនេះ ពុំមែនជាករណីចាប់បង្ខាំង ធ្វើទារុណកម្មនោះទេ ប៉ុន្តែជនជាតិឥណ្ឌូនេស៊ីទាំង២៨នាក់នេះ ចង់លាឈប់ពីការងារ និងមានបំណងវិលទៅប្រទេសកំណើតវិញ។

បើតាមអ្នកនាំពាក្យ, គិតត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចបានស្រាវជ្រាវបឋម ចំនួន៧៤៥សំណើ និងបិទសំណុំរឿង ២៥៧សំណើ ក្នុងចំណោមសំណើស្ថិតក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម ស ខេង សរុប ៧៦០ករណី។ ក្នុងចំណោមសំណើទាំងនោះ សមត្ថកិច្ចរកឃើញមនុស្ស ១,១៤៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។ សមត្ថកិច្ចកំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៥ករណីទៀតផងដែរ៕

## សមាជិកព្រឹទ្ធសភាហ្វីលីពីន៖
## ជនរងគ្រោះជនជាតិហ្វីលីពីននៃការបោកប្រាស់រូបិយប័ណ្ណគ្រីបតូចំនួន ៨ នាក់ត្រូវរង់ចាំដំណើរការនីតិវិធីជាច្រើនសប្តាហ៍មុនពេលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសកម្ពុជា

https://www.khmertimeskh.com/501246753/-3/ Khmer Times February 28, 2023

សមាជិកព្រឹទ្ធសភា Risa Hontiveros បាននិយាយកាលពីថ្ងៃចន្ទ ទី២៧ ខែកុម្ភៈថា ពលករហ្វីលីពីននៅក្រៅប្រទេសដែលត្រូវបានជួញដូរ និងបង្ខំឱ្យធ្វើការក្នុងប្រតិបត្តិការបោកប្រាស់រូបិយប័ណ្ណគ្រីបតូនៅកម្ពុជាត្រូវរង់ចាំជាច្រើនសប្តាហ៍មុនពេលពួកគេអាចត្រឡប់ទៅប្រទេសហ្វីលីពីន ដោយសាររដ្ឋាភិបាលកម្ពុជាតម្រូវអោយមាននីតិវិធី និង"ការពិភាក្សាជាច្រើន"។ ក្រសួងការបរទេសហ្វីលីពីន នៅមុននេះបន្តិចបានប្រកាសពីការបញ្ជូនជនរងគ្រោះដែលត្រូវបានជួញដូរចំនួន៨នាក់ត្រឡប់ទៅហ្វីលីពីនវិញកាលពីថ្ងៃសៅរ៍ទី២៥ ខែកុម្ភៈ។ ជនរងគ្រោះត្រូវរង់ចាំជាច្រើនសប្តាហ៍ ហើយមានការពិភាក្សារច្រើន ដោយសារតែរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវអនុវត្តតាមនីតិវិធី មុនពេលជនរងគ្រោះនៃការជួញដូរមនុស្សអាចត្រឡប់ទៅប្រទេសហ្វីលីពីនវិញបាន។ ជាមួយនឹងរបាយការណ៍ស្តីពីការជួញដូរ ពលករហ្វីលីពីននៅបរទេសនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងកម្ពុជា ក្រសួងការបរទេសនិយាយថា ខ្លួនកំពុងរៀបចំដំណើរការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះហ្វីលីពីនពីការជួញដូរខុសច្បាប់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោកស្រី Risa Hontiveros បានបន្តថា "សប្តាហ៍ទាំងនេះពោរពេញទៅដោយការអន្ទះអន្ទែង។ ដោយសារប្រតិបត្តិការបោកប្រាស់គ្រីបតូទាំងនេះ គឺជាបញ្ហាថ្មីក្នុងការជួញដូរមនុស្សនៅតំបន់អាស៊ាន ដូច្នេះ វាហាក់បីដូចជាខ្វះការយល់ស្របលើរបៀបដែលយើងកំណត់ជនរងគ្រោះទាំងនេះ ដោយអ្នកខ្លះគិតថាពួកគេជាពលករខុសច្បាប់ ឬជនអន្តោប្រវេសន៍គ្មានឯកសារ»។ លោកស្រីក៏បានលាតត្រដាងជាលើកដំបូងនូវរបាយការណ៍ស្តីពីពលករហ្វីលីពីននៅបរទេស ដែលត្រូវបានជួញដូរ និងបង្ខំឱ្យធ្វើការក្នុងការបោកប្រាស់គ្រីបតូនៅអាស៊ីអាគ្នេយ៍ក្នុងខែវិច្ឆិកា ឆ្នាំ ២០២២។ របាយការណ៍ទាំងនេះបានរកឃើញថា ពលករហ្វីលីពីនទាំងនេះត្រូវបានជួញដូរទៅប្រទេសមីយ៉ាន់ម៉ា បន្ទាប់ពីត្រូវបានជ្រើសរើសជាភ្នាក់ងារមជ្ឈមណ្ឌលហៅទូរសព្ទ ឬបុគ្គលិកសម្រាប់ប្រតិបត្តិករហ្គេមនៅក្រៅប្រទេសហ្វីលីពីនតាមរយៈវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗ ហើយប្រតិបត្តិករបោកប្រាស់ត្រូវបានចោទប្រកាន់ថាមានម្ចាស់ជាជនជាតិចិន។ លោកស្រីក៏បានបង្ហាញពីករណីជាច្រើនទៀតដែលជនជាតិហ្វីលីពីនត្រូវបាននាំមកប្រទេសកម្ពុជា ដើម្បីធ្វើការបោកប្រាស់រូបិយប័ណ្ណគ្រីបតូ។

នៅក្នុងសេចក្តីថ្លែងការណ៍កាលពីថ្ងៃច័ន្ទ លោកស្រី Hontiveros បានថ្លែងអំណរគុណដល់មន្ត្រីក្រសួងការបរទេស នគរបាលកម្ពុជា អង្គការសង្គមស៊ីវិល និងបុគ្គលដែលបានជួយការិយាល័យរបស់លោកស្រីក្នុងការផ្តល់អាហារបន្ថែម និងសម្ភារៈចាំបាច់ដល់ជនរងគ្រោះ ខណៈដែលពួកគេរង់ចាំការធ្វើមាតុភូមិនិវត្តន៍។ ជនរងគ្រោះជាច្រើនត្រូវបានសង្គ្រោះដោយនគរបាលជាតិកម្ពុជាក្នុងខេត្តឧត្តរមានជ័យ និងខេត្តកំពត។ អង្គភាពប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតរបស់អាជ្ញាធរកម្ពុជាបានសាកសួរជនជាតិហ្វីលីពីនមុននឹងបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

អនុរដ្ឋលេខាធិការក្រសួងការបរទេសទទួលបន្ទុកកិច្ចការពលករចំណាកស្រុក Eduardo de Vega បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃអាទិត្យទី២៦ ខែកុម្ភៈថា ការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍គឺជា "បញ្ហាធ្ងន់ធ្ងរក្នុងតំបន់" ។ De Vega បាននិយាយថា "យើងនឹងបន្តចូលរួមជាមួយប្រទេសសមាជិកអាស៊ាន និងដៃគូអន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពដ៏គួរឱ្យស្អប់ខ្ពើមនេះ"។

នៅថ្ងៃទី២៣ ខែកុម្ភៈ ស្ថានទូតហ្វីលីពីននៅរាជធានីភ្នំពេញ បានចេញសេចក្តីណែនាំមួយដល់ប្រជាជនហ្វីលីពីនក្រើនរំលឹកពួកគេអំពីការកើនឡើងនៃករណីជនជាតិហ្វីលីពីនដែលត្រូវបានជ្រើសរើសដោយខុសច្បាប់ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត។ ស្ថានទូតបានរៀបរាប់លម្អិតអំពីបទពិសោធន៍ដែលជនជាតិហ្វីលីពីនត្រូវបានជួញដូរពីមុនដោយបានឆ្លងកាត់ ដូចជាការបំពានផ្លូវកាយ និងផ្លូវចិត្ត ធ្វើការងារច្រើនម៉ោង ការមិនបើកប្រាក់ឈ្នួល ការរឹបអូសលិខិតឆ្លងដែន ទូរស័ព្ទដៃ និងការជំរិតទារប្រាក់។ «អ្នកខ្លះត្រូវបានគំរាមសម្លាប់ ឬកាត់ដៃចោលប្រសិនបើពួកគេមិនសហការ។ ពេលខ្លះពួកគេត្រូវបានគេគំរាមកំហែងថាគ្រួសាររបស់ពួកគេក្នុងប្រទេសហ្វីលីពីននឹងមានគ្រោះថ្នាក់។ ជនរងគ្រោះមួយចំនួនត្រូវបានលក់ទៅឱ្យក្រុមផ្សេងទៀត ក្នុងទម្រង់ផ្សេងទៀតនៃទាសភាព រួមទាំងទាសភាពផ្លូវភេទផងដែរ»។ ស្ថានទូតបានរំលឹកសារជាថ្មីដល់សាធារណជនឱ្យមានការប្រុងប្រយ័ត្នចំពោះក្រុមហ៊ុនមួយចំនួនដែលសន្យាផ្តល់ការងារធ្វើការនៅកម្ពុជាដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវ។ *Rappler.com*

# មន្ត្រីអង្គការសង្គមស៊ីវិលរកឃើញថា ពលករខ្មែររាប់រយនាក់ដែលធ្វើការនៅប្រទេសថៃ បានបាត់បង់ការងារនៅដើមឆ្នាំ ២០២៣ នេះ

https://www.postkhmer.com/national/2023-02-27-1736-247430.html ជា សុខនី | Publication date 27 February 2023 | 17:36 ICT

**ភ្នំពេញៈ** មន្ត្រីអង្គការសង្គមស៊ីវិលរកឃើញថា ពលករខ្មែររាប់រយនាក់ដែលធ្វើការនៅប្រទេសថៃត្រូវបាត់បង់ការងារនៅដើមឆ្នាំ ២០២៣ នេះ។ មន្ត្រីអង្គការសង់គ្រាល់ប្រចាំប្រទេសថៃថា នៅដើមឆ្នាំ ២០២៣ នេះ មានរោងចក្រជាច្រើននៅប្រទេសថៃ បានផ្អាកដំណើរការ រួមទាំងវិស័យសំណង់ ដែលជាហេតុធ្វើឲ្យពលករខ្មែរដែលធ្វើការនៅនោះ ត្រូវបានបញ្ឈប់ពីការងារ និងពិបាកក្នុងការស្វែងរកការងារថ្មី។

លោក ឡឹង សុផុន មន្ត្រីគម្រោងប្រចាំនៅប្រទេសថៃនៃអង្គការសិទ្ធិការងារកម្ពុជាសង់គ្រាល់បានឲ្យដឹងថា នៅដើមឆ្នាំ២០២៣នេះ ចំនួនរោងចក្រនៅប្រទេសថៃ ដែលបានបញ្ឈប់ពលករខ្មែរពីការងារ មានការកើនឡើងច្រើន ខណៈដែលពលករនៅវិស័យសំណង់ ក៏រងការបញ្ឈប់ពីការងារផងដែរ។ លោកបន្តថា ពលករខ្មែរមួយចំនួនទៀត ត្រូវបានថៅកែផ្តល់ប្រាក់ឈ្នួលឲ្យមិនទៀងទាត់តាមពេលវេលាជាដើម ជាហេតុនាំឱ្យមានពលករមួយចំនួនបានទាក់ទងទៅស្ថានទូត អង្គការសង្គមស៊ីវិល និងមូលនិធិផ្សេងៗ ដើម្បីសុំឲ្យជួយអន្តរាគមន៍ដោះស្រាយបញ្ហារបស់ពួកគាត់។ លោកលើកឡើងថា ចាប់តាំងពីដើមខែកុម្ភៈមក មានរោងចក្រជាច្រើននៅប្រទេសថៃបានចាប់ផ្តើមបញ្ឈប់ពលករខ្មែរដោយមិនបានធ្វើការជូនដំណឹងទុកជាមុន ក្រោមហេតុផលមិនមានអ្នកបញ្ជាទិញ ដូច្នេះមានពលករខ្មែរមួយចំនួនបានមកទំនាក់ទំនងមកស្ថានទូត សុំអន្តរាគមន៍ និងមួយចំនួនទៀត កំពុងស្វែងរកការងារថ្មី។

លោកឡឹង សុផុន បញ្ជាក់ថា៖ «តាំងពីចូលមកដើមឆ្នាំ២០២៣នេះ ឃើញថា បងប្អូនមួយចំនួនច្រើន គឺពួកគាត់បានត្អូនត្អែរពីភាពលំបាកក្នុងការស្វែងរកការងារធ្វើអ៊ីចឹង ហើយការបញ្ឈប់នេះ គឺមិនមែនតែរោងចក្រទេ សូម្បីតែខាងពលករដែលធ្វើការកសាង ធ្វើសំណង់ហ្នឹង ក៏ត្រូវបានបញ្ឈប់ដែរ។ កន្លែងខ្លះពួកគាត់ត្រូវបានផ្អាកពីការងារ ត្រូវបានគេពន្យារពេលក្នុងការបើកប្រាក់ឈ្នួល ដែលធ្វើឲ្យពលករគាត់លំបាក អ៊ីចឹងហើយបានជាពួកគាត់ខ្លះប្តូរការងារអ៊ីចឹងទៅ»។ លោកបន្តថា ទោះបីជារោងចក្រនៅប្រទេសថៃមានចំនួនច្រើនក៏ដោយ ប៉ុន្តែមានរោងចក្រខ្លះបានបញ្ឈប់ពលករដោយបើកប្រាក់ឈ្នួលឲ្យ និងមានរោងចក្រខ្លះទៀតមិនបានបើកប្រាក់ឈ្នួលឲ្យពលករខ្មែរទាំងនោះ ដែលជាហេតុនាំឲ្យពួកគាត់មានការព្រួយបារម្ភលើជីវភាពរស់នៅ។

លោក សេង ហុក ជាពលករធ្វើការរោងចក្រនៅខេត្តឈុនបុរីប្រទេសថៃ។ លោកប្រាប់ថាលោកមានស្រុកកំណើតនៅខេត្តកំពត ហើយលោកធ្វើការនៅប្រទេសថៃអស់រយៈពេល៤ឆ្នាំមកហើយ។លោកសេង ហុក ឱ្យដឹងថា លោកបានបាត់បង់ការងារតាំងពីខែមករា ដើមឆ្នាំនេះ ប៉ុន្តែលោកគ្រោងនឹងចូលធ្វើការវិញនៅដើមខែមិនាខាងមុខ។ លោក សេង ហុក៖ ថ្លែងថា៖«ខ្ញុំធ្វើការងារនៅរោងចក្រ តាមរយៈក្រុមម៉ៅការការងារដេរ តែពេលធ្វើៗគេប្រាប់ថាអស់ការងារយើងក៏អត់អីធ្វើអ៊ីចឹងទៅ។ ដេកហូបជាង១ខែហើយ ទើបបងប្អូនគេហៅទៅធ្វើនៅជិតបាងកក នឹងចូលធ្វើនៅថ្ងៃទីមួយខែ៣នេះហើយ»។ លោក សេង ហុក បានបន្ថែមថា៖«យើងនៅស្រុកគេអុ៊ចេះ? បើអស់ការងារធ្វើមិនយូរមិនឆាប់ច្បាស់ជារត់ទៅវិញព្រោះអត់លុយចំណាយទេ ពិតជាមិនស្រួលឡើយ»។

ឆ្លើយតបជាមួយបញ្ហាប្រឈមរបស់ពលករខ្មែរនៅប្រទេសថៃ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ថ្មីៗនេះក៏បានចុះជួយអន្តរាគមន៍ដោះស្រាយក្នុងការស្វែងរកការងារថ្មីជូនពលករទាំងនោះ ខណៈដែលមានពលករខ្មែរបានទៅរាយការណ៍ប្រាប់ស្ថានទូត។

ទាក់ទិនរឿងនេះមន្ត្រីអនុព័ន្ធការងារនៃស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ គឺលោក ជុំ សម្ភស្ស មិនទាន់ឆ្លើយតបចំពោះបញ្ហាដែលសង្គមស៊ីវិលសង្កេតឃើញនេះទេ ខណៈដែលអ្នកនាំពាក្យក្រសួងការងារក៏មិនអត្ថាធិប្បាយពីបញ្ហាទាំងនេះដែរ។

តាមរបាយការណ៍របស់អង្គការសង់ត្រាល់បង្ហាញថា ពលករខ្មែរដែលកំពុងធ្វើការងារ នៅក្នុងប្រទេសថៃមានប្រមាណជាង២លាននាក់ក្នុងនោះអ្នកមិនមានឯកសារស្របច្បាប់ដោយផុតសុពលភាពការងារនិងឆ្លងដែនខុសច្បាប់មានប្រមាណ១លាននាក់។ អង្គការនេះបញ្ជាក់ថា អ្នកដែលមិនមានឯកសារស្របច្បាប់ប្រឈមមុខច្រើនដូចជា រងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការចាប់ខ្លួនពីសំណាក់អាជ្ញាធរថៃ៕

## សេតវិមានសហរដ្ឋអាមេរិក សន្យានឹងបង្ក្រាបលើការប្រើប្រាស់ពលកម្មកុមារចំណាកស្រុក

https://www.postkhmer.com/international/2023-02-28-1341-247456.html ឡេង អារីតា | Publication date 28 February 2023 | 13:41 ICT

រដ្ឋបាលរបស់ប្រធានាធិបតីលោក ចូ បៃដិន (Joe Biden) កាលពីថ្ងៃចន្ទ បាននិយាយថា ខ្លួននឹងចាត់វិធានការបង្ក្រាបបទល្មើសកេងប្រវ័ញ្ចកម្លាំងពលកម្មខុសច្បាប់ទៅលើកុមារចំណាកស្រុក នៅក្នុងសហរដ្ឋអាមេរិក។ ក្នុងរយៈពេល៥ ឆ្នាំក្រោយនេះគេសង្កេតឃើញថា កុមារចំណាកស្រុកជាង ៤ ០០០នាក់ បានទទួលរងការរំលោភបំពានច្បាប់ការងារនៅក្រោមក្រុមហ៊ុនរាប់រយកន្លែង។បញ្ហានេះ បានធ្វើឱ្យរដ្ឋលេខាធិការនៃសេវាថែទាំសុខាភិបាលនិងមនុស្ស គឺលោក Xavier Becerra មានការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះ កុមារចំណាកស្រុក ដែលត្រូវបានបណ្តេញចេញ ពីជម្រករបស់សហព័ន្ធលឿនពេក និងបណ្តាលឱ្យពួកគេធ្លាក់ចូលទៅក្នុងស្ថានភាពងាយរងគ្រោះ ដែលទំនងជាក្លាយជាជនរងគ្រោះនៃពលកម្មកុមារផងដែរ។

យោងតាមវីដេអូថ្មីមួយដែលត្រូវបានផ្សព្វផ្សាយ និងរាយការណ៍ដំបូងដោយសារព័ត៌មាន The New York Times បានបង្ហាញថា ក្រុមលេខាធិការបានជំរុញឱ្យបុគ្គលិករបស់គាត់នាំកុមារចេញពីជម្រក ខូចខាតមួយចំនួនរបស់រដ្ឋាភិ បាលសហព័ន្ធឱ្យបានឆាប់រហ័ស។ មិនតែប៉ុណ្ណោះ តាមការស៊ើបអង្កេតរបស់កាសែតដដែលនេះ បានកំណត់អត្តសញ្ញាណកុមារចំណាកស្រុកជាង ១០០ នាក់ដោយក្នុងនោះរួមមាន ក្មេងអាយុ ១២ឆ្នាំ ដែលបានរាយការណ៍ប្រាប់ដល់កាសែតថា ពួកគេកំពុងធ្វើការវេនយប់ និងការងារគ្រោះថ្នាក់ខ្លះសម្រាប់ក្រុមហ៊ុនទាំងធំ និងតូចនៅក្នុងសហរដ្ឋអាមេរិក។

គួរបញ្ជាក់ផងដែរថា ចាត់តាំងពីលោក Joe Biden ឡើងតំណែងជាប្រធានាធិបតីមក អាត្រាជនចំណាកស្រុក រួមទាំងកុមារធ្វើដំណើរម្នាក់ឯងមកកាន់សហរដ្ឋអាមេរិក កើនឡើង ៣៧% ឬ២ ដងនៃកម្រិតខ្ពស់បំផុតបើធៀបទៅនិងអាណត្តិ Donald Trump ឆ្នាំ២០១៩។ កាលពីថ្ងៃចន្ទផងដែរ HHS និងនាយកដ្ឋានការងារ បានដាក់ចេញនូវគោលនយោបាយថ្មីក្នុងការងារ រួមទាំងសន្យាថានឹងបង្កើនការតាមដានឱ្យ កាន់តែខ្លាំងទៅលើកុមារដែលបានផ្លាស់ប្តូរទីជម្រកទៅរស់នៅជាមួយអ្នកឧបត្ថម្ភនៅសហរដ្ឋអាមេរិក ដោយទីភ្នាក់ងារទាំងអស់នោះនិងជួយកុមារចំណាកស្រុកឱ្យចុះឈ្មោះចូលរៀន និងតម្រូវឱ្យបុគ្គលិកតាមមជ្ឈមណ្ឌលនីមួយៗតាមដានកុមារនិងរាយការណ៍ពីសុវត្ថិភាពរបស់ពួកគេ។ ក្រៅពីនេះ ក្រសួងការងារក៏បានគំរាមបញ្ឈប់ការដឹកជញ្ជូនផលិតផលដែលផលិតដោយកម្លាំងពលកម្មកុមារផងដែរ៕

# ថ្ងៃទី០២ ខែ មីនា ឆ្នាំ២០២៣

## កម្មករខ្មែរស្លាប់ក្នុងឧប្បត្តិហេតុការដ្ឋានសំណង់ ក្នុងទីក្រុងបាងកក

https://www.khmertimeskh.com/501247453// Khmer Times March 1, 2023

សោកនាដកម្មបានកើតឡើងនៅការដ្ឋានសំណង់មួយក្នុងសង្កាត់ Chatuchak នៃទីក្រុងបាងកកកាលពីម្សិលមិញ នៅពេលដែលប៉មស្ទូចបានបាក់និងសម្លាប់កម្មករខ្មែរម្នាក់។ សារព័ត៌មានថៃប៉ុស្តិ៍លេខ៧បានរាយការណ៍ថា ខ្សែស្ទូចបានដាច់ បណ្តាលឲ្យដៃដងស្ទូចធ្លាក់មកលើកម្មករម្នាក់ឈ្មោះ សុផាន់ណា អាយុ៣១ឆ្នាំ។ កម្មករខ្មែរពីរនាក់ផ្សេងទៀតបានរងរបួសក្នុងហេតុការណ៍នេះ។ កម្មកម្នាក់ក្នុងចំណោមកម្មករដែលរងរបួសត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ Paolo ដោយមានរបួសស្រាល ចំណែកកម្មករម្នាក់ទៀតមិនចង់ទៅមន្ទីរពេទ្យទេ។

អនុលេខាអចិន្ត្រៃយ៍របស់ទីក្រុងបាងកក លោកបណ្ឌិត Wantanee Wattana រួមជាមួយនឹងនាយកសង្កាត់ Chatuchak លោក Pornlert Penpass បានចុះទៅពិនិត្យទីតាំងនោះ។ អគារនេះមានការិយាល័យ ២៩ ជាន់ សាលប្រជុំ ៣ ជាន់ និងចំណតរថយន្ត ៧ ជាន់។ វាត្រូវបានចុះកិច្ចសន្យានៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ហើយរយៈពេលសាងសង់បានចាប់ផ្តើមនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១។ គម្រោងនេះគ្រោងនឹងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ហើយសំណង់នេះមានតម្លៃ២.១ ពាន់លានបាត។ នេះមិនមែនជាលើកទីមួយទេ ដែលឧបទ្ទវហេតុបែបនេះបានកើតឡើងនៅក្នុងឧស្សាហកម្មសំណង់របស់ប្រទេសថៃ ដែលប្រឈមនិងវិធានការសុវត្ថិភាពរបស់ខ្លួន៕Thaiger

## ឆ្នាំ២០២២ ពលរដ្ឋរងគ្រោះនៅក្រៅប្រទេសជិត ៨ពាន់នាក់ ត្រូវបានជួយសង្គ្រោះ

https://btv.com.kh/article/20703 2023/03/01 03:48:06 pm

ភ្នំពេញ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា តាមរយៈស្ថានទូត និងកុងស៊ុលប្រចាំនៅប្រទេសនានា ក្នុងឆ្នាំ២០២២ បានជួយអន្តរាគមន៍សង្គ្រោះពលរដ្ឋខ្មែរ ដែលបានរងគ្រោះដោយអំពើផ្សេងៗ នៅក្រៅប្រទេស ប្រមាណជិត ៨ពាន់ ឲ្យបានវិលត្រឡប់មកប្រទេសកំណើតវិញ ។ ក្នុងសន្និបាទបូកសរុបលទ្ធផលការងារ ឆ្នាំ២០២២ និងលើកទិសដៅការងារ ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា នៅថ្ងៃទី១ ខែមីនា នេះ ឯកឧត្តម អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួង បានឱ្យដឹងថា ឆ្នាំ២០២២ ក្រសួង បានផ្តោតលើការដ្ឋានធំៗចំនួន៥ ក្នុងនោះ ទី១. ការការពារឯករាជ្យ អធិបតេយ្យ កិត្តិយស និងសេចក្តីថ្លៃថ្នូរជាតិ, ទី២. ការការពារបូរណភាពទឹកដីកម្ពុជា, ទី៣. ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរ នៅបរទេស, ទី៤. ទំនាក់ទំនងទ្វេភាគី និងទី៥. ទំនាក់ទំនងពហុភាគី ។

ឯកឧត្តម បានបន្តថា ចំពោះការងារការការពារផលប្រយោជន៍ពលរដ្ឋ ក្រសួងបានផ្តល់ការគាំទ្រ គាំពារ ជួយសង្គ្រោះ និងសម្របសម្រួលមាតុភូមិនិវត្តន៍ដល់ពលរដ្ឋខ្មែរ ដែលរងគ្រោះដោយការរំលោភសិទ្ធិសេរីភាពនៅបរទេស និងអំពើជួញដូរមនុស្ស ចំនួន៧៩៥៣នាក់ ក្នុងប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី ចិន ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា និងសិង្ហបុរី ។ ឯកឧត្តម បានបន្ថែមថា លើសពីនេះ ស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស បានយកចិត្តទុកដាក់ខ្ពស់ ក្នុងការប្រាស្រ័យទាក់ទងជាមួយពលរដ្ឋកម្ពុជារស់នៅជាបរទេស ដូចជា អាមេរិក បារាំង អឺរ៉ុប និងអូស្ត្រាលី ក៏ដូចជាសម្របសម្រួលដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ សិស្ស និស្សិត ពលករ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សានៅបរទេស រួមមាន៖ ការផ្តល់សេវារដ្ឋបាល កុងស៊ុល និងការឧបត្ថម្ភគាំពារផ្សេងៗ ៕ បាន សុខរិទ្ធិ

# ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២៣

## បុរសអាមេរិកម្នាក់ ត្រូវជាប់គុក ០៨ឆ្នាំ ដោយសារការទិញពេស្យាផ្លូវភេទ និងថតរំលោភក្មេងប្រុសកម្ពុជា ជាច្រើននាក់នៅខេត្តសៀមរាប

https://cen.com.kh/archives/626467.html Posted ByPen Srey NeatMarch 2, 2023

ភ្នំពេញៈ តុលាការកំពូល កាលពីព្រឹកថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០២៣នេះ បានបើកសវនាការជំនុំជម្រះ លើបណ្តឹងសាទុក្ខរបស់ពិរុទ្ធជន -បុរសជនជាតិអាមេរិកម្នាក់ ដែលបានតុលាការថ្នាក់ក្រោម កាត់ទោសដាក់ពន្ធនាគារ កំណត់ ០៨ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងបទល្មើសៈ ការទិញពេស្យាចារកុមារ រូបភាព និង ការផលិតសម្ភារៈអាសអាភាស និងបទ រំលោភសេព.សន្ថវៈ ប្រព្រឹត្តនៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ ២០១៨ ។

លោក ជីវ កេង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ Reldy John Patrick ភេទប្រុស អាយុ ៥៩ ឆ្នាំ(កើតឆ្នាំ ១៩៦៣) ជនជាតិអាមេរិក ។ ចំណែកឯ ក្មេងប្រុសខ្មែរ ដែលរងគ្រោះ មានចំនួន៤នាក់ មានអាយុពី ១៣ ដល់១៩ ឆ្នាំ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ឈ្មោះ Reldy John Patrick ត្រូវបានសាលាដំបូងខេត្តខេត្តសៀមរាប កាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៩ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៨ ឆ្នាំ និង ពិន័យ ចំនួន ៤ លានរៀល ក្រោមការចោទប្រកាន់ពីបទ : ការទិញពេស្យាចារកុមារ រូបភាព និង សម្ភារៈអាសអាភាស និងបទ រំលោភសេពសន្ថវៈ តាមមាត្រា ៣៤ និង មាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ និង មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

ជនជាប់ចោទ បានប្តឹងឧទ្ធរណ៍។ តែតុលាការឧទ្ធរណ៍ បានតម្កល់ទោសរបស់គាត់ដដែល។ គាត់ក៏ប្តឹងសាទុក្ខ មកតុលាការកំពូលទៀត។ ជនជាប់ចោទរូបនេះ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០១៩ នៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ នៅក្នុងសំណុំរឿងនេះ តុលាការកំពូល នឹងប្រកាសសាលដីកា នៅព្រឹកថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០២៣៕ រក្សាសិទ្ធិដោយៈ ចន្ទា ភា

## ក្រុមហ៊ុនសំណង់ធំរបស់សិង្ហបុរី ប្រកាសត្រូវការកម្លាំងពលកម្មពីកម្ពុជាលើផ្នែកសំណង់ដើម្បីទៅបម្រើការងារនៅប្រទេសសិង្ហបុរី

https://www.information.gov.kh/articles/98832 AKP ភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣

លោក Greory Lin នាយកប្រតិបត្តិក្រុមហ៊ុន KEN-PAL(S) PTE LTD និងជាក្រុមហ៊ុនសំណង់លំដាប់ថ្នាក់ទី១ របស់សិង្ហបុរីបានប្រកាសត្រូវការកម្លាំងពលកម្មពីកម្ពុជាលើផ្នែកសំណង់ ដើម្បីទៅបម្រើការងារនៅប្រទេសសិង្ហបុរី។ ការប្រកាសរបស់នាយកប្រតិបត្តិក្រុមហ៊ុនសិង្ហបុរីនេះ ក្នុងឱកាសជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លោក Greory Lin បានស្នើសុំកិច្ចសហការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងជាមួយភាគីកម្ពុជា ក្នុងការបញ្ជូនកម្លាំងពលកម្មផ្នែកសំណង់ និងគាំទ្រក្រុមហ៊ុនក្នុងការបញ្ជូនកពលករផ្នែកសំណង់ ឱ្យបានទៅធ្វើការនៅប្រទេសសិង្ហបុរីនាពេលខាងមុខ។

ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានគាំទ្រចំពោះការស្នើសុំរបស់ខាងក្រុមហ៊ុនសិង្ហបុរី ដែលចាត់ទុកថានេះជាឱកាសមួយបន្ថែមទៀតសម្រាប់ពលករកម្ពុជា ក្នុងការលើកកម្ពស់ជំនាញ ទទួលបានប្រាក់ចំណូល និងនាំយក

ចំណេះជំនាញមកជួយដល់សង្គមជាតិវិញ។ ឯកឧត្តមបានគូសបញ្ជាក់ថា នៅកម្ពុជា វិស័យសំណង់នេះ រីកដុះដាល ខ្លាំង លើការសាងសង់អគារ ហេដ្ឋារចនាសម្ព័ន្ធនានា ហើយក្រសួងផ្ទាល់ក៏មានការផ្តល់នូវការបណ្តុះបណ្តាលជំនាញផ្នែកសំណង់នេះ ដល់ប្រជាពលរដ្ឋ យុវជនកម្ពុជាក្នុងការពង្រឹងសមត្ថភាពបន្ថែមផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី បានលើកឡើងថា មុននឹងធ្វើការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូន ត្រូវរៀបចំជានីតិវិធី លើកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរសិន។

នាឱកាសនោះដែរ លោក Greory Lin នាយកប្រតិបត្តិក្រុមហ៊ុន បានចែករំលែកនូវព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុន ជម្រាបជូនដល់ឯកឧត្តមរដ្ឋមន្ត្រីថា ក្រុមហ៊ុនសំណង់របស់សិង្ហបុរីមួយនេះ បង្កើតឡើងតាំងពីឆ្នាំ១៩៨៩ ដែលផ្តោតលើឧស្សាហកម្មសំណង់ក្នុងស្រុក តាមតម្រូវការសំណង់អគារទាំងរដ្ឋ និងឯកជន ហើយទទួលបានពានរង្វាន់ឆ្នើមផ្នែកសំណង់ សុខភាព សុវត្ថិភាពការងារ និងបរិស្ថាន។ លោកបានឱ្យដឹងថា ក្នុងដំណើរទស្សនកិច្ចរបស់ក្រុមហ៊ុនមកកម្ពុជា គឺដើម្បីជួបជាមួយសាស្ត្រាចារ្យផ្នែកសំណង់ស៊ីវិល នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ និងវិទ្យាស្ថានជាតិពហុបច្ចេកទសកម្ពុជា ដើម្បីឈ្វេងយល់ពីកម្មវិធីសិក្សាដែលទាក់ទងនឹងសំណង់ស៊ីវិល។

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានវាយតម្លៃខ្ពស់ចំពោះក្រុមហ៊ុនដែលមានប្រវត្តិយូរមកហើយ និងមានស្តង់ដារខ្ពស់ខាងផ្នែកសំណង់នេះ។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្ថែមថា ពាក់ព័ន្ធកិច្ចសហការលើការងារកម្លាំងពលកម្ម នាពេលកន្លងមក កម្ពុជាបានបញ្ជូនស្ត្រីជំនួយការផ្ទះ ទៅសិង្ហបុរី ប្រមាណជាងមួយពាន់នាក់ ហើយសង្កេតឃើញថា ការជ្រើសរើស និងបញ្ជូនទៅធ្វើការនៅសិង្ហបុរី មានសុវត្ថិភាព និងទទួលបានប្រាក់ចំណូលខ្ពស់សមរម្យ៕ដោយ៖ រិទ្ធី, ប្រភព៖ ក្រសួងការងារ សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរមួយក្រុម<br>ធ្វើការនៅប្រទេសថៃមានជីវភាពខ្វះខាតក្រោយពីអត់ការងារធ្វើជិតមួយខែ

https://www.rfa.org/khmer/news/social-economy/a-group-khmer-workers-in-thailand-living-with-hardship-after-losing-jobs-03012023212935.html ដោយ ឡេង ម៉ាលី2023.03.01

ពលករខ្មែរមួយក្រុម ធ្វើការនៅទីក្រុងបាងកក ប្រទេសថៃ ប្រឹងត្រដររស់នៅទាំងវេទនា ក្រោយពីអត់ការងារធ្វើអស់រយៈពេលជិត ១ខែ។ មន្ត្រីសង្គមស៊ីវិលថា បញ្ហាពលករអត់ការងារធ្វើកើតមានស្ទើរតែគ្រប់កន្លែង និងស្នើដល់អាជ្ញាធរខ្មែរ គួរតែជួយស្វែងរកដោះស្រាយជូនពលករឱ្យបានឆាប់ ដើម្បីសម្រួលដល់ការរស់នៅរបស់ពលករ ។

ពលករខ្មែរមួយក្រុមនេះមានគ្នាជាង ៣០នាក់ សព្វថ្ងៃនេះ កំពុងស្នាក់នៅប្រទេសថៃដោយខុសច្បាប់។ ពួកគាត់អះអាងថា ថៅកែបានសន្យានឹងជួយធ្វើឯកសារឱ្យពួកគាត់ឱ្យបានឆាប់ៗ ដើម្បីបានធ្វើការឡើងវិញ។ ពួកគាត់ថា ថៅកែបានទារលុយពីពលករក្នុងម្នាក់ជាង ១ម៉ឺនបាត (១០.០០០បាត) ដែលស្មើជាង ១លានរៀល (១.០០០.០០០៛) ដើម្បីយកទៅធ្វើប័ណ្ណការងារ។ នៅក្នុងបន្ទប់តូចចង្អៀត ដែលមានទំហំជាង ៣ម៉ែត្របួនជ្រុង ពោរពេញដោយខោអាវ និងឆ្នាំងចាន។ ពលករទាំងនោះ ភាគច្រើនមកពីខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប។ ពួកគាត់មកជាមួយ ប្តីប្រពន្ធ និងកូន ដើម្បីរកការងារធ្វើនៅប្រទេសថៃ។ អស់រយៈពេលជិត ១ខែនេះ ពួកគាត់មិនហ៊ានដើរចេញក្រៅ ឆ្ងាយពីកន្លែងដែលខ្លួនស្នាក់នៅឡើយ ព្រោះខ្លាចប៉ូលិសថៃចាប់ពួកគាត់បញ្ជូនមកខ្មែរវិញ ខណៈដែលខ្លួនពុំមានលិខិតឆ្លងដែន និងប័ណ្ណការងារត្រឹមត្រូវឡើយ។ ចំណែកការចំណាយលើការហូបចុកវិញ ពួកគាត់មិនមានលុយសម្រាប់ទិញបាយហូបនោះទេ ដូច្នេះជារៀងរាល់ព្រឹក ល្ងាច ពួកគាត់ទៅទិញស្បៀងអាហារបន្លែត្រីសាច់ជំពាក់គេ នៅកន្លែងលក់ឥវ៉ាន់មួយក្បែរនោះយកមកហូបចុកប្រចាំថ្ងៃ។ ពួកគាត់សន្យាថា នឹងសងលុយគេវិញ ពេលបានចូលធ្វើការវិញ។

ពលករខ្មែរម្នាក់រស់នៅស្រុកក្រឡាញ់ ខេត្តសៀមរាប លោកស្រី ស៊ូ រៀន ប្រាប់វិទ្យុអាស៊ីសេរីថា លោកស្រីមកធ្វើការនៅប្រទេសថៃនេះ តាំងពីដើមខែធ្នូ ឆ្នាំ២០២២ ប៉ុន្តែនៅដើមខែកុម្ភៈនេះ ថៅកែឱ្យក្រុមពួកលោកស្រីដែលមានគ្នា ១១នាក់ សម្រាកពីការងារជាបណ្ដោះអាសន្ន ព្រោះឯកសារការងារធ្វើមិនទាន់ហើយ។ លោកស្រីថា បើសិនជាពួកគាត់បន្តធ្វើការទៀត ប៉ូលិសនឹងចុះចាប់។ លោកស្រី ស៊ូ រៀន៖ «បារម្ភ ពិបាក អត់ហ៊ានចេញទៅណាទេ នៅក្នុង ខិម [បន្ទប់]នេះ នៅតែក្នុងនេះអត់ហ៊ានចេញទៅណាទេ ព្រោះយើងខ្លាចអត់មានស្អី [លិខិតឆ្លងដែន] កាន់នៅក្នុងដៃ។ អត់ហ៊ានទៅខាងក្រៅដូចពួកគាត់មកលេងទីនេះ អត់ហ៊ានចេញទៅទេ តាំងពីទើបនឹងចូលនៅទីនេះមុន ពីម៉ែ [ឆ្លងឆ្នាំ] កាលពីឆ្នាំ២០២២»។

ស្រដៀងគ្នានេះពលករម្នាក់ទៀត លោក លឿង រដ្ឋា ដែលមកធ្វើការនៅប្រទេសថៃជិត ១០ឆ្នាំជាមួយប្រពន្ធរបស់ខ្លួន លើកឡើងថា លោកធ្លាប់អត់ការងារធ្វើជាច្រើនដងមកហើយ ភាគច្រើន គឺបញ្ហាធ្វើលិខិតឆ្លងដែន និងប័ណ្ណការងារ។ លោកថា ដោយសារតែការធ្វើឯកសារយឺតយ៉ាវ និងស្មុគស្មាញ ស្របពេលដែលការចំណាយថវិកាវិញក៏ច្រើន ដែលធ្វើឱ្យលោកជំពាក់បំណុលធនាគារកាន់តែច្រើន នៅពេលធ្វើឯកសារម្ដងៗ។ លោកថា ពលករទាំងអស់ពុំមាននរណាចង់ធ្វើការដោយខុសច្បាប់នោះទេ បើសិនជាការរៀបចំឯកសារទាំងនោះមានភាពងាយស្រួលជាងនេះ។ លោក លឿង រដ្ឋា៖ «ចង់ឱ្យទូតកម្ពុជា និងរដ្ឋាភិបាលជួយរៀបចំឯកសារ ដើម្បីងាយស្រួលក្នុងការធ្វើការឆាប់បានឱ្យពលករហ្នឹងចូលធ្វើការ ហើយពេលធ្វើដំណើរនៅតាមច្រកព្រំដែន ជួយកាត់បន្ថយការរឿងសេវាឱ្យចំណាយតិចតួចកុំឱ្យសូវច្រើនពេក កុំឱ្យមានបញ្ហា»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងរដ្ឋលេខាធិការក្រសួងការងារ លោក ហេង សួរ និងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី២៧ ខែកុម្ភៈ ដោយសារហៅទូរស័ព្ទចូលតែគ្មានអ្នកទទួល។ ទោះយ៉ាងណាក្ដី មន្ត្រីកុងស៊ុលខ្មែរ ប្រចាំស្ថានទូតនៅប្រទេសថៃ លោក ផៃ លន បដិសេធមិនឆ្លើយតបជុំវិញរឿងនេះ ដោយលោកថា កំពុងជាប់រវល់ចុះជួបពលករខ្មែរ។

លោក ផៃ លន៖ «ខ្ញុំរវល់ណាស់ កំពុងតែជួបភ្ញៀវ កំពុងតែជួបបងប្អូនពលករយើងហ្នឹងហើយ អរគុណបាទ!»។ ពលករខ្មែរធ្វើការសំណង់នៅប្រទេសថៃភាគច្រើន ពួកគាត់អាចរកចំណូលបានក្នុងម្នាក់ ៣០០បាត ទៅ ៥០០បាត ក្នុងមួយថ្ងៃ ដែលស្មើជាង ៣០.០០០រៀល ទៅជាង ៥.០០០រៀល ក្នុងមួយថ្ងៃ។ ពួកគាត់ចូលធ្វើការចាប់ពីម៉ោង ៧ព្រឹកដល់ម៉ោង ៥ល្ងាច។ ចំណែកពលករ ដែលចង់បានលុយថែមម៉ោង ពួកគាត់អាចបន្តធ្វើការពេលយប់ចាប់ពីម៉ោង ៥ល្ងាចរហូតដល់ ១១យប់ ដែលក្នុងម្នាក់ទទួលបាន ៣០០បាតថែមទៀតក្នុងមួយថ្ងៃ។ ទោះយ៉ាងនេះក្ដី ពួកគាត់ថា ការងារធ្វើការសំណង់នេះ ត្រូវតស៊ូប្រឹងប្រែងដោយលំបាក និងហានិភ័យខ្ពស់ដល់អាយុជីវិត នៅពេលដែលឡើងលើអគារខ្ពស់ៗ។

ជុំវិញរឿងនេះ មន្ត្រីផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃ នៃអង្គការសង់ត្រាល់ (Central) លោក លឹង សុផុន កត់សម្គាល់ឃើញថា ពលករខ្មែរ ដែលមកធ្វើការនៅប្រទេសថៃខុសច្បាប់ភាគច្រើន ប្រឈមអត់ការងារធ្វើជាបន្តបន្ទាប់។ លោកថា បញ្ហានេះមានស្ទើរតែគ្រប់កន្លែង ជាពិសេស តំបន់ដែលសម្បូរពលករខ្មែររស់នៅ ដូចជា ខេត្តសាមុត ប្រាកាន (Samut Prakan Province) និងខេត្ត ឈុនបុរី (Chonburi) ជាដើម។ លោកថា ប្រសិនបើបញ្ហានេះ អាជ្ញាធរខ្មែរមិនឆាប់ជួយអន្តរាគមន៍ដល់ពួកគាត់ទេ នោះ នឹងធ្វើឱ្យជីវភាពពលករខ្មែរ កាន់តែលំបាក។ លោក លឹង សុផុន៖ «អ៊ីចឹងបើសិនជាស្ថានពាក់ព័ន្ធដែលបានដឹងដំណឹង ឬក៏បានយល់ពីបញ្ហានេះហើយគួរដោះស្រាយដោយវិធីណាហើយ មានវិធានការដើម្បីកែប្រែខ្ញុំគិតថាវាជារឿងល្អ ឬក៏យើងមានវិធានការបណ្ដុះបណ្ដាលអប់រំតាមអ្វីដែលយើងអាចធ្វើបាន នេះវាជារឿងល្អប្រសើរ តែបើសិនជាយើងមិនធ្វើអ៊ីចឹងទេ បងប្អូនពលករនៅថៃហ្នឹងកាន់តែក្លាយជាជនរងគ្រោះច្រើនទៅៗ»។

ចាប់តាំងពីខែមករា ដល់ខែកុម្ភៈនេះ អ្នកឃ្លាំមើលបញ្ហាពលករខ្មែរនៅប្រទេសថៃឱ្យដឹងថា មានពលករខ្មែរជាង ២០០នាក់ ហើយនៅតាមតំបន់ផ្សេងៗ ក្នុងប្រទេសថៃ ពួកគាត់ដាច់ស្បៀង និងអត់ការងារធ្វើដោយសារតែពុំមានឯកសារត្រឹមត្រូវសម្រាប់ធ្វើការ។ មិនតែប៉ុណ្ណោះពួកគាត់ក៏ត្រូវបានមេខ្យល់ និងថៅកែថៃបោកប្រាស់កម្លាំងពលកម្ម។ បញ្ហាទាំងនេះធ្វើឱ្យពលករខ្មែរទាំងនោះប្រឹងត្រដររស់នៅដោយវេទនា។ ពួកគាត់ទទូចឱ្យអាជ្ញាធរពាក់ព័ន្ធជួយរកដំណោះស្រាយជូនពួកគាត់ឱ្យបានឆាប់ ដើម្បីពួកគាត់មានលទ្ធភាពអាចចូលធ្វើការឡើងវិញ រកប្រាក់ដោះស្រាយជីវភាពគ្រួសារ៕

# ថ្ងៃទី០៦ ខែ មីនា ឆ្នាំ២០២៣

## ក្រសួងមហាផ្ទៃ
## បន្តចុះ MOU ជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីរួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស

https://www.kampucheathmey.com/local-news/473552 ថ្ងៃសុក្រ ៣ មីនា ២០២៣ដោយ sopheak khoun

ក្រសួងមហាផ្ទៃ បានបន្តចុះអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយអង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជា ស្តីពី ការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់នីតិជន នៅព្រះរាជាណាចក្រកម្ពុជា។ ពិធីអនុស្សរណៈយោគយល់គ្នា ធ្វើឡើងនៅព្រឹកថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០២៣នេះ ក្រោមអធិបតីភាពលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) នៅទីស្តីការក្រសួងមហាផ្ទៃ។

លោកស្រី ជូ ប៊ុនអេង លើកឡើងក្នុងឱកាសនោះថា ការចុះអនុស្សរណៈជាមួយអង្គការក្រៅរដ្ឋាភិបាលនេះ គឺដើម្បីរួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានលើកុមារនៅកម្ពុជា ឲ្យមានប្រសិទ្ធភាពបន្ថែមទៀត ខណៈបញ្ហានេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជា បានកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងនោះ។ លោកស្រី បានឲ្យដឹងដែរថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានធ្វើការជាមួយដៃគូជាច្រើន រួមទាំងអង្គការសហប្រជាជាតិផងនោះ ដោយបានខិតខំយ៉ាងសកម្មក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានលើមនុស្សគ្រប់ប្រភេទ ដោយមិនប្រកាន់និន្នាការអ្វីនោះឡើយ។ ជាមួយគ្នានេះ លោកស្រី ជូ ប៊ុនអេង បានសម្តែងនូវក្តីសោមនស្សរីករាយ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចសហ ការល្អជាមួយអង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជានាពេលនេះ ដែលបានក្លាយទៅជាដៃគូមួយទៀត ក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សូមជម្រាបថា ការចុះអនុស្សរណៈជាមួយអង្គការក្រៅរាជរដ្ឋាភិបាល និងដៃគូនានានេះ គឺមានគោលបំណងដូចជា៖ ការសហការប្រមូលព័ត៌មាន សម្រាប់ជំនួយដល់នីតិវិធីច្បាប់, ការសហការក្នុងការធ្វើអន្តរាគមន៍ និងសង្គ្រោះ, ការសហការសម្របសម្រួល ក្នុងការលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាព, ការសហការសិក្សាស្រាវជ្រាវ និងតស៊ូមតិ ដើម្បីវិភាគ ចងក្រងរបាយការណ៍ អំពីបេកគំហើញ និងអនុសាសន៍ជាដើម៕

## ក្រសួងការបរទេសបានជួយសង្គ្រោះពលរដ្ឋជិត ៨ពាន់នាក់ពីអំពើជួញដូរក្នុងឆ្នាំ២០២២

https://www.kampucheathmey.com/local-news/472218 ថ្ងៃសៅរ៍ ៤ មីនា ២០២៣ដោយ Thoeun Vansong

ក្នុងពិធីបើកសន្និបាតប្រចាំរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនាថ្ងៃទីពុធនេះលោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការប្រចាំក្រសួងការបរទេស បានថ្លែងឲ្យដឹងថា ក្នុងរយៈពេលនៃឆ្នាំ២០២២ កន្លងទៅ ក្រសួងបានជួយសង្គ្រោះ និងសម្របសម្រួលដល់ពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរមនុស្សចំនួនជិត ៨ពាន់នាក់។

បើតាមរបាយការណ៍ដែលអានដោយលោក អ៊ុច បូរិទ្ធ បានឲ្យដឹងដូច្នេះថា៖ «ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្តល់ការគាំពារ ជួយសង្គ្រោះ និងសម្របសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ដល់ពលរដ្ឋកម្ពុជាដែលរងគ្រោះដោយការរំលោភសិទ្ធិសេរីភាព និងអំពើជួញដូរមនុស្សចំនួន៧ ៩៥៣នាក់ពីប្រទេសចំនួន៨ ជាអាទិ៍ ថៃ ឡាវ វៀតណាម ម៉ាឡេស៊ី ចិន ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី»។

ជាមួយគ្នានេះ លោក អ៊ុច បូរិទ្ធ បានគូសបញ្ជាក់ថា ស្ថានទូតរបស់កម្ពុជាប្រចាំនៅបណ្តាប្រទេសនានាតែងតែបានយកចិត្តទុកដាក់ខ្ពស់ក្នុងការប្រាស្រ័យទាក់ទងជាមួយពលរដ្ឋកម្ពុជាដែលរស់នៅបរទេសជាប់ជាប្រចាំ ជាពិសេសប្រជាពលរដ្ឋកម្ពុជាដែលរស់នៅសហរដ្ឋអាមេរិក បារាំង អឺរ៉ុប និងអូស្ត្រាលី ជាដើម។ ក្នុងនោះ ស្ថានទូតកម្ពុជា ក៏បានសម្របសម្រួលដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ សិស្ស និស្សិត ពលករ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សានៅបរទេស ដែលរួមមានការផ្តល់សេវារដ្ឋបាល សេវាកុងស៊ុល និងការឧបត្ថម្ភគាំពារផ្សេងៗជាច្រើន។

ពាក់ព័ន្ធនឹងទំនាក់ទំនងទ្វេភាគី គឺកម្ពុជាបានបន្តពង្រឹងទំនាក់ទំនង និងសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសជាមិត្តជាច្រើននៅលើពិភពលោក តាមរយៈសកម្មភាពរបស់ស្ថានទូត និងស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅប្រទេសទាំងនោះ។ យោងតាមរបាយការណ៍ គិតមកដល់ពេលនេះ កម្ពុជា មានស្ថានទូត និងស្ថានតំណាងអចិន្ត្រៃយ៍ប្រចាំនៅបរទេសចំនួន៣១ ស្ថានអគ្គកុងស៊ុលចំនួន១២ កុងស៊ុលកិត្តិយសចំនួន២៦ និងមានមន្ត្រីការទូតដែលកំពុងបម្រើការ និងបំពេញបេសកកម្មនៅបរទេសសរុបចំនួន ២០២នាក់៕ ដោយ៖ ធឿន វ៉ាន់សុង

## ក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារចុះ MOU ដើម្បីស្វែងរកយុត្តិធម៌ជូនអនីតិជន

https://www.postkhmer.com/national/2023-03-03-1350-247612.html សុខ វត្ថា | Publication date 03 March 2023 | 13:50 ICT

ក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារ (CPU) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាដើម្បីចូលរួមចំណែកសកម្មភាពមនុស្សធម៌ និងស្វែងរកយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជនជាពិសេសឆ្លើយតបទៅនឹងការបង្ក្រាបបទល្មើសនានា ពាក់ព័ន្ធទៅនឹងកុមារ។

ពិធីៈហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ ធ្វើឡើងរវាងលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ.) និងអង្គភាពការពារកុមារ(CPU) នៃអង្គការមូលនិធិកុមារកម្ពុជា ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជននៅកម្ពុជា ២០២២-២០២៤ នៅព្រឹកសុក្រថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣។ នេះបើតាមក្រសួងមហាផ្ទៃបានបង្ហោះនៅលើហ្វេសប៊ុក។

លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍ថា៖« ក្រសួងមហាផ្ទៃ នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការមូលនិធិកុមារកម្ពុជា (CPU) រឹតតែមានភាពជិតស្និទ្ធ ព្រមទាំងឆ្លើយតបបានលឿន ចំពោះបទល្មើសដែលកើត

មានឡើងនៅកម្ពុជា ព្រមទាំងបន្តគាំទ្រចំពោះសកម្មភាពរបស់អង្គភាព CPU ដើម្បីកុមារផងដែរ»។ ជាមួយគ្នានេះ លោកស្រី បានសម្តែងសេចក្តីរីករាយ ក្នុងនាមក្រសួងមហាផ្ទៃ សម្រាប់ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាថ្មីម្តងទៀត ជាមួយអង្គភាព CPU ដែលបានធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ហើយក៏ទទួលបានលទ្ធផលល្អប្រសើរទាក់ទងទៅនឹងការបង្ក្រាបបទល្មើសនានា ជាពិសេស បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធទៅនឹងកុមារ។ លោកស្រី បានសង្កេតឃើញថា ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ការអនុវត្តបង្ក្រាបបទល្មើសនានា អង្គភាព CPU បានស្គាល់បទពិសោធន៍កាន់តែច្បាស់ក្នុងទម្រង់បទល្មើសដែលមានទៅលើកុមារនៅកម្ពុជា។

ទន្ទឹមនេះ លោក James McCabe នាយកទទួលបន្ទុកប្រតិបត្តិការរបស់អង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា បានថ្លែងអំណរគុណចំពោះក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលតែងតែគាំទ្រចំពោះសកម្មភាពរបស់អង្គភាពCPU។ លើសពីនេះ លោកក៏បានថ្លែងអំណរគុណចំពោះ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលតែងតែជំរុញកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសនានាពាក់ព័ន្ធទៅនឹងកុមារ។ នាឱកាសនោះដែរលោក James McCabe បានរំឭកដែរថា អង្គភាពបានធ្វើកិច្ចសហប្រតិបត្តិការអស់រយៈពេល១០ឆ្នាំកន្លងមកហើយជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ លើការងារដើម្បីកុមារនៅកម្ពុជានេះ។

សូមជម្រាបជូនដែរ ក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នា (MOU) ស្តីពីការចូលរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អនីតិជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២-២០២៤ នាពេលនេះ គឺលើកទី ០៤ ហើយ៕

## តុលាការកំពូល បដិសេធបណ្តឹងសុំនៅក្រៅឃុំ របស់បុរសជាប់ចោទ៣នាក់ ជាប់ពាក់ព័ន្ធនឹងអំពើ សមគំនិតក្នុងអំពើជួញដូរមនុស្ស និង បទសម្អាតប្រាក់

https://cen.com.kh/archives/627607.html Posted ByPen Srey NeatMarch 4, 2023

ភ្នំពេញ: តុលាការកំពូលកាលពីព្រឹក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២៣ នេះ បានប្រកាសសាលដីកាបដិសេធបណ្តឹង សុំនៅក្រៅឃុំបណ្តោះអាសន្ន របស់ជនជាប់ចោទ ចំនួន ៣នាក់ ដែលត្រូវបាន តុលាការថ្នាក់ក្រោម ចាប់ខ្លួនគាត់ដាក់គុកបណ្តោះអាសន្ន ជាប់ពាក់ព័ន្ធនឹងការ សមគំនិតក្នុងអំពើជួញដូរមនុស្ស ដោយមានគោលដៅ និង បទសម្អាតប្រាក់ ប្រព្រឹត្តនៅក្នុង ព្រះរាជាណាចក្រកម្ពុជា កាលកាលពីដើម ឆ្នាំ ២០២២ ។

លោក និល ណុន ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានឲ្យដឹងថា ជនជាប់ចោទ ៣នាក់ខាងលើមាន៖ ១- ឈ្មោះ ហង្ស សុគន្ធា ភេទប្រុស កើតឆ្នាំ១៩៨៩។ ២- ឈ្មោះ សេក មុន្នី ភេទប្រុស កើតឆ្នាំ១៩៩០ ។ ៣- ឈ្មោះ ទូត វ៉ាត់ ភេទប្រុស កើតឆ្នាំ ១៩៧៥ ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូង ខេត្តសៀមរាប កាលពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០២២ បានបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នពីបទ ″ សមគំនិតក្នុងអំពើជួញដូរមនុស្ស ដោយមានគោលដៅ តាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និង បទសម្អាតប្រាក់ តាមមាត្រា ២៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។ ពួកគេត្រូវបានសមត្ថកិច្ចនគរបាលរាជធានី ចាប់ខ្លួន កាលពី២០២២ នៅខេត្តសៀមរាប ។

ជនជាប់ចោទ ប្ដឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍បាត់ដំបងបានតម្កល់ សេចក្ដីសម្រេចរបស់ សាលាដំបូងរាជធានីភ្នំពេញ រក្សាទុកដដែល (អនុញ្ញាតឱ្យស្ថិតនៅក្រៅឃុំ)។ ជនជាប់ចោទ ក៏បានបន្តប្ដឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

# ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០២៣

## វៀតណាមស្នើកម្ពុជាឱ្យជួយសង្គ្រោះ និងបញ្ជូនពលរដ្ឋរបស់ខ្លួនដែលជាប់បង្ខាំងនៅបនល្បែងខុសច្បាប់ក្នុងប្រទេសកម្ពុជា

https://www.rfa.org/khmer/news/politics/vietnamese-leader-asks-cambodia-to-rescue-and-repatriate-its-citizens-detained-in-illegal-gambling-compound-in-cambodia-03052023184513.html

ដោយ មាន ឫទ្ធិ 2023.03.05

វៀតណាមស្នើឱ្យកម្ពុជាជួយសង្គ្រោះ និងបញ្ជូនពលរដ្ឋរបស់ខ្លួនដែលកំពុងជាប់បង្ខាំងដោយខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស នៅបនល្បែងខុសច្បាប់ក្នុងប្រទេសកម្ពុជា។ ចំណែកកម្ពុជាសន្យាថា នឹងពង្រឹងកិច្ចសហប្រតិបត្តិការ និងដោះស្រាយបញ្ហាឧក្រិដ្ឋកម្មទាំងនោះ ប្រកបដោយប្រសិទ្ធភាព។ អ្នកឃ្លាំមើលបញ្ហានយោបាយថា កម្ពុជាត្រូវរក្សាជំហរអព្យាក្រឹត្យមិនលំអៀងទៅរកប្រទេសណាមួយ ហើយត្រូវអនុវត្តទៅតាមច្បាប់ប្រកបដោយតម្លាភាពត្រឹមត្រូវ ក្នុងការលុបបំបាត់ឧក្រិដ្ឋកម្មខុសច្បាប់។

ការស្នើរបស់ភាគីវៀតណាមនេះ ធ្វើឡើងកាលពីថ្ងៃទី៤ ខែមីនា ក្នុងអំឡុងដំណើរទស្សនកិច្ចការងាររយៈពេល៣ថ្ងៃ របស់រដ្ឋមន្ត្រីមហាផ្ទៃ លោក ស ខេង នៅទីក្រុងហាណូយ (Hanoi) ប្រទេសវៀតណាម ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែមីនា។ ភាគីកម្ពុជា និងវៀតណាម ក៏បានចុះហត្ថលេខាលើផែនការសហប្រតិបត្តិការឆ្នាំ២០២៣ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម។

ទីភ្នាក់ងារសារព័ត៌មានវៀតណាម VNA ផ្សាយកាលពីថ្ងៃទី០៤ ខែមីនា ឱ្យដឹងថា ក្នុងជំនួបជាមួយនាយករដ្ឋមន្ត្រីវៀតណាម លោក ផាម ម៉ិញជីញ (Pham Minh Chinh) ភាគីវៀតណាមបានស្នើក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈវៀតណាម ឲ្យបន្តពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រប់ប្រភេទ ជាពិសេសឧក្រិដ្ឋកម្មឆ្លងដែន។ ភាគីវៀតណាមក៏ចង់ឃើញមានការសម្របសម្រួលក្នុងការជួយសង្គ្រោះពលរដ្ឋវៀតណាមដែលត្រូវបានបង្ខាំង និងបង្ខំឱ្យធ្វើការនៅតាមបនល្បែងខុសច្បាប់នៅកម្ពុជា។ នាយករដ្ឋមន្ត្រីវៀតណាមក៏បាន ស្នើឲ្យភាគីកម្ពុជាបន្តជួយគាំទ្រដល់សហគមន៍វៀតណាមនៅកម្ពុជាផងដែរ។ ទីភ្នាក់ងារសារព័ត៌មានវៀតណាម VNA ដដែលរាយការណ៍ថា ជាការឆ្លើយតបលោក ស ខេង បានសន្យាថានឹងបន្តធ្វើការជាមួយភាគីវៀតណាមដើម្បីដោះស្រាយបញ្ហានានាប្រកបដោយប្រសិទ្ធភាព។ លោក ស ខេង ក៏មិនភ្លេចអរគុណវៀតណាមចំពោះការណ៍ដែលលោកថាប្រទេសនេះបានជួយរំដោះកម្ពុជាកាលពីពេលអតីតកាល និងការចូលរួមចំណែកកសាង និងអភិវឌ្ឍកម្ពុជានាពេលបច្ចុប្បន្ន។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ និងអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បានទេ នៅថ្ងៃទី០៥ ខែមីនា ដើម្បីសុំអត្ថាធិប្បាយជុំវិញសំណើទាំងនេះរបស់ភាគីវៀតណាម។

អ្នកជំនាញផ្នែកវិទ្យាសាស្ត្រនយោបាយ លោក ឯម សុវណ្ណារ៉ា ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី០៥ ខែមីនាថា កិច្ចសហប្រតិបត្តិការផ្សេងៗ និងការទប់ស្កាត់បទល្មើសជួញដូរមនុស្ស រវាងកម្ពុជា និងវៀតណាមនេះ ជារឿងល្អដែលកន្លងទៅប្រទេសទាំងពីរបានធ្វើរួមគ្នារួចមកហើយ។ ប៉ុន្តែ លោកថា កម្ពុជាត្រូវតែឈរលើជំហរដែលត្រឹមត្រូវ

និងអនុវត្តទៅតាមច្បាប់។ លោកបន្តថា កម្ពុជា និងវៀតណាម ពុំសូវមានប្រវត្តិសាស្ត្រល្អជាមួយគ្នានោះទេ ដាក់ស្តែងបញ្ហាព្រំដែន និង ការមិនទទួលយកជនអន្តោប្រវេសន្តវៀតណាមខុសច្បាប់ ជាច្រើននៅកម្ពុជា មកវៀតណាមវិញ។

«សំខាន់កម្ពុជាប្រកាន់នូវគោលការណ៍ច្បាប់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ហើយកិច្ចសហប្រតិបត្តិការល្អជាមួយភាគីវៀតណាម ឬក៏ចិន គេហៅថាលោក ខាងកើតអស់នេះ គួរតែពង្រីកគេហៅថាប្រតិបត្តិការល្អជាមួយលោកខាងលិច លោក សេរី ដូចជាលោកអាមេរិក ជប៉ុន អូស្ត្រាលី និងអ៊ឺរ៉ុបជាដើមហ្នឹង ធ្វើឱ្យការបង្ហាញនូវនយោបាយការបរទេសកម្ពុជា អាចឈរនៅកណ្តាល និងអព្យាក្រឹត្យ»។ កន្លងទៅ សារព័ត៌មានជាតិ និងអន្តរជាតិបានរកឃើញថា កម្ពុជា ត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធើណិត (Scam) ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗ ហើយអ្នកទាំងនោះរងការបង្ខាំងទុកមិនឱ្យមានសេរីភាព ធ្វើទារុណកម្ម និងជំរិតទារប្រាក់ជាដើម។ ក្រសួងមហាផ្ទៃធ្លាប់អះអាងថា មានជនរងគ្រោះនៃអំពើជួញដូរនិងរត់ពន្ធមនុស្ស សរុបប្រមាណ ៩០០ នាក់ គិតចាប់តាំងពីដើមខែមករា រហូតដល់ថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០២២។

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ជនជាតិវៀតណាមប្រមាណ៤២នាក់បានសម្រុករត់ចេញពីការ ស៊ីណូ មួយកន្លែងស្ថិតក្នុងស្រុកកោះធំ ខេត្តកណ្តាល ជាប់ព្រំដែន កម្ពុជា វៀតណាម ដោយអ្នកខ្លះហែលឆ្លងទន្លេឆ្ពោះទៅកាន់ប្រទេសវៀតណាម ព្រោះពួកគេមិនអាចទ្រាំនឹងការធ្វើទារុណកម្មផ្សេងៗ។ កុមារអាយុ១៦ឆ្នាំបានលង់ទឹកស្លាប់ក្នុងហេតុការណ៍នេះ។ តំបន់ក្រហមដែលសង្ស័យថាមានការជួញដូរមនុស្សជាងគេនៅកម្ពុជា គឺនៅខេត្តព្រះសីហនុ និងក្រុងបាវិត ខេត្តស្វាយរៀង ដែលសម្បូរដោយបនល្បែងការ ស៊ីណូ របស់ជនជាតិចិន។ បើទោះបីបច្ចុប្បន្នករណីជួញដូរមនុស្ស និងការបើកបន់ល្បែងខុសច្បាប់ ហាក់មានភាពស្ងប់ស្ងាត់ជាងមុន ក៏តំបន់មួយចំនួនដូចភ្នំបូកគោ ខេត្តកំពត ត្រូវគេរកឃើញថាកំពុងតែប្រតិបត្តិការបើកបនល្បែងខុសច្បាប់ និងបង្ខាំងមនុស្ស ដោយពុំមានវិធានការត្រឹមត្រូវពីសំណាកអាជ្ញាធរនោះឡើយ។

លោក ឯម សុវណ្ណារ៉ា លើកឡើងថា អាជ្ញាធរកម្ពុជា ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ក្រាបឧក្រិដ្ឋកម្មខុសច្បាប់ ដើម្បីលើកមុខមាត់ប្រទេសជាតិឱ្យបានល្អ ដោយមិនត្រូវបង្កើនកិច្ចសហការតែជាមួយប្រទេសកុម្មុយនិស្តដូចជាវៀតណាម ឬចិនប៉ុណ្ណោះទេ តែកម្ពុជាត្រូវមានកិច្ចសហប្រតិបត្តិការទ្វេភាគីជាច្រើនទៀតជាមួយនឹងសហគមន៍អន្តរជាតិ ជាពិសេសប្រទេសលោក ខាងលិច៕

## មេខ្យល់ជនជាតិថៃជាឃាតកសម្លាប់ស្ត្រីពលករខ្មែរ

https://www.kampucheathmey.com/security/474509 ថ្ងៃចន្ទ ៦ មីនា ២០២៣ដោយ deth leng

ក្រោយពេលធ្វើការស្រាវជ្រាវទើបដឹងថា សពស្ត្រីពលករខ្មែរម្នាក់ដែលត្រូវបានកងល្បាតប្រទះឃើញ កាលពីថ្ងៃទី ១ ខែមីនាមានឈ្មោះ ស្វៃ សុភត្រា អាយុ៣៨ឆ្នាំ ទីលំនៅភូមិផ្អាំ ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ស្លាប់នៅ ព្រំដែន ស្រុកអូរជ្រៅ ជាប់ ណូនម៉ាក់។

កាលពីថ្ងៃទី១ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង២០នាទីរសៀល កងល្បាតទី៣ កងការពារព្រំដែនលេខ៥០៣ អូរបីជាន់ បានប្រទះឃើញសពស្ត្រីរូបនេះនៅក្នុងព្រៃចំការមីន ព្រំដែន ខាងលិចទំនប់ក៥ ពីផ្លូវជាតិលេខ៥៨ ស្ថិតនៅភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទល់មុខថ្នល់ខ្មៅថៃ ភូមិអាងសិលាថៃ ឃុំណូនម៉ាកមុន ស្រុកគោកធ្លុង ខេត្តស្រះកែវ ប្រទេសថៃ។ ការបើកការស៊ើបអង្កេត សមត្ថកិច្ចបានឈានដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះហុង ខាវសិរីវេត អាយុ ៥១ឆ្នាំ ជាមេខ្យល់ជនជាតិថៃ រស់នៅភូមិណាំគៀង ឃុំណូនម៉ាក់មុន ស្រុកគោកធ្លុង ខេត្តស្រះកែវប្រទេសថៃ នៅថ្ងៃទី ៥ ខែមីនា។

លោកឧត្តមសេនីយ៍ត្រីអ៊ុ សុផល ស្នងការរងទទួលផែនការងារព្រំដែនខេត្តបន្ទាយមានជ័យបាននឹងកំពុងសម្របសម្រួលជាមួយភាគីថៃឲ្យបញ្ជូនមកប្រទេសកម្ពុជាវិញ។ ការបំភ្លឺរបស់ ឈ្មោះ ពេជ្រ រត្ន អាយុ១៧ឆ្នាំ ត្រូវជាកូនប្រុសបង្កើតរបស់ស្ត្រីរងគ្រោះបានប្រាប់ថា នៅវេលាប្រហែលម៉ោង៩ និង ៣០នាទីម្តាយរបស់គាត់មកដល់ចំណុចផ្សាររោងគ្លឿ ស្រុកអារញ្ញប្រថេត ខេត្តស្រះកែវប្រទេសថៃ រួចបានបែកគ្នា មូលហេតុម្តាយមានប៉ាស្ព័រលិខិតឆ្លងដែនដែរ តែផុតថ្ងៃកំណត់សុពលភាពហើយ ក៏សម្រេចចូលមកកម្ពុជាវិញ តែដើរតាមច្រកផ្លូវកាត់ ច្រករបៀង ចំណែកខ្លួនជាកូនមានប៉ាស្ព័រ ក៏បានបោះត្រាចូលមកផ្លូវត្រង់ច្រកទ្វារអន្តរជាតិខ្លងលឹក ប៉ោយប៉ែតតែម្តងលុះដល់ម៉ោងប្រហែល៣រសៀលថ្ងៃទើបដឹងថា ម្តាយខ្លួនស្លាប់។

លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ឃាតករនោះលោកកំពុងធ្វើការទំនាក់ទំនងជាមួយភាគីថៃឲ្យបញ្ជូនមកស្រុកខ្មែរដើម្បីដាក់ទោសទៅតាមផ្លូវច្បាប់៕ អត្ថបទ៖ វ៉ាន់ ណាង

## ឃាត់ខ្លួនបុរសជនជាតិថៃម្នាក់ ពាក់ព័ន្ធនឹងអំពើឃា.តកម្ម ដោយប្ល.ន់ស.ម្លាប់ស្ត្រីពលករខ្មែរម្នាក់នៅច្រករបៀង នៃព្រំដែន នាស្រុកអូរជ្រៅ-ណូនម៉ាក់មុន

https://cen.com.kh/archives/628332.html Posted ByPen Srey NeatMarch 6, 2023

បន្ទាយមានជ័យៈ កម្លាំងសមត្ថកិច្ចនគរបាលស្រុកអូរជ្រៅ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យសហការនឹងនគរបាលការពារព្រំដែន នគរបាលដែនដីភាគីថៃ នៅស្រុកគោកធ្សូង ខេត្តស្រះកែវ កាលពីថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០២៣ បានធ្វើការ ឃាត់ខ្លួន ជនសង្ស័យជនជាតិថៃម្នាក់ ដែលជាមេខ្យល់ នាំពលករឆ្លងដែនខុសច្បាប់ ពាក់ព័ន្ធនឹងអំពើ ឃាតកម្ម ដោយប្លន់សម្លាប់ស្ត្រីពលករខ្មែរម្នាក់ ប្រព្រឹត្តកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ នៅចំណុចក្នុងព្រៃចំការមីនព្រំដែន ខាងលិចទំនប់ក៥ ពីផ្លូវជាតិលេខ៥៨ ស្ថិតនៅភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ គឺទល់មុខថ្នល់ខ្មៅថៃ ភូមិអាងសិលាថៃ ឃុំណូនម៉ាកម៉ុន ស្រុកគោកធ្សូង ខេត្តស្រះកែវប្រទេសថៃ ។

យោងតាមសមត្ថកិច្ចជំនាញបានឲ្យដឹងថា ជនសង្ស័យមានឈ្មោះ ហុង ខាវសិរីវេត (ហៅហុង) ភេទប្រុសអាយុ៥១ឆ្នាំ ជាមេខ្យល់ជនជាតិថៃ រស់នៅភូមិណាំគៀង ឃុំណូនម៉ាក់មុន ស្រុកគោកធ្សូង ខេត្តស្រះកែវ ប្រទេសថៃ។ ចំណែកឯ ជនរងគ្រោះ មានឈ្មោះ ស្វៃ សុភត្រា អាយុ ៣៨ ឆ្នាំ ទីលំនៅភូមិផ្គាំ ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ក្រោយឃាត់ខ្លួនជនសង្ស័យ, សមត្ថកិច្ចនៃភាគីទាំងពីរ បាននិងកំពុងសម្របសម្រួលនីតិវិធី ក្នុងការសួរចម្លើយជនសង្ស័យ និងនីតិវិធីបញ្ជូនមកប្រទេសកម្ពុជា ។

បច្ចុប្បន្ន, ជនសង្ស័យខាងលើ ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលជាតិ ដើម្បីរៀបចំបែបបទ និងកសាងសំណុំរឿង បញ្ជូនបន្តទៅកាន់តុលាការ ចាត់ការតាមនីតិវិធីច្បាប់ ។ ចំណែកឯ សាកសពរបស់ជនរងគ្រោះត្រូវបានសមត្ថកិច្ចប្រគល់ឲ្យទៅគ្រួសាររបស់ជនរងគ្រោះ ដើម្បីយកទៅធ្វើបុណ្យតាមប្រពៃណី ៕ ចន្ទា ភា

## រដ្ឋមន្រ្តីមហាផ្ទៃ ឱ្យពលរដ្ឋបន្តរួមគ្នាគាំទ្រ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

https://dap-news.com/national/2023/03/06/317034/ ByPH104Posted on March 6, 2023

**ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បានអំពាវនាវឱ្យប្រជាពលរដ្ឋ បន្តរួមគ្នាគាំទ្រ ការអនុវត្តគោល នយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។**

ក្នុងពិធីបុណ្យឆ្លងចេតិយ និងតម្កល់អដ្ឋិធាតុ ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធឧបាសិកា ស ស៊ន់ និងឧបាសកឈុន ឈាន ព្រមទាំងញាតិកាលទាំង ៧សន្តាន នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ សម្តេច ស ខេង បានរំលឹកអំពី

ប្រវត្តិក្រុមគ្រួសារ សម្តេច នៅភូមិកំណើត ពិសេសប្រវត្តិឆ្លងកាត់សង្គ្រាមបែកបាក់ និងផល នៃការបញ្ចប់សង្គ្រាម នាំមកនូវសុខសន្តិភាព និងការអភិវឌ្ឍទាំង នៅក្នុងមូលដ្ឋានឃុំក្រពៅ និងនៅទូទាំងប្រទេស។ សម្តេច មានប្រសាសន៍ថា «សូមអំពាវនាវ ឱ្យប្រជាពលរដ្ឋបន្តរួមគ្នាគាំទ្រ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព»។ នាឱកាសនោះ សម្តេច ក៏បានណែនាំពលរដ្ឋ ត្រៀមអញ្ជើញទៅបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រនីតិកាលទី៧ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខនេះឱ្យបានគ្រប់ៗ ដើម្បីគាំទ្រលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ពិសេសគាំទ្រការដឹកនាំដ៏ត្រឹមត្រូវ របស់រាជរដ្ឋាភិបាលកម្ពុជា។

គួរបញ្ជាក់ថា លក្ខណសម្បត្តិ របស់ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព មានចំនួន០៧ យ៉ាង រួមមាន៖ ទី១-ផ្តល់សេវាជាណរណៈ ជាពិសេសសេវារដ្ឋបាល ប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ,ទី២-គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ,ទី៣-មានសណ្តាប់ធ្នាប់សាសធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍ ,ទី៤-គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង ,ទី៥-ដោះស្រាយវិវាទនៅមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធិភាព ,ទី៦-មានអនាម័យ មានសោភ័ណភាពល្អ និងទី៧-ឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាត កាចសាហាវ ប្រកបដោយប្រសិទ្ធិភាព៕

## កម្ពុជា-វៀតណាម បង្កើនកិច្ចសហការទប់ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ

https://dap-news.com/national/2023/03/06/317084/ BySS107Posted on March 6, 2023

ភ្នំពេញ ៖ ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម បានប្តេជ្ញារួមគ្នាបង្កើនកិច្ចសហការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងតំបន់។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ ក្រសួងមហាផ្ទៃ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣នេះ។

ក្នុងជំនួបពិភាក្សាការងាររវាង សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយ ឧត្តមសេនីយ៍ឯក តូ ឡឹម សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម ភាគីទាំងពីរ បានផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកអំពីបច្ចុប្បន្នភាព និងការវិវត្តនៃសភាពការណ៍ សន្តិសុខទូទៅក្នុងតំបន់ និងសកលលោក ក្នុងនោះក៏បានកត់សម្គាល់និន្នាការកើនឡើងនៃបទល្មើសឆ្លងដែន ជាពិសេសបទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យា។

ក្នុងន័យនេះ ដើម្បីបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់កាន់តែសកម្ម និងខ្លាំងក្លាថែមទៀត ភាគីទាំងពីរ បានចុះហត្ថលេខាលើផែនការសហប្រតិបត្តិការឆ្នាំ២០២៣ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម ព្រមទាំងឯកភាពជំរុញអនុវត្តកិច្ចការសំខាន់ៗមួយចំនួន ដូចជា ៖

ទី១-បង្កើនកិច្ចសហការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងតំបន់ ព្រមទាំងការផ្លាស់ប្តូរបទពិសោធន៍ការងារ និងការអភិវឌ្ឍធនធានមនុស្ស សំដៅឆ្លើយតបបានសមស្របទៅនឹងការវិវត្តស្មុគស្មាញនៃបទល្មើស ជាពិសេសបទល្មើសមិន ប្រពៃណីដែលកំពុងមានកើនឡើងយ៉ាងឆាប់រហ័ស ទាំងក្នុងតំបន់ និងសកលលោក។

និងទី២-សហការជំរុញការបើកដំណើរការជាផ្លូវការនូវបណ្តាច្រកទ្វារព្រំដែនអន្តរជាតិ ដែលរដ្ឋាភិបាល នៃប្រទេសទាំងពីរបានឯកភាពគ្នាកន្លងមក ដើម្បីឱ្យសមស្របតាមបរិបទរីកចម្រើននៃសេដ្ឋកិច្ច សង្គម និងជំរុញដល់កំណើននៃការផ្លាស់ប្តូរពាណិជ្ជកម្ម ព្រមទាំងការផ្លាស់ប្តូររវាងប្រជាជន និង ប្រជាជន ដែលបន្តមានការកើនឡើងជាលំដាប់ ក៏ដូចជារួមចំណែកលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។

សូមរំលឹកថា តបតាមការអញ្ជើញរបស់ ឧត្តមសេនីយ៍ឯក តូ ឡឹម សមាជិកការិយាល័យនយោបាយ និង ជារដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម និងដោយទទួលបានការអនុញ្ញាតពី សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ អញ្ជើញបំពេញទស្សនកិច្ចការងារ នៅវៀតណាម ចាប់ពីថ្ងៃទី៣-០៥ ខែមីនា ឆ្នាំ២០២៣។

## ក្រុមពលករធ្វើការនៅប្រទេសថៃ ស្នើរដ្ឋាភិបាលឱ្យបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែន

https://www.rfa.org/khmer/news/social-economy/workers-and-civil-society-organizations-call-on-government-to-reduce-passport-fees-03062023120727.html ដោយ ជី រីតា2023.03.06

ពលករខ្មែរធ្វើការនៅប្រទេសថៃ ស្នើសុំរដ្ឋាភិបាលឱ្យបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែន ដើម្បីឲ្យពលរដ្ឋក្រីក្រ មានលទ្ធភាពចំណាយ ហើយអាចធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដោយស្របច្បាប់។ មន្ត្រីអង្គការសង្គមស៊ីវិល គាំទ្រចំពោះការស្នើសុំនេះ និងជំរុញឱ្យរដ្ឋាភិបាលបង្កើនចំនួនខេត្ត ធ្វើលិខិតឆ្លងដែនឱ្យបានច្រើន ដើម្បីផ្តល់ភាពងាយស្រួលដល់ពលរដ្ឋ។ ពលករខ្មែរធ្វើការនៅប្រទេសថៃ ស្នើសុំឱ្យរដ្ឋាភិបាលបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែនឱ្យបានទាប ដើម្បីជួយកាត់បន្ថយចំណាយរបស់ពួកគេ ក្នុងការបំពេញឯកសារ ធ្វើការនៅប្រទេសថៃ និងប្រទេសផ្សេងទៀត។

ពលករខ្មែរម្នាក់ ដែលកំពុងធ្វើការនៅខេត្តសមុទ្រប្រាកាន លោក គួ សារឿន ប្រាប់វិទ្យុអាស៊ីសេរីថា លោកបានធ្វើចំណាកស្រុកជាមួយប្រពន្ធលោក ទៅធ្វើការនៅប្រទេសថៃ កាលពីឆ្នាំ២០១៥ ដោយត្រូវចំណាយអស់ម្នាក់ ១ម៉ឺនបាត (១០.០០០បាត) ឬប្រហែល ៣០០ដុល្លារអាមេរិក ដើម្បីបំពេញឯកសារឱ្យបានស្របច្បាប់។ លោកបន្ថែមថា លោកបានបង់លុយឱ្យក្រុមហ៊ុនឯកជន ដើម្បីបំពេញបែបបទឯកសារឱ្យលោក ប៉ុន្តែដោយសារក្រុមហ៊ុនធ្វើឯកសារយឺតយ៉ាវ តម្រួតថៃបានចាប់ប្រពន្ធលោក និងកូនរបស់លោក ដែលមានអាយុទើបតែ ២ខែ ទៅបង្ខាំងទុកទៅប៉ុស្តិ៍ប៉ូលិសខូកខាម (Khok Kham) បាត់ ហើយនៅថ្ងៃទី៥ ខែមិនា ហើយពេលនេះលោកកំពុងយកលុយ ២ម៉ឺនបាត (២០.០០០បាត) ឬប្រហែល ៦រយដុល្លារអាមេរិក ដើម្បីយកប្រពន្ធកូនរបស់លោកវិញ។ លោក គួ សារឿន បន្ថែមថា គ្រួសាររបស់លោកមិនសូវបានផ្ញើលុយទៅស្រុកកំណើតវិញនោះទេ ព្រោះលោកត្រូវចំណាយលើថ្លៃបំពេញឯកសារស្របច្បាប់ច្រើន។ លោក គួ សារឿន «ចុះតម្លៃមកអ៊ីចឹង បងប្អូនយើងគាត់អាចធ្វើច្រើន (ឯកសារស្របច្បាប់) ពេលនេះ បងប្អូនគាត់ដាច់ឯកសារ ដល់ពេលជួលគេទៅធ្វើអស់ថ្លៃ។ ជួនកាលធ្វើការមួយថ្ងៃបាន ៣០០រយ ឬ១០ដុល្លារ អី ហើយគាត់ធ្វើអ៊ីចឹងទៅ បងប្អូនខ្លះគាត់ខ្វល់គាត់ខ្វាយ ពួកតម្រួតថៃចង់ចុះចាប់ ចង់អីអ៊ីចឹង ពិបាកចិត្តដែររាល់ថ្ងៃហ្នឹង»។

ស្រដៀងគ្នានេះ ពលករខ្មែរម្នាក់ទៀត ដែលកំពុងធ្វើការនៅទីក្រុងបាងកក (Bangkok) លោក ហាក់ ស្លូ ប្រាប់វិទ្យុអាស៊ីសេរីថា លោកបានមកធ្វើការនៅប្រទេសថៃជាមួយប្រពន្ធជិត២ឆ្នាំមកហើយ ប៉ុន្តែគ្រួសាររបស់លោកនៅតែមិនអាចមានលទ្ធភាពឱ្យកូនចូលរៀនបាននោះឡើយ។ លោកបន្ថែមថា បច្ចុប្បន្នលោកកំពុងទាក់ទងឱ្យក្រុមហ៊ុនឯកជនរត់ឯកសារ ដើម្បីបានធ្វើការស្របច្បាប់នៅប្រទេសថៃបន្ត ដោយលោកត្រូវចំណាយក្នុងម្នាក់ ៧ពាន់បាត (៧.០០០បាត) ឬប្រហែលជាង ២រយដុល្លារអាមេរិក (២០០ដុល្លារ)។ លោក ហាក់ ស្លូ ស្នើសុំរដ្ឋាភិបាលឱ្យបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែនឱ្យបានទាប ដើម្បីជួយកាត់បន្ថយការចំណាយគ្រួសាររបស់លោក និងពលរដ្ឋខ្មែរដទៃទៀត។ លោក ហាក់ ស្លូ៖ «បានតែមួយហូប មួយចិញ្ចឹមកូន ព្រោះកូនច្រើនពេក ៣នាក់ ហើយនៅតូចៗ។ សំណូមពរដល់រដ្ឋាភិបាលខ្មែរយើង ឱ្យចុះតម្លៃធ្វើប៉ាស្ព័រជាងហ្នឹងទៀត ព្រោះខ្ញុំរកលុយអត់សូវបានអ៊ីចឹងទៅ មានលុយឱ្យកូនបានចូលរៀន»។ ប្រៀបធៀបជាមួយធ្វើលិខិតឆ្លងដែនជាមួយប្រទេសជិតខាងវិញ ការធ្វើលិខិតឆ្លងដែនកម្ពុជា

មានតម្លៃថ្លៃជាងគេ។ ដើម្បីធ្វើលិខិតឆ្លងដែនប្រើប្រាស់ ប្រជាពលរដ្ឋខ្មែរត្រូវចំណាយចាប់ពីជាង ១រយដុល្លារ (១១០ដុល្លារ) ទៅដល់ជាង ២រយដុល្លារអាមេរិក (២៣០ដុល្លារ) ខណៈការធ្វើលិខិតឆ្លងដែន ប្រទេសថៃ (Thailand) និងប្រទេសឡាវ (Lao) ប្រជាពលរដ្ឋនៃប្រទេសទាំង ២នេះ ត្រូវចំណាយត្រឹម ៥០ដុល្លារតែប៉ុណ្ណោះ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអគ្គស្នងការរង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោក កែវ វណ្ណថន ដើម្បីបកស្រាយជុំវិញការស្នើសុំនេះបានទេ នៅថ្ងៃទី៥ ខែមិនា ដោយទូរស័ព្ទចូល តែលោកថា កំពុងជាប់រវល់។ ទោះជាយ៉ាងណាក្ដី នៅក្នុងពិធីចែកសញ្ញាប័ត្រដល់និស្សិតសកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅខេត្តបាត់ដំបង កាលពីថ្ងៃទី១ ខែមីនា កន្លងទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានថ្លែងថា រដ្ឋាភិបាលកំពុងពិចារណាបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែន ក៏ប៉ុន្តែលោកមិនបានបញ្ជាក់ពីពេលវេលាច្បាស់លាស់នៅឡើយទេ។

លោក កែវ វណ្ណថន៖ «ឥឡូវមានតែប៉ាស្ព័រទេ ដែលមានតម្លៃ ហើយមានអ្នកខ្លះគាត់ស្រែកថា ប៉ាស្ព័រហ្នឹងថ្លៃពេក (សំឡេងសើច) ថ្លៃពេកដែរ រដ្ឋាភិបាលនឹងពិចារណាទៀត តើតម្លៃប៉ុណ្ណា ដែលស្រប ព្រោះរដ្ឋាភិបាលយើងនេះកើតចេញពីការបោះឆ្នោត»។

ជុំវិញរឿងនេះ នាយកប្រតិបត្តិអង្គការសង់ត្រាល់ (CENTRAL) លោក មឿន តុលា គាំទ្រ ចំពោះការស្នើសុំឱ្យរដ្ឋាភិបាលបញ្ចុះតម្លៃក្នុងការធ្វើលិខិតឆ្លងដែនឱ្យបានទាប ។ លោកបន្ថែមថា ការបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែនមិនត្រឹមតែជួយកាត់បន្ថយចំណាយពលករខ្មែរ ដែលធ្វើការចំណាកស្រុកប៉ុណ្ណោះទេ តែក៏ជាកត្តាជំរុញពលករខ្មែរឱ្យធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ទៀតផង។ លើសពីនេះ លោកថា រដ្ឋាភិបាលគួរអនុញ្ញាតឱ្យខេត្តនីមួយៗអាចធ្វើលិខិតឆ្លងដែនដល់ប្រជាពលរដ្ឋផ្ទាល់ខ្លួនដើម្បីផ្ដល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋផងដែរ។ លោក មឿន តុលា៖ «នីតិវិធីនៃការធ្វើប៉ាស្ព័រហ្នឹង យើងធ្វើម៉េចកុំឱ្យវាចំណាយ ឬកុំឱ្យវាមានភាពស្មុគស្មាញទៅដល់ប្រជាពលរដ្ឋពេក ហើយឥឡូវនេះយើងមាននៅភ្នំពេញ និងបាត់ដំបង ប៉ុន្តែ បើសិនជាអាចធ្វើប្រតិភូកម្ម ទៅឱ្យបណ្ដាខេត្តអីផ្សេងៗ ទៀត ក៏ល្អដែរ ដើម្បីឱ្យប្រជាពលរដ្ឋយើងនៅតាមខេត្តមួយចំនួនហ្នឹង គាត់មិនចាំបាច់ឡើងមកភ្នំពេញ មិនចាំបាច់ឡើងទៅបាត់ដំបងអី លោកអាចធ្វើបាននៅខេត្ត ដែលខ្លួនរស់នៅហ្នឹងឯងបាទ»។

ប្រជាពលរដ្ឋខ្មែរបានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសរាប់លាននាក់ ក្នុងនោះភាគច្រើននៅប្រទេសថៃ។ ជាមួយគ្នានេះ ពលករខ្មែរធ្វើការនៅប្រទេសថៃ នៅតែប្រឈមជីវភាពលំបាក ដោយសារការចំណាយច្រើនទៅលើការធ្វើលិខិតឆ្លងដែន និងការបំពេញឯកសារផ្សេងៗ។ ស្របពេលប្រជាពលរដ្ឋកម្ពុជារកចំណូលបានទាបជាងគេ ប្រៀបធៀបជាមួយប្រទេសជិតខាង អង្គការសង្គមស៊ីវិល លើកឡើងថា រដ្ឋាភិបាលកម្ពុជាគួរតែបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែនឱ្យបានទាបជាង ឬយ៉ាងហោចណាស់ស្មើប្រទេសជិតខាង ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋខ្លួនឯង៕

# ថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០២៣

## ចាប់ខ្លួនមេខ្យល់

## ប្រើល្បិចឆបោកលុយជិត១ពាន់ដុល្លារពីពលរដ្ឋជាង១០០នាក់ផ្អើលផ្ទះសំណាក់

https://kohsantepheapdaily.com.kh/article/1698297.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ ០៨ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ០៩:១២

រាជធានីភ្នំពេញ ៖ ប្រជាពលរដ្ឋចំនួន១១២នាក់បានចាញ់បោ.កមេខ្យល់ ដោយនិយាយថា នាំទៅធ្វើការនៅប្រទេសកូរ៉េ ហើយក្នុងម្នាក់ៗត្រូវចំណាយលុយជិត១០០០ដុល្លារនោះ ពេលនេះត្រូវបានប្រជាពលរដ្ឋនាំគ្នាតវ៉ា និងឃាត់ខ្លួនមេខ្យល់បានម្នាក់យកទៅសួរនាំ បង្កអោយមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៨និង៣០នាទីយប់ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ នៅចំណុចផ្ទះសំណាក់ «នាគទេព» ដែលស្ថិតនៅភូមិត្រពាំងល្វា១ ក្នុងសង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ។ ជនឆបោកដែលត្រូវសមត្ថកិច្ចឃាត់បានម្នាក់ខាងលើនេះ មានឈ្មោះ តាំ ចាន់ទិ ភេទប្រុស អាយុ២៧ឆ្នាំ មុខរបរមិនពិតប្រាកដ រស់នៅភូមិត្រពាំងតឹង ឃុំព្រាល ស្រុកកញ្ជៀក ខេត្តស្វាយរៀង ។

តាមប្រភពព័ត៌មានពីជនរងគ្រោះទាំង១១២នាក់ ក្នុងនោះមានស្រី មានប្រុស អ្នកខ្លះអាយុ៥០ឆ្នាំក៏មានដែរ បានចាញ់បោ.កមេខ្យល់ ដោយនិយាយប្រាប់ថា នាំទៅធ្វើការនៅប្រទេសកូរ៉េ នឹងបានប្រាក់ខែចំនួន១៥០០ដុល្លារក្នុងមួយខែ ទៅរយៈពេល៦ខែ បើថៅកែពេញចិត្តនឹងសុំបន្តទៀតបាន ដោយប្រាប់ពួកគាត់ថា ទៅបេះផ្លែឈើ។ ជនរងគ្រោះដែលចាញ់បោ.កមេខ្យល់ខាងលើនេះ បានអោយដឹងទៀតថា បន្ទាប់ពីមេខ្យល់ដែលបំផុសបំផុលព័ត៌មានដល់ពួកគាត់ តាមរោងចក្រ និងនៅតាមភូមិ ហើយមានខេត្តជាច្រើននៅក្នុងនោះផងដែរ ប៉ុន្តែជនរងគ្រោះនៅស្រុកស្អាង ខេត្តកណ្ដាល មានច្រើនជាងគេ គឺមានជាង៥០ភាគរយឯណោះ។ ពលរដ្ឋរងគ្រោះបន្តថា ប្រជាពលរដ្ឋបានប្រគល់លុយសុទ្ធម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅ អ្នកខ្លះអស់ជិត១០០០ដុល្លារ ដោយទិញសម្លៀកបំពាក់ និងរបស់របរ ដើម្បីយកទៅរស់នៅប្រទេសកូរ៉េ។ ក្នុងនោះជនឆបោ.កខាងលើ បាននិយាយទៅកាន់ជនរងគ្រោះទាំង១១២នាក់ ថា ពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េតាមរយៈសមាគម តែមិនបានបញ្ជាក់ឈ្មោះសមាគមនោះឡើយ។ ហើយមានវគ្គផ្សេងៗគ្នា និងមានការប្រឡង ឬរៀនវគ្គភាសាកូរ៉េបន្ថែមទៀត។

ជនរងគ្រោះបន្តទៀតថា ក្នុងនោះវគ្គដំបូងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ ដែលមានគ្នា៩៤នាក់ តែមិនបានធ្វើដំណើរទេ ដោយសារមេខ្យល់បានប្រាប់ថា យន្តហោះផ្អាកជើងហោះហើររង់ចាំថ្ងៃទី៧ បន្ទាប់មកមេខ្យល់ក៏នាំបងប្អូនប្រជាពលរដ្ឋទៅសំរាកនៅផ្ទះសំណាក់ «នាគទេព» ដើម្បីរង់ចាំយប់ថ្ងៃទី៧ ទើបយន្តហោះដឹកពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េ ។ ប្រភពពីជនរងគ្រោះដែលជាពលកររៀបចំទៅធ្វើការនៅប្រទេសកូរ៉េ បានបញ្ជាក់ថា មិនត្រឹមតែចាញ់បោ.កមេខ្យល់អស់លុយក្នុងម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅទេ គឺថែមទាំងចាញ់បោ.កមេខ្យល់ ដោយយកលុយខ្មែរទៅប្តូរយកលុយកូរ៉េ ដើម្បីយកទៅចាយនៅប្រទេសកូរ៉េអស់មួយចំនួនទៀត។ លុះនៅវេលាម៉ោងកើតហេតុ ដោយមានការសង្ស័យ ខ្លាចមិនបានទៅធ្វើការនៅប្រទេសកូរ៉េ ទើបនាំគ្នាប្តឹងសមត្ថកិច្ច និងអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ដើម្បីជួយអន្តរាគមន៍ ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បានម្នាក់ ក្នុងចំណោមបក្សពួកចំនួន៣នាក់ ដើម្បីយកទៅសួរនាំភ្លាមៗតែម្តង។

ចំណែកខាងរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ចុះធ្វើប្រវត្តិរូបប្រជាពលរដ្ឋដែលចាញ់បោ.កមេខ្យល់ ហើយបានអោយបងប្អូនប្រជាពលរដ្ឋសម្រាកនៅផ្ទះសំណាក់ខាងលើមួយយប់ទៀត ដើម្បីរកដំណោះស្រាយបន្ត។ បើតាមសមត្ថកិច្ចនគរបាលជំនាញខណ្ឌពោធិ៍សែនជ័យ បន្ទាប់ពីឃាត់ជនសង្ស័យបានម្នាក់យកទៅសួរនាំនោះ បានបញ្ជាក់ប្រាប់ថា រូបគេមានមេធំ២នាក់ទៀត ហើយរូបគាត់ជាអ្នកទទួលលុយពីបងប្រជាពលរដ្ឋពិតប្រាកដមែន។

ទោះបីជាយ៉ាងណា ជនសង្ស័យជាមេខ្យល់ខាងលើនេះ មិនបានបញ្ជាក់លំអិតនោះទេ ហើយពេលនេះសមត្ថកិច្ចកំពុងតែស្វះស្វែងទៀតហើយ៕

## សមាជិកព្រឹទ្ធសភាហ្វីលីពីននិយាយថា មានការខ្វែងមតិគ្នាជុំវិញការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរមនុស្ស

https://www.khmertimeskh.com/501250606/-4/ Khmer Times March 7, 2023

ព្រឹទ្ធសមាជិកលោកស្រី Risa Hontiveros បាននិយាយថា ប្រតិបត្តិការក្លែងបន្លំគ្រីបតូ គឺជាគ្រោងការណ៍ជួញដូរមនុស្សថ្មីនៅក្នុងតំបន់អាស៊ាន ប៉ុន្តែវាហាក់នៅតែមានការខ្វែងមតិគ្នាជុំវិញរបៀបកំណត់អត្តសញ្ញាណជនរងគ្រោះទាំងនេះ ដោយអ្នកខ្លះគិតថាពួកគេជាកម្មករខុសច្បាប់ ឬជនអន្តោប្រវេសន៍គ្មានឯកសារត្រឹមត្រូវ។ លោកស្រីបានថ្លែងបែបនេះ បន្ទាប់ពីបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍របស់ជនជាតិហ្វីលីពីនចំនួន៨នាក់ ដែលត្រូវបានជួញដូរមកកម្ពុជា ដើម្បីធ្វើការជាអ្នកបោកប្រាស់រូបិយប័ណ្ណគ្រីបតូ បន្ទាប់ពីពួកគេត្រូវបានជួយសង្គ្រោះពីថៅកែជនជាតិចិនដោយនគរបាលក្នុងស្រុកនៅទីនោះ។ លោកស្រី បានថ្លែងអំណរគុណដល់មន្ត្រីមកពីក្រសួងការបរទេសនគរបាលកម្ពុជា និងអង្គការសង្គមស៊ីវិល និងបុគ្គលពាក់ព័ន្ធដែលបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ជនហ្វីលីពីនទាំង៨នាក់។ លោកស្រីបានបន្ថែមថា "ជាច្រើនសប្តាហ៍បានកន្លងផុតទៅ មានការពិភាក្សាជាច្រើន ដោយសារតែត្រូវអនុវត្តតាមដំណើរការនីតិវិធីរបស់រដ្ឋាភិបាលកម្ពុជា មុនពេលដែលជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅប្រទេសហ្វីលីពីនវិញ" ។

លោកស្រីបានគូសបញ្ជាក់ថា ជនរងគ្រោះដោយសារការជួញដូរមនុស្ស គឺជាជនរងគ្រោះដែលធ្លាក់ខ្លួនចាញ់បោកអ្នកជួញដូរ ដោយសារតែពួកគេចង់មានជីវភាពអោយកាន់តែប្រសើរឡើង។ យ៉ាងណាក៏ដោយ លោកស្រីបានអំពាវនាវដល់ប្រជាជនហ្វីលីពីនកុំឲ្យស្វែងរកការងារជាភ្នាក់ងារបម្រើអតិថិជននៅក្នុងប្រទេសកម្ពុជា ឬមីយ៉ាន់ម៉ាពីព្រោះទាំងនេះអាចជាប្រតិបត្តិការបោកប្រាស់គ្រីបតូ។ កាលពីចុងឆ្នាំមុន លោកស្រីសមាជិកព្រឹទ្ធសភាបានលើកឡើងពីគម្រោងការជួញដូរមនុស្សនៅក្នុងសម័យប្រជុំព្រឹទ្ធសភា បន្ទាប់ពីជនរងគ្រោះនៃការជួញដូរជនជាតិហ្វីលីពីនចំនួន១២ នាក់ត្រូវបានក្រសួងការបរទេសធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកផ្ទះវិញ។ ក្រៅពីត្រូវបានគេបង្ខំអោយបោកប្រាស់បុគ្គលផ្សេងទៀត ជនរងគ្រោះជនជាតិហ្វីលីពីននៅក្រៅប្រទេសទាំងនេះត្រូវបានគេរំលោភបំពាននៅពេលដែលពួកគេមិនអាចបំពេញតាមកិច្ចការដែលបានដាក់អោយ។ *Philstar.com*

## ជនអន្តោប្រវេសន៍៣៤៣នាក់ ត្រូវបានរកឃើញក្នុងរថយន្តកុងតឺន័រមួយគ្រឿង នៅប្រទេសម៉ិកស៊ិក

https://kohsantepheapdaily.com.kh/article/1698169.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៧ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ២៣:០៩

មន្ត្រីប្រទេសម៉ិកស៊ិក បានរកឃើញជនចំណាកស្រុកចំនួន ៣៤៣នាក់ (អនីតិជនចំនួន ១០៣ នាក់) នៅក្នុងកុងតឺន័រដឹកទំនិញដែលគេទុកចោល នៅក្នុងរដ្ឋ Veracruz ។នេះបើយោងតាមការចុះផ្សាយរបស់ទូរទស្សន៍ BBC នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣។ រថយន្តនេះត្រូវបានគេបោះបង់ចោលនៅលើផ្លូវដែលជាធម្មតាដឹកជនចំណាកស្រុកទៅព្រំដែនសហរដ្ឋអាមេរិក។ មន្ត្រីម៉ិកស៊ិកបន្ថែមថា ជនចំណាកស្រុកដែលរកឃើញនេះមិនមានបញ្ហាសុខភាពទេ ហើយរថយន្តដឹកជញ្ជូនមនុស្សក៏មានកង្ហារ និងទ្វារខ្យល់ចេញចូលផងដែរ ប៉ុន្តែគេមិនដឹងថាហេតុអ្វី

បានជាអ្នកបើកបរគេចខ្លួន ផ្លូងរថយន្តចោលបែបនេះ។ ជនចំណាកស្រុកទាំងនេះ នឹងត្រូវបានយកចិត្តទុកដាក់ដោយអាជ្ញាធរសេវាសង្គមម៉ិកស៊ិក រហូតដល់ការសម្រេចចិត្តថ្មីមួយត្រូវបានធ្វើឡើង។

យោងតាមវិទ្យាស្ថានជាតិចំណាកស្រុករបស់ប្រទេសម៉ិកស៊ិក ប្រជាជនមួយក្រុមនេះមកពីប្រទេសក្វាតេម៉ាឡា ហុងឌូរ៉ាស អែលសាល់វ៉ាឌ័រ និងអេក្វាឌ័រ។ ដោយអស់សង្ឃឹមក្នុងការគេចចេញពីភាពក្រីក្រ និងអំពើហិង្សានៅអាមេរិកកណ្តាល ជនចំណាកស្រុកជាច្រើនបានចំណាយប្រាក់យ៉ាងច្រើនដល់ក្រុមអ្នកជួញដូរមនុស្សដើម្បីឆ្លងកាត់ព្រំដែនសហរដ្ឋអាមេរិកដោយខុសច្បាប់៕

## អាជ្ញាធររកឃើញអ្នកចាញ់បោកមេខ្យល់ កើនដល់ ១២៥នាក់ និងបានប្រគល់លិខិតឆ្លងដែន ជូនបាយទឹក ព្រមថវិកា រួចដឹកពួកគាត់តាមរថយន្តក្រុង ត្រលប់ទៅផ្ទះវិញ

https://kohsantepheapdaily.com.kh/article/1698581.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ ០៨ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ២០:៣៩

ភ្នំពេញ៖ អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ បាននិយាយថា ចំនួនប្រជាពលរដ្ឋ ដែលលង់ខ្លួន ចាញ់បោកមេខ្យល់ ដែលថា នាំទៅធ្វើការ នៅប្រទេសកូរ៉េនោះ ពុំមែនមានតែត្រឹម ១១២នាក់ប៉ុណ្ណោះទេ។ ក្រោយពីការចុះទៅត្រួតពិនិត្យផ្ទះសំណាក់ និងស្រង់ឈ្មោះដាក់ស្តែង អាជ្ញាធរបានរកឃើញចំនួន ១៣នាក់បន្ថែមទៀត។ ដូច្នេះកើនដល់ ១២៥នាក់ឯណោះ។ ពួកគាត់បានខាតបង់ប្រាក់ចន្លោះពី ៨០០ដុល្លារ ទៅ ១,០០០ដុល្លារ។ ប្រភពដដែលបានប្រាប់ថា ដោយអនុវត្តតាមការដឹកនាំ និងបញ្ជាដោយលោក ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ លោក សុខ ពេញវុធ អភិបាលរងរាជធានី ភ្នំពេញ រួមជាមួយលោកឧត្តមសេនីយទោ សុង លី ស្នងការរងនគរបាលរាជធានីភ្នំពេញ និងលោក សក់ ចន្ទ័កញ្ញារិទ្ធ អភិបាលខណ្ឌពោធិ៍សែនជ័យ បានបន្តចុះត្រួតពិនិត្យផ្ទះសំណាក់ «នាគទេព» ស្ថិតក្នុងភូមិត្រពាំងល្វា១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីវេលាព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣។

ប្រភពខាងលើ បាននិយាយថា កម្លាំងអាជ្ញាធរបានពិនិត្យ និងរកឃើញ ហើយស្រង់ស្ថិតិដាក់ស្តែង មានប្រជាពលរដ្ឋ ដែលបានចាញ់បោកមេខ្យល់ នាំទៅធ្វើការនៅប្រទេសកូរ៉េនោះ រហូតចំនួន ១២៥នាក់ ក្នុងនោះ ប្រុសចំនួន ៨៧នាក់ និងស្រីចំនួន ៣៨នាក់។ កម្លាំងបានធ្វើការឃាត់ខ្លួនជនសង្ស័យ ជាមេខ្យល់ចំនួន ៤នាក់ ក្នុងនោះមានស្ត្រីម្នាក់ រួចបញ្ជូនទៅកាន់ស្នងការនគរបាលរាជធានីភ្នំពេញ ដើម្បីសាកសួរបន្ត និងកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមច្បាប់។ ប្រភពមួយនេះ បានបញ្ជាក់បន្ថែមទៀតថា នៅក្នុងដំណោះស្រាយ នាពេលនោះ អាជ្ញាធរបានប្រគល់និខិតឆ្លងដែន ដែលដកហូតពីមេខ្យល់ ជូនពួកគាត់វិញ ហើយបានឧបត្ថម្ភថវិកាជាសោហ៊ុយ ក្នុងម្នាក់ៗ ចំនួន ២ម៉ឺនរៀល ព្រមទាំងជូនបាយទឹក សម្រាប់បរិភោគ និងបានរៀបចំរថយន្តក្រុងសាធារណៈរបស់រាជធានីភ្នំពេញ ចំនួន ៣គ្រឿង ដឹកពួកគាត់ ត្រលប់ទៅកាន់ស្រុកកំណើតវិញរួចរាល់ហើយ៕ យន់ ស៊ីថា

# នគរបាលចាប់មេខ្យល់៤នាក់ ក្រោយបោកប្រជាពលរដ្ឋខាង១០០នាក់ រឿងនាំទៅធ្វើការនៅប្រទេសកូរ៉េ នៅខណ្ឌពោធិ៍សែនជ័យ

https://freshnewsasia.com/index.php/en/localnews/281365-2023-03-08-08-34-04.html 2023-03-08 03:34pm

**(ភ្នំពេញ)៖** នគរបាលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សហការនគរបាលខណ្ឌពោធិ៍សែនជ័យ បានចាប់ខ្លួនមេខ្យល់ធបោកម្នាក់ រួចបន្តស្រាវជ្រាវចាប់បក្ខពួកបន្ថែមចំនួន៣នាក់ទៀត ក្រោយធបោកប្រជាពលរដ្ឋចំនួន១១២នាក់ រឿងនាំទៅធ្វើការនៅប្រទេសកូរ៉េ ដោយម្នាក់ៗចាញ់បោកអស់លុយជិត១ពាន់ដុល្លារ។ សមត្ថកិច្ចបានឲ្យដឹងថា ការចាប់ខ្លួនមេខ្យល់ខាងលើបានធ្វើឡើងកាលពីរាត្រីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ ក្រោយប្រជាពលរដ្ឋនាំគ្នាតវ៉ា នៅចំណុចផ្ទះសំណាក់ «នាគទេព» នៅភូមិត្រពាំងល្វា១ ក្នុងសង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ។ ជនធបោកខាងលើនេះមានឈ្មោះ តាំ ចាន់ទិ អាយុ២៧ឆ្នាំ មុខរបរមិនពិតប្រាកដ រស់នៅភូមិត្រពាំងតឹង ឃុំព្រាល ស្រុកកញ្ជៀច ខេត្តព្រៃវែង។

ក្រោយឃាត់ខ្លួនជនសង្ស័យខាងលើ, នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣នេះ សមត្ថកិច្ចបានបន្តការស្រាវជ្រាវឃាត់ខ្លួនបក្ខចំនួន៣នាក់បន្ថែមទៀត។ ក្រោយចាប់ខ្លួន ជនសង្ស័យទាំង៤នាក់ ត្រូវបានបញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលរជធានីភ្នំពេញ សាកសួរបន្តតាមនិតិវិធី។

សូមបញ្ជាក់ថា នៅយប់ថ្ងៃទី៧ ខែមិនា ឆ្នាំ២០២៣ មានជនរងគ្រោះទាំង១១២នាក់ ក្នុងនោះមានស្រីមានប្រុស អ្នកខ្លះអាយុ៥០ឆ្នាំ ដែលបានចាញ់បោកមេខ្យល់ខាងលើ សន្យាថានាំទៅធ្វើការនៅប្រទេសកូរ៉េ ទទួលបានប្រាក់ខែ ចំនួន១៥០០ដុល្លារ ក្នុង១ខែ ទៅរយៈពេល៦ខែ ការងារនៅចំការបេះផ្លែឈើត្រូវបានសមត្ថកិច្ចជួយសង្គ្រោះទាន់ពេលវេលាដោយធ្វើការឃាត់ខ្លួនមេខ្យល់ម្នាក់ផងដែរ។ ក្រុមជនរងគ្រោះ បានឱ្យដឹងទៀតថា បន្ទាប់ពីមេខ្យល់ដែលបំផុសបំផុលព័ត៌មានដល់ពួកគាត់ តាមរោងចក្រ និងនៅតាមភូមិ ហើយមានខេត្តជាច្រើននៅ ក្នុងនោះផងដែរ ប៉ុន្តែជនរងគ្រោះនៅស្រុកស្អាង ខេត្តកណ្តាល មានច្រើនជាងគេ គឺមានជាង៥០ភាគរយឯណោះ។

ពលរដ្ឋរងគ្រោះបន្តថា ប្រជាពលរដ្ឋបានប្រគល់លុយសុទ្ធម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅ អ្នកខ្លះអស់ជិត១០០០ដុល្លារ ដោយទិញសម្លៀកបំពាក់ និងរបស់របរ ដើម្បីយកទៅរស់នៅប្រទេសកូរ៉េ។ ក្នុងនោះជនធបោកខាងលើ បាននិយាយទៅកាន់ជនរងគ្រោះទាំង១១២នាក់ថា ពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េ តាមរយៈសមាគម តែមិនបានបញ្ជាក់ឈ្មោះសមាគមនោះឡើយ។ ហើយមានវគ្គផ្សេងៗគ្នា និងមានការប្រឡង ឬរៀនវគ្គភាសាកូរ៉េបន្ថែមទៀត។ ជនរងគ្រោះបន្តទៀតថា ក្នុងនោះវគ្គដំបូងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ ដែលមានគ្នា៩៤នាក់ តែមិនបានធ្វើដំណើរទេ ដោយសារមេខ្យល់បានប្រាប់ថា យន្តហោះផ្អាកជើងហោះហើររង់ចាំថ្ងៃទី៧ ខែមីនា។ បន្ទាប់មកមេខ្យល់ក៏នាំ បងបងប្អូនប្រជាពលរដ្ឋទៅសំរាកនៅផ្ទះសំណាក់ «នាគទេព» ដើម្បីរង់ចាំយប់ថ្ងៃទី៧ ខែមីនា ទើបយន្តហោះដឹកពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េ។

ជនរងគ្រោះ បានបញ្ជាក់ថា មិនត្រឹមតែចាញ់បោកមេខ្យល់អស់លុយក្នុងម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅទេ គឺថែមទាំងចាញ់បោកមេខ្យល់ ដោយយកលុយខ្មែរទៅប្តូរយកលុយកូរ៉េ ដើម្បីយកទៅចាយនៅប្រទេសកូរ៉េ អស់មួយចំនួនទៀត។ លុះនៅវេលាម៉ោងកើតហេតុ ដោយមានការសង្ស័យ ខ្លាចមិនបានទៅធ្វើការនៅប្រទេសកូរ៉េ ទើបនាំគ្នាប្តឹងសមត្ថកិច្ច និងអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ដើម្បីជួយអន្តរាគមន៍ ឃាត់ខ្លួនជនសង្ស័យ ជាមេខ្យល់បានម្នាក់ ក្នុងចំណោមបក្សពួកចំនួន៣នាក់ ដើម្បីយកទៅសួរនាំភ្លាមៗតែម្តង។ សមត្ថកិច្ចនគរបាលជំនាញខណ្ឌពោធិ៍សែនជ័យ បន្ទាប់ពីឃាត់ជនសង្ស័យបានម្នាក់យកទៅសួរនាំនោះ បានបញ្ជាក់ប្រាប់ថា រូបគេមានមេធំ២នាក់ទៀត

ហើយរូបគាត់ជាអ្នកទទួលលុយពីបងប្រជាពលរដ្ឋពិតប្រាកដមែន។ ទោះបីជាយ៉ាងណា ជនសង្ស័យជាមេខ្យល់នេះ មិនបានបញ្ជាក់លំអិតនោះទេ ហើយពេលនេះសមត្ថកិច្ចកំពុងតែសួរនាំបន្តទៀត៕

## អភិបាលរាជធានីភ្នំពេញ យករថយន្តក្រុង៣គ្រឿង ដឹកពលរដ្ឋជាង១០០នាក់ ដែលចាញ់បោកមេខ្យល់នាំទៅកូរ៉េ ត្រឡប់ទៅលំនៅដ្ឋានវិញ

https://freshnewsasia.com/index.php/en/localnews/281407-2023-03-08-11-50-20.html 2023-03-08 06:50pm

**(ភ្នំពេញ)៖** ក្រោយប្រជាពលរដ្ឋជាង១០០នាក់ ដែលបានចាញ់បោកមេខ្យល់នាំទៅធ្វើការ នៅឯបរទេសកូរ៉េនោះ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣ លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានដឹកនាំក្រុមការងាររួមមាន លោក សុខ ពេញវុធ អភិបាលរងរាជធានី ភ្នំពេញ លោកឧត្តមសេនីយទោ សុង លី ស្នងការរងរាជធានីភ្នំពេញ លោក សក់ ចន្ទ័កញ្ញារិទ្ធ អភិបាលខណ្ឌ ពោធិ៍សែនជយ៍ »បានបន្តចុះត្រួតពិនិត្យផ្ទះសំណាក់ «នាគទេព» ស្ថិតក្នុងភូមិត្រពាំងល្វា១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជយ៍ បានយករថយន្តក្រុងសាលារាជធានីភ្នំពេញ៣គ្រឿងដឹកជញ្ជូនពលរដ្ឋចំនួន១២៥នាក់ ប្រុសចំនួន ៨៧ប្រុស ស្រីចំនួន៣៨នាក់ត្រឡប់ទៅកាន់លំនៅដ្ឋាននៅស្រុកកំណើតតាមបណ្ដាខេត្តវិញរួមផ្តល់អាហារនិងថវិការមួយចំនួនផងដែរ។

សូមបញ្ជាក់ថា នគរបាលស្នងការនគរបាលរាជធានីភ្នំពេញ សហការនគរបាលនៃអធិការដ្ឋានខណ្ឌពោធិ៍សែនជ័យ បានធ្វើការចាប់ខ្លួនមេខ្យល់ឆបោកម្នាក់ រួចបន្តស្រាវជ្រាវឃាត់ខ្លួនបក្ខពួក បន្ថែមចំនួន៣នាក់ទៀតដែលបានឆបោកថាប្រជាពលរដ្ឋចំនួន១១២នាក់នាំទៅធ្វើការនៅប្រទេសកូរ៉េ ហើយក្នុងម្នាក់ៗចាញ់បោងអស់លុយជិត១ពាន់ដុល្លារ។ សមត្ថកិច្ច បានឲ្យដឹងថា ការចាប់ខ្លួនមេខ្យល់ខាងលើ បានធ្វើឡើងកាលពីរាត្រី ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០២៣ក្រោយប្រជាពលរដ្ឋនាំគ្នាតវ៉ា នៅចំណុចផ្ទះសំណាក់ «នាគទេព» ដែលស្ថិតនៅភូមិត្រពាំងល្វា១ ក្នុងសង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ។ ជនឆោកខាងលើនេះមានឈ្មោះ តាំ ចាន់ទិ ភេទ ប្រុសអាយុ២៧ឆ្នាំ មុខរបរមិនពិតប្រាកដ រស់នៅភូមិត្រពាំងតឹង ឃុំព្រាល ស្រុកកញ្ជៀច ខេត្តព្រៃវែង ។

ក្រោយឃាត់ខ្លួនជនសង្ស័យនៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣នេះ សមត្ថកិច្ចបានបន្តការស្រាជ្រាវឃាត់ខ្លួនបក្ខចំនួន៣នាក់បន្ថែមទៀត កម្លាំងជំនាញបានបញ្ជូនជនសង្ស័យទាំង៤នាក់ ខាងលើទៅការិយាល័យប្រឆាំងការជួញដូរផ្លូវភេទ នៃស្នងការដ្ឋាននគរបាលរជធានីភ្នំពេញសាកសួរបន្តតាមនិតិវិធី។ នៅយប់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ មានជនរងគ្រោះទាំង១១២នាក់ ក្នុងនោះមានស្រី មានប្រុស អ្នកខ្លះអាយុ៥០ឆ្នាំ ដែលបានចាញ់បោកមេខ្យល់ខាងលើ សន្យាថា នាំទៅធ្វើការនៅប្រទេសកូរ៉េ ទទួលបានប្រាក់ខែចំនួន១៥០០ដុល្លារក្នុង១ខែ ទៅរយៈពេល៦ខែ ការងារនៅចំការបេះផ្លែឈើត្រូវបានសមត្ថកិច្ចជួយសង្គ្រោះទាន់ពេលវេលា ដោយធ្វើការឃាត់ខ្លួនមេខ្យល់ម្នាក់ផងដែរ។ ក្រុមជនរងគ្រោះ បានឲ្យដឹងទៀតថា បន្ទាប់ពីមេខ្យល់ដែលបំផុសបំផុលព័ត៌មានដល់ពួកគាត់ តាមរោងចក្រ និងនៅតាមភូមិ ហើយមានខេត្តជាច្រើននៅ ក្នុងនោះផងដែរ ប៉ុន្តែជនរងគ្រោះនៅស្រុកស្អាង ខេត្តកណ្ដាល មានច្រើនជាងគេ គឺមានជាង៥០ភាគរយឯណោះ។

ពលរដ្ឋរងគ្រោះបន្តថា ប្រជាពលរដ្ឋបានប្រគល់លុយសុទ្ធម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅ អ្នកខ្លះអស់ជិត ១០០០ដុល្លារ ដោយទិញសម្លៀកបំពាក់ និងរបស់របរ ដើម្បីយកទៅរស់នៅប្រទេសកូរ៉េ។ ក្នុងនោះជនឆបោកខាងលើ បាននិយាយទៅកាន់ជនរងគ្រោះទាំង១១២នាក់ថា ពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េតាមរយៈសមាគម តែមិនបានបញ្ជាក់ឈ្មោះសមាគមនោះឡើយ។ ហើយមានវគ្គផ្សេងៗគ្នា និងមានការប្រឡងឬរៀនវគ្គភាសាកូរ៉េបន្ថែមទៀត។ ជនបរងគ្រោះបន្តទៀតថា ក្នុងនោះវគ្គដំបូងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ ដែលមានគ្នា៩៤នាក់ តែមិនបានធ្វើដំណើរទេ ដោយសារមេខ្យល់បានប្រាប់ថា យន្តហោះផ្អាកជើងហោះហើររង់ចាំថ្ងៃទី៧មីនា។ បន្ទាប់មកមេខ្យល់ក៏នាំ

បងបងប្អូនប្រជាពលរដ្ឋទៅសំរាកនៅផ្ទះសំណាក់ «នាគទេព» ដើម្បីរង់ចាំយប់ថ្ងៃទី៧មីនា ទើបយន្តហោះដឹកពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េ ។

ជនរងគ្រោះ បានបញ្ជាក់ថា មិនត្រឹមតែចាញ់បោកមេ ខ្យល់អស់លុយក្នុងម្នាក់ៗចំនួន៧០០ដុល្លារឡើងទៅទេ គឺថែមទាំងចាញ់បោកមេខ្យល់ ដោយយកលុយខ្មែរទៅប្តូរយកលុយកូរ៉េ ដើម្បីយកទៅចាយនៅប្រទេសកូរ៉េអស់មួយចំនួនទៀត។ លុះនៅវេលាម៉ោងកើតហេតុ ដោយ មានការសង្ស័យ ខ្លាចមិនបានទៅធ្វើការនៅប្រទេសកូរ៉េ ទើបនាំគ្នាប្តឹងសមត្ថកិច្ច និងអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ដើម្បីជួយអន្តរាគមន៍ ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បានម្នាក់ ក្នុងចំណោមបក្សពួកចំនួន៣នាក់ ដើម្បីយកទៅសួរនាំភ្លាមៗតែម្តង។ សមត្ថកិច្ចនគរបាលជំនាញខណ្ឌពោធិ៍សែនជ័យ បន្ទាប់ ពីឃាត់ជនសង្ស័យបានម្នាក់យកទៅសួរនាំនោះ បានបញ្ជាក់ប្រាប់ថា រូបគេមានមេធំ២នាក់ទៀត ហើយរូបគាត់ជាអ្នកទទួលលុយ ពីបងប្អូនប្រជាពលរដ្ឋពិតប្រាកដមែន។ ទោះបីជាយ៉ាងណា ជនសង្ស័យជាមេខ្យល់នេះ មិនបានបញ្ជាក់លំអិតនោះទេ ហើយពេលនេះសមត្ថកិច្ចកំពុងតែសួរនាំបន្តទៀត៕

# ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២៣

## រដ្ឋបាលរាជធានីភ្នំពេញ ប្រជុំផ្សព្វផ្សាយ ស្តីពីការងារគ្រប់គ្រងហត្ថពលកម្មបរទេស សំដៅធ្វើយ៉ាងណាគ្រប់គ្រងជនបរទេស រស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញឱ្យបានល្អ

https://www.information.gov.kh/articles/99218 AKP ភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣

អាជ្ញាធររាជធានីភ្នំពេញ បានធ្វើការកោះអញ្ជើញម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញប្រមាណ ៤០០នាក់ មកជួបប្រជុំ ដើម្បីផ្សព្វផ្សាយលើការងារគ្រប់គ្រងហត្ថពលកម្មបរទេស ដើម្បីសំដៅធ្វើយ៉ាងណាគ្រប់គ្រងជនបរទេសដែលរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ឱ្យបានល្អ ចៀសវាងកុំឱ្យប្រព្រឹត្តបទល្មើសខុសច្បាប់ផ្សេងៗ នៅតាមទីតាំងដែលពួកគាត់ស្នាក់នៅ។

ថ្លែងក្នុងកិច្ចប្រជុំផ្សព្វផ្សាយ កាលពីរសៀលថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ នៅសាលារាជធានីភ្នំពេញ លោក ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ បានមានប្រសាសន៍ថា ការជួបប្រជុំនេះ គឺអាជ្ញាធររាជធានីភ្នំពេញ មានគោលបំណងឱ្យម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញទាំងអស់គ្រប់គ្រងជនបរទេសឱ្យបានល្អ នៅក្នុងទីតាំងរបស់ខ្លួន ពិសេសរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សគ្រប់ទម្រង់ ទប់ស្កាត់ការលេងល្បែងស៊ីសងគ្រប់ប្រភេទ តាមអនឡាញជាដើម និងទប់ស្កាត់ការលាងសម្អាតប្រាក់ ។ លោកអភិបាលរងបានបន្តថា ជាជំហានដំបូងនេះ អាជ្ញាធរគ្រាន់តែធ្វើការផ្សព្វផ្សាយច្បាប់តែប៉ុណ្ណោះ ដោយរដ្ឋបាលរាជធានីភ្នំពេញ ទុករយៈពេលឱ្យបងប្អូនជាម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរ ចំនួន៣ខែ គឺខែមេសា ឧសភា និងខែមិថុនា ។ លោកបានអះអាងថា ក្រោយពេល៣ខែនេះ ក្រុមការងារដែលមានកងកម្លាំងសមត្ថកិច្ចទាំងពីរភេទ អាជ្ញាធរដែនដី ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចុះពិនិត្យដល់ទីតាំងអាជីវកម្មរបស់បងប្អូនតែម្តង ។ ចំពោះជនបរទេសមករកស៊ី ធ្វើការនិងស្នាក់នៅកម្ពុជា ត្រូវយល់ដឹងពីច្បាប់របស់កម្ពុជានិងអនុវត្តន៍ឱ្យបានល្អ ចៀសវាងប្រព្រឹត្តបទល្មើសផ្សេងៗ ប្រាស់ចាកពីច្បាប់របស់កម្ពុជា។

លោក ហ៊ុន សុរិទ្ធី អភិបាលរងរាជធានីភ្នំពេញបានឱ្យដឹងដែរថា ចំពោះការងារលើនេះ មាន៣តំណាក់កាលដែលបងប្អូនជាម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរ ត្រូវដឹង ក្នុងនោះទី១ គឺអាជ្ញាធរត្រូវណែនាំនិងផ្សព្វផ្សាយដើម្បីឱ្យបងប្អូនបានដឹងពីច្បាប់យកទៅអនុវត្តន៍កុំឱ្យប្រព្រឹត្តខុសច្បាប់រហូតមានទោសទណ្ឌ។

ទី២ អនុវត្តន៍វិធានការរដ្ឋបាលដោយចុះពិនិត្យដល់ទីតាំង និងទី៣ វិធានការច្បាប់។ លោកអភិបាលរងក៏បានស្នើសុំដល់បងប្អូនជាម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរទាំងអស់គ្នា ចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីយើងរួមគ្នាលុបបំបាត់និងបង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទបាន៕ដោយ៖ សួស សំរិត សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរទុកពេល៣ខែឱ្យម្ចាស់លំនៅឋានគ្រប់ប្រភេទពង្រឹងការគ្រប់គ្រងជនបរទេស

https://www.khmertimeskh.com/501251966// តន វិបុល / Khmer Times March 9, 2023

អាជ្ញាធររាជធានីភ្នំពេញកាលពីថ្ងៃអង្គារបានកំណត់ទុកពេល៣ខែឱ្យម្ចាស់ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងខុនដូទាំងអស់ពង្រឹងការគ្រប់គ្រងជនបរទេស ដែលបានស្នាក់នៅ ដើម្បីរួមគ្នាបង្ការនិងទប់ស្កាត់ពួកគេប្រព្រឹត្តបទល្មើស ដូចជាការជួញដូរមនុស្ស ការលេងល្បែងខុសច្បាប់ និងការលាងសម្អាតប្រាក់ជាដើម។ ឱសានវាទដែលបានដាក់ចេញនេះធ្វើឡើងនៅពេលដែលអាជ្ញាធររាជធានីភ្នំពេញកោះហៅមនុស្សប្រមាណ ៤០០នាក់ ដែលជាម្ចាស់ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងខុនដូនៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ ដើម្បីណែនាំពីការងារគ្រប់គ្រងជនបរទេសបានមករស់នៅទីតាំងរបស់ពួកគេ។

លោក ហួត ហៃ អភិបាលរងរាជធានីភ្នំពេញ បានលើកឡើងថា ការកោះហៅពួកគេមកជួបជុំគ្នានេះ គឺផ្តោតសំខាន់លើការពង្រឹងការគ្រប់គ្រងជនបរទេស ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ទប់ស្កាត់ការលេងល្បែងខុសច្បាប់តាមអនឡាញ និងទប់ស្កាត់ការលាងសម្អាតប្រាក់។ លោកបញ្ជាក់ថា៖ «ក្នុងជំហានដំបូង យើងគ្រាន់តែធ្វើការផ្សព្វផ្សាយច្បាប់ប៉ុណ្ណោះ ហើយរដ្ឋបាលរាជធានីភ្នំពេញ ទុកពេល៣ខែឱ្យម្ចាស់ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងខុនដូ គឺខែមេសា ខែឧសភា និងខែមិថុនា»។ លោកថា៖ «ដល់ពេលកំណត់ ក្រុមការងារដែលមានកងកម្លាំងសមត្ថកិច្ច អាជ្ញាធរដែនដី ក្រសួងមហាផ្ទៃ និងក្រសួងការងារនឹងចុះពិនិត្យដល់ទីតាំងអាជីវកម្មរបស់ពួកគេតែម្តង»។ លោកបានណែនាំថា៖ «ជនបរទេសដែលមកធ្វើការងារ មករកស៊ី និងស្នាក់នៅកម្ពុជា គឺត្រូវយល់ដឹងពីច្បាប់របស់កម្ពុជានិងអនុវត្តដោយត្រឹមត្រូវ ហើយត្រូវចៀវាងប្រព្រឹត្តបទល្មើសផ្សេងៗដែលប្រាសចាកពីច្បាប់របស់កម្ពុជា»។

អភិបាលរងរាជធានីម្នាក់ទៀត គឺលោក ហ៊ុន សុរិទ្ធី បានសង្កត់ធ្ងន់ថា ការអនុវត្តការងារនេះមានបីដំណាក់ការ គឺដំណាក់ការដំបូង អាជ្ញាធរបានណែនាំ និងផ្សព្វផ្សាយច្បាប់ដល់ម្ចាស់ ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូទាំងអស់ត្រូវតែអនុវត្តតាម និងហាមប្រព្រឹត្តខុសរហូតមានទោសទណ្ឌ។ លោកបន្តថា ដំណាក់ការបន្ទាប់ ជាដំណាក់ការ ដែលអាជ្ញាធរអនុវត្តវិធានការរដ្ឋបាល ដោយការចុះពិនិត្យដល់ទីតាំង និងដំណាក់ការចុងក្រោយ ជាការអនុវត្តវិធានការច្បាប់។ ជាមួយនឹងគ្នានោះលោកអំពាវនាវដល់ម្ចាស់ឬអ្នកកាន់កាប់សណ្ឋាគារ អាផាតមិន និងម្ចាស់ខុនដូរទាំងអស់ចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរួមគ្នាលុបបំបាត់និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទ។

លោកនាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានព្រមានតាមរយៈសេចក្តីជូនដំណឹងកាលពីថ្ងៃទី១៧ ខែកុម្ភៈថា ខ្លួននឹងអនុវត្តវិធានការពិន័យអន្តរការជាប្រាក់ចំពោះម្ចាស់ និងអ្នកកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមិនបានជូនដំណឹងអំពីវត្តមានជនបរទេសជាជនអន្តោប្រវេសន្ត និងមិនមែនអន្តោប្រវេសន្តដែលបានស្នាក់នៅក្នុងលំនៅឋានរបស់ខ្លួនមកកាន់ស្ថាប័ននគរបាលមានសមត្ថកិច្ចក្នុយរយៈពេល២៤ម៉ោង។ ការពិន័យអន្តរការនេះអនុវត្តតាមសេចក្តីណែនាំ ស្តីពីគ្រប់គ្រងជនបរទេសក្នុងប្រទេសកម្ពុជា ក្នុងគោលដៅអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍។ ច្បាប់ស្តីពីអន្តោប្រវេសន៍បានចែកថា៖ «ម្ចាស់ឬអ្នកកាន់កាប់លំនៅឋានគ្រប់ប្រភេទត្រូវ

ជូនដំណឹងក្នុងរយៈពេល២៤ម៉ោងដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាន នៃជនបរទេសអន្តោប្រវេសន្ត និងមិនមែនអន្តោប្រវេសន្តដែលបានមកស្នាក់នៅឱ្យមានប្រសិទ្ធភាព»។

លោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានលើកឡើងថា បច្ចុប្បន្នប្រព័ន្ធ FPCS កត់ត្រាបានតែជនបរទេសស្នាក់នៅរយៈពេលវែងតែប៉ុណ្ណោះ ដោយឡែកជនបរទេស ដែលស្នាក់នៅរយៈពេលខ្លី ជាពិសេសភ្ញៀវទេសចរមិនបានចុះឈ្មោះក្នុងប្រព័ន្ធនេះនៅឡើយ។ លោកបានណែនាំក្រុមការងារស្វែងរកវិធីសាស្ត្រជំរុញឱ្យម្ចាស់លំនៅឋាន សណ្ឋាគារ និងរមណីយដ្ឋានទាំងអស់ត្រូវតែចុះឈ្មោះជនបរទេសដែលចូលមកស្នាក់នៅក្នុងទីតាំងរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ការពារសុវត្ថិភាពពួកគេ និងសម្រាប់បម្រើដល់ការងារស៊ើបអង្កេត ស្រាវជ្រាវសកម្មភាពល្មើសផ្សេងៗដែលបង្កឡើងដោយជនបរទេសក្នុងពេលស្នាក់នៅក្នុងកម្ពុជា។

លោក ស៊ឹង សែនករុណា មន្ត្រីអង្កេតផ្នែកសិទ្ធិមនុស្ស នៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ បានលើកឡើងថា វាជាកាតព្វកិច្ចរបស់អាជ្ញាធរត្រូវអនុវត្តច្បាប់។ ការអនុវត្តនេះ ជាយន្តការមួយដ៏ល្អ ដើម្បីការគ្រប់គ្រងជនបរទេសមករស់នៅក្នុងប្រទេសកម្ពុជា។ លោកកត់សម្គាល់ឃើញថា៖ «កន្លងមកមានជនបរទេសជាច្រើនដែលបានមករស់នៅក្នុងប្រទេសយើង ហើយមានមួយចំនួនបានប្រព្រឹត្តបទល្មើសផ្សេងៗដែលបានបង្កភាពអសន្តិសុខ។ ដូច្នេះជនបរទេសទាំងអស់ដែលមករស់នៅក្នុងប្រទេសគួរតែត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវតាមច្បាប់សម្រាប់ពួកគេ»៕

## អាជ្ញាធររាជធានីភ្នំពេញ ចុះដោះស្រាយបញ្ហារឿងពលករជាង ១០០នាក់ចាញ់បោកមេខ្យល់

https://news.btv.com.kh/article/20945 2023/03/09 08:33:10 am

ភ្នំពេញ៖ ពលករជាង ១០០នាក់ចាញ់បោកមេខ្យល់ថា រត់ការនាំទៅធ្វើការនៅប្រទេសកូរ៉េ ដោយអ្នកខ្លះចំណាយអស់លុយចាប់ពី ៨០០ដុល្លារដល់ ១០០០ដុល្លារសហរដ្ឋអាមេរិក ឥឡូវត្រូវបានអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ សហការជាមួយសាលារាជធានីភ្នំពេញ ចុះដោះស្រាយ នៅសង្កាត់កាកបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ នាល្ងាចថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣ ប្រាប់ឱ្យដឹងថា ពលករដែលចាញ់ល្បិចឆបោកមេខ្យល់ថា រត់ការទៅធ្វើការនៅប្រទេសកូរ៉េ សរុបទាំងអស់ ១២៥នាក់ ( ស្រី ៣៨នាក់) ក្រោយកើតហេតុអាជ្ញាធរសមត្ថកិច្ចខណ្ឌពោធិ៍សែនជ័យ ចាប់ខ្លួនជនសង្ស័យជាមេខ្យល់ ៤នាក់ ( ប្រុស ៣នាក់ ស្រី ម្នាក់ ) បញ្ជូនទៅកាន់ស្នងការដ្ឋានរាជធានីភ្នំពេញ ដើម្បីបន្តនីតិវិធី ។ អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ប្រាប់បន្តថា ពលករដែលចាញ់ល្បិចឆបោកមេខ្យល់ថា រត់ការទៅធ្វើការនៅប្រទេសកូរ៉េទាំង ១២៥នាក់ ( ស្រី ៣៨នាក់) នោះ ត្រូវបានក្រុមមេខ្យល់ទាំងអស់នោះប្រើល្បិចឆបោកមកពីបណ្ដាខេត្តនានា មានអ្នកខ្លះជាបងប្អូនបង្កើត និងអ្នកខ្លះទៀត បងប្អូនជីដូនមួយក៏មានដែរ ។ ដោយពលករខ្លះ ត្រូវចំណាយអស់លុយ ៨០០ដុល្លារ និងអ្នកខ្លះអស់លុយរហូតដល់ ១០០០ដុល្លារសហរដ្ឋអាមេរិក ។ អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ប្រាប់បញ្ជាក់ថា ដោយមានការយកចិត្តទុកដាក់ពីឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អាជ្ញាធររាជធានីភ្នំពេញបានបញ្ចេញរថយន្តដឹកបងប្អូនពលករទាំងអស់នោះទៅស្រុកកំណើតរៀងៗខ្លួន ដោយមិនគិតថ្លៃឡើយ ។

ជំនួសមុខអាជ្ញាធររាជធានីភ្នំពេញ សូមអំពាវនាវប្រជាពលរដ្ឋទាំងអស់ សូមកុំចាញ់បោកមេខ្យល់ដែលសន្យាថា រត់ការទៅធ្វើការនៅប្រទេសនេះ ប្រទេសនោះ ការពិតគឺជាល្បិចកល់សម្រាប់បោកបញ្ឆោតបងប្អូនទាំងអស់ ដើម្បីបានលុយពីបងប្អូន ។ មុននឹងបងប្អូនធ្វើអ្វីមួយ ត្រូវពិនិត្យ និងគិតអោយបានដិតដល់បំផុត តើក្រុមហ៊ុនមានយីហោឬអត់ ? និង មានអាជ្ញាប័ណ្ណអនុញ្ញាត ឬទេ ? ៕តារាវុទ្ធី

## នគរបាលប្រឆាំងការជួញដូរមនុស្សឃាត់ខ្លួនបុរសម្នាក់ជាមេខ្យល់ ពាក់ព័ន្ធករណី នាំពលករជាង ១០០នាក់ ទៅធ្វើការនៅកូរ៉េ

https://news.btv.com.kh/article/20961 2023/03/09 11:58:13 am

ភ្នំពេញ៖ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំសហការជាមួយកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌខណ្ឌពោធិ៍សែនជ័យ បានចុះត្រួតពិនិត្យរដ្ឋបាលផ្ទះសំណាក់មួយកន្លែងឃើហៅ «នាគទេព» រកឃើញជនរងគ្រោះចំនួន ១២៤នាក់ (ស្រី ៣៩នាក់) និងឃាត់ខ្លួនប្រុសមេខ្យល់ម្នាក់ រួមទាំងដកហូតលិខិតឆ្លងដែនមួយចំនួន ពាក់ព័ន្ធករណី នាំពលករមិនស្របច្បាប់ទៅធ្វើការនៅប្រទេសកូរ៉េ ។

សូមជម្រាបជូនថា កាលពីព្រឹកថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ ដោយមានការចង្អុលបង្ហាញពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរនគរបាលរាជធានីភ្នំពេញ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរង ទទួលផែនការងារប្រឆាំការជួញដូរមនុស្សនិងការពារអនីតិជននិងការងារយេនឌ័រ និងលោកវរសេនីយ៍ទោ ហាក់ លី នាយការិយាល័យ បានសហការជាមួយកម្លាំងគណៈបញ្ជាឯកភាពខណ្ឌពោធិ៍សែនជ័យ បានចុះត្រួតពិនិត្យរដ្ឋបាលផ្ទះសំណាក់ «នាគទេព» ស្ថិតក្នុងភូមិត្រពាំងល្វា១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ជនសង្ស័យដែលជាមេខ្យល់មាន ឈ្មោះ តាំ ច័ន្ទទី ហៅ សីហា ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ តាមចម្លើយសារភាពរបស់ជនសង្ស័យ បានឲ្យដឹងថា ខ្លួនបានកុហកបោកប្រាស់ទៅជនរងគ្រោះជាង ១០០ នាក់នោះថា នឹងនាំពួកគាត់ទៅធ្វើការនៅប្រទេសកូរ៉េ ដោយក្នុងម្នាក់ៗត្រូវចំណាយលុយពី ៦០០ទៅ ៨០០ដុល្លារ ដើម្បីចំណាយទៅលើការធ្វើលិខិតឆ្លងដែនរួចឲ្យមក បានសម្រាកនៅទីតាំងផ្ទះសំណាក់នេះត្រៀមចេញទៅប្រទេសកូរ៉េ។

តាមប្រភពពីជនរងគ្រោះ បានឲ្យដឹងថា ពួកគាត់ពិតជាបានបានខាតបង់ប្រាក់ដែលបានឲ្យទៅជនសង្ស័យជាមេខ្យល់ ក្នុងម្នាក់ៗ ចន្លោះពី ៦០០ដុល្លារ ទៅ ៨០០ដុល្លារ ពិតប្រាកដមែន។ បច្ចុប្បន្នកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន កំពុងកសាងសំណុំ បញ្ជូនជនសង្ស័យ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធីច្បាប់ ។ ចំណែកជនរងគ្រោះចំនួន ១២៤នាក់ (ស្រី ៣៩នាក់) អនុញ្ញាតឲ្យវិលត្រលប់ទៅលំនៅដ្ឋានវិញ៕ អត្ថបទ៖ កុម្ភៈ

# ថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០២៣

## តុលាការកំពូល តម្កល់ទោសបុរសអាមេរិកម្នាក់ ជាប់គុក ០៨ឆ្នាំ ពាក់ព័ន្ធនឹងការរៀតរៀនផ្លូវភេទ និងថាប់រំលោភក្មេងប្រុសកម្ពុជា ជាច្រើននាក់នៅ ខេត្តសៀមរាប

https://cen.com.kh/archives/630556.html Posted ByPen Srey NeatMarch 10, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២៣នេះ បានប្រកាសសាលដីកា តម្កល់ទោស បុរសជាប់ចោទជនជាតិអាមេរិកម្នាក់ ដែលបានតុលាការថ្នាក់ក្រោមកាត់ទោសដាក់ពន្ធនាគារកំណត់ ០៨ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងបទល្មើស: ការទិញពេស្យាចារកុមារ រូបភាព និង ការផលិតសម្ភារៈអាសអាភាស និងបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ ២០១៨ ។

លោក ជីវ កេង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះមានឈ្មោះ Reldy John Patrick ភេទប្រុស អាយុ ៥៩ ឆ្នាំ(កើតឆ្នាំ ១៩៦៣) ជនជាតិអាមេរិក ។ ចំណែកឯ ក្មេងប្រុសខ្មែរ

ដែលរងគ្រោះមានចំនួន៤នាក់ មានអាយុពី ១៣ ដល់១៩ ឆ្នាំ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ឈ្មោះ Reldy John Patrick ត្រូវបានសាលាដំបូងខេត្តខេត្តសៀមរាប កាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៩ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៨ ឆ្នាំ និង ពិន័យ ចំនួន ៤ លានរៀល ក្រោមការចោទប្រកាន់ពីបទ : ការទិញពេស្យាចារកុមារ រូបភាព និង សម្ភារៈអាសអាភាស និងបទ រំលោភសេពសន្ថវៈ តាមមាត្រា ៣៤ និង មាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ និង មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

ជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍។ តែតុលាការឧទ្ធរណ៍ បានតម្កល់ទោសរបស់គាត់ដដែល។ គាត់ក៏ប្តឹងសាទុក្ខ មកតុលាការកំពូលទៀត។ ជនជាប់ចោទរូបនេះ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០១៩ នៅភូមិតាកុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប៕ រក្សាសិទ្ធិដោយ: ចន្ទា ភា

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២៩នាក់

https://freshnewsasia.com/index.php/en/localnews/281560-2023-03-10-03-42-04.html 2023-03-10 10:42am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៧៧ករណី មានមនុស្ស ១,៩៨២នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៥៣សំណើ និងបិទសំណុំរឿង ២៥៨សំណើ (រកឃើញមនុស្ស ១,១៥៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៤នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៤ករណី៕

## ឃាត់ខ្លួនពលករខុសច្បាប់ប្រុស ស្រី ៧នាក់ លួចឆ្លងដែនតាមច្រករបៀងចូលទឹកដីថៃ

https://www.kampucheathmey.com/security/477255 ថ្ងៃសៅរ៍ ១១ មីនា ២០២៣ដោយ Sokhom Khon

ពលករប្រុស ស្រី ចំនួន៧នាក់ លួចឆ្លងដែនទៅរកការងារធ្វើនៅស្រុកថៃខុសច្បាប់ ត្រូវបានកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ឃាត់ខ្លួនបាននៅវេលាម៉ោង១១ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការបានប្រាប់ឲ្យដឹងថា កាឃាត់ខ្លួនពលករលួចឆ្លងដែនទៅរកការងារធ្វើនៅស្រុកថៃខុសច្បាប់នេះ ដោយអនុវត្តតាមបទបញ្ជាលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ។ ក្រោយទទួលបានផែនការហើយ លោកបានដឹកនាំមន្ត្រីក្រោមឱវាទចុះល្បាតត្រង់ចំណុចមាត់អូរព្រំដែនស្ថិតក្នុងភូមិសាស្ត្រភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃខេត្តបន្ទាយមានជ័យ បានធ្វើការឃាត់ខ្លួនពលករបានចំនួន៧នាក់ មានស្រី៣នាក់ ក្នុងនោះអ្នកនាំផ្លូវចំនួន១នាក់ឈ្មោះ ប្រឹក សំអ៊ី ភេទប្រុស អាយុ៣៧ ឆ្នាំ រស់នៅភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បំរុងលួចនាំពលករទាំង៧នាក់នេះទៅរក

ការងារធ្វើនៅប្រទេសថៃខុសច្បាប់ ពលករ៤នាក់ រស់នៅក្នុងខេត្តបន្ទាយមានជ័យ ១នាក់រស់នៅខេត្តកំពត ២នាក់រស់នៅខេត្ត កំពង់ចាម។

លោកវរសេនីយ៍ឯក សួង សៅ បានបន្តថា ពលករដែលលួចឆ្លងដែនចូលទៅប្រទេសថៃរកការងារខុសច្បាប់ទាំងនេះ ទាំងប្រថុយប្រថាន ពួកគាត់ប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ដូចជាត្រូវទាហានថៃបាញ់សម្លាប់ ចាប់ដាក់គុក និងធ្វើទារុណកម្ម ជិះរថយន្តរត់គេចពីការតាមចាប់ខ្លួនរបស់ទាហានថៃ បង្កគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យស្លាប់ និងចាញ់បោកមេខ្យល់កេងកម្លាំងពលកម្ម និងការជួញដូរមនុស្សទៅប្រទេសទី៣ជាដើម ។

ពាក់ព័ន្ធការឆ្លងដែនទៅរកការងារធ្វើខុសច្បាប់របស់ពលករខាងលើនោះ ពលករបាននិយាយថា ពួកគាត់គ្រោងនឹងចេញឆ្លងដែនទៅរកការងារជាកម្មករនៅក្នុងប្រទេសថៃ ហើយឆ្លងដែនតាមច្រករបៀងត្រូវសមត្ថកិច្ចបាប់បានតែម្តង។ ពលករទាំង៧នាក់ខាងលើបន្ទាប់ពីសមត្ថកិច្ចធ្វើការអប់រំ និងឲ្យធ្វើកិច្ចសន្យាបញ្ឈប់ការឆ្លងដែនខុសច្បាប់តទៅទៀត ហើយសមត្ថកិច្ចបានប្រគល់ពួកគាត់ជូនទៅផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីអនុវត្តទៅតាមនិតិវិធីបន្ត៕ អត្ថបទ៖ វ៉ាន់ ណាង

## មន្ទីរកិច្ចការនារីរាជធានី ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រីនិងកុមារ

https://cen.com.kh/archives/631206.html Posted ByPen Srey NeatMarch 10, 2023

ភ្នំពេញ ៖ វគ្គអប់រំផ្សព្វផ្សាយច្បាប់ស្តីពីកម្មវិធីច្បាប់ប្រឆាំងការជួញដូរស្ត្រីនិងកុមារនិងការ ទប់ស្កាត់ការរំលោភរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ នៅរសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣នេះ ក្រោម កិច្ចសហការរវាងមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ និងអង្គការភាពការពារកុមារដោយមានកិច្ចសហការជាមួយរដ្ឋបាលសាលាខណ្ឌដូនពេញ។ សមាសភាពចូលរួមមាន ប្រធាន គ.ក.ស.ក ខណ្ឌ, មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាល ភាពសង្គមខណ្ឌ, ចៅសង្កាត់, ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់,មន្ត្រី ទួលបន្ទុកកិច្ចការពារនិងកុមារសង្កាត់ និងប្រធានភូមិ សរុបចំនួនជិត ១០០នាក់។ វគ្គផ្សព្វផ្សាយនេះក្នុងគោលបំណងអ្នកចូលរួមទទួលបានព័ត៌មាន ស្តីពីល្បិចកលរបស់មេខ្យល់ក្នុងការជួញដូរស្ត្រីនិង កុមារ ការរំលោភសេពសន្ថវៈ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងសេវាអន្តរាគមន៍លើកករណីនៃការជួញដូរ និការរំលោភ សេពសន្ថវៈលើស្ត្រីនិងកុមារ។

នៅក្នុងឱកាសនោះដែរលោកមុត សុវណ្ណ នាយករដ្ឋបាលសាលាខណ្ឌ ដូនពេញ មានបញ្ជាក់ថា:វគ្គផ្សព្វផ្សាយនេះពិតជាមានសារៈសំខាន់ដើម្បីបងប្អូន ប្រជាពលរដ្ឋ ក៏ដូច ជាមេភូមិ សមាជិកភូមិ នៅតាមបណ្ដាសង្កាត់ក្នុងភូមិសាស្ត្រខណ្ឌដូន ពេញ ដើម្បីទទួលបាននូវព័ត៌មានពីល្បិចកលមេខ្យល់និងបានយល់ដឹងអំពីការរំលោភ បំពាន ច្បាប់ផ្លូវលើស្ត្រីនិងកុមារ តាមគ្រប់រូបភាព ។ជាពិសេសការជួយអន្តរាគមន៏ដល់ជនរងគ្រោះឲ្យបានទាន់ពេលវេលាពីសំណាក់អាជ្ញាធរមូលដ្ឋាន។ លោកមុត សុវណ្ណ បានបញ្ជាក់ទៀតថា:ការបញ្ជ្រាប ច្បាប់ដល់មន្ត្រីនគរបាលប៉ុស្តិ៍ មេភូមិ អនុភូមិ ពិតមានសារៈសំខាន់ក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ។

លោកស្រីឈឹម វត្តី តំណាងក្រុមប្រឹក្សាខណ្ឌដូនពេញ មានប្រសាសន៍បញ្ជាក់ថា ស្ត្រីនៅខណ្ឌដូនពេញ បានធ្វើជាគំរូដល់យុវជនជំនាន់ក្រោយ ស្ត្រីបានចូលរួមយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ដើម្បីសុខុមាល ភាពរបស់ប្រជាជនគ្រប់រូប។

សូមបញ្ជាក់ថា ការជឿនលឿននៃផ្នែកបច្ចេកវិទ្យា និង ការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធឺណិតនៅទូទាំងពិភពលោកបាន បង្កើននិន្នាការថ្មីគួរឱ្យព្រួយបារម្ភដែលអាចនាំឱ្យកុមារប្រឈមនឹងហានិភ័យ។ខណៈដែលអ្នកប្រើប្រាស់ អ៊ីនធឺណិតស្ទើរតែម្នាក់ក្នុងចំណោម៣នាក់ជាកុមារ ជនល្មើសផ្លូវភេទលើកុមារ កំពុងតែប្រើប្រាស់អ៊ីនធឺណិតដើម្បី ទាក់ទងជាមួយកុមារ និងសម្របសម្រួលដើម្បីប្រព្រឹត្តអំពើកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ជាមួយគ្នាដែរការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទ ដែល អាច

កើតឡើងចំពោះកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ។ ពោលរួមបញ្ចូលទាំងការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ បណ្តាលឱ្យកុមារត្រូវបានគេកេង ប្រវ័ញ្ច ផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬ បញ្ជូននូវរូបភាព ឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

បើទោះបីជាយ៉ាងណាបច្ចុប្បន្ននៅប្រទេសកម្ពុជា សង្កេតឃើញថា : ការវិភាគស្ថានភាពមួយលើប្រធានបទការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ ក្នុងប្រទេសកម្ពុជា ដែលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្ហាញថា:ក្នុង ចំណោម កុមារ ២២០នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ១នាក់ក្នុងចំណោម ៦នាក់ ធ្លាប់ប្រឈមនឹង ហានិភ័យដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញដែល ភាគច្រើនក្នុងទម្រង់នៃ ការលួងលោមឬទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទពីមនុស្សពេញវ័យតាមអនឡាញ។ការកើនឡើង នៃការប្រើប្រាស់អ៊ីនធឺណិតក្នុងចំណោមកុមារនៅកម្ពុជា បូក រួមទាំងការមានកម្រិតទាបផ្នែកចំណេះដឹង របស់ឪពុកម្តាយ និងអ្នកថែទាំកុមារអំពីហានិភ័យផ្សេងៗ ជាហេតុនាំឲ្យមានការកើនឡើងនៃចំនួនកុមារដែលប្រឈមនឹងហានិភ័យពីការកេងប្រវ័ញ្ចផ្លូវ ភេទតាមអនឡាញ៕ រក្សាសិទ្ធិដោយ : សុវណ្ណារិទ្ធ

## អ្នកសុំទានខ្មែរ៤នាក់ជាមួយកូនក្មេង ត្រូវបានឃាត់ខ្លួននៅប៉ាតាយ៉ាប្រទេសថៃ

https://www.khmertimeskh.com/501253182// March 11, 2023

អ្នកសុំទានត្រូវបានគេស្គាល់ថា ជាជនជាតិខ្មែរឈ្មោះ ពយ អាយុ៥៨ឆ្នាំ សោមផុន អាយុ៦៨ឆ្នាំ នី អាយុ៤៣ឆ្នាំ និងជា អាយុ៤២ឆ្នាំ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនពេលរៀបចំសណ្តាប់ធ្នាប់តាមបណ្តោយផ្លូវទី២ កាលពីថ្ងៃទី៧ ខែមីនា។ ពួកគេមិនត្រូវបានប្រាប់ពីនាមត្រកូលនោះទេ។ ពួកគេត្រូវបានរកឃើញថាមិនមានទិដ្ឋាការត្រឹមត្រូវ និងកំពុងត្រូវបានរៀបចំឯកសារសម្រាប់ការនិរទេស។ បញ្ហាអ្នកសុំទាននៅប៉ាតាយ៉ាមិនបានធូរស្រាលទេជាមួយនឹងការបើកទីក្រុងឡើងវិញ។ ទោះបីជាមានការខិតខំប្រឹងប្រែងពីអង្គការសុខុមាលភាពសង្គមដើម្បីផ្លាស់ទីអ្នកសុំទានទៅកាន់ទីជម្រកសម្រាប់អ្នកគ្មានផ្ទះសម្បែង ហើយនគរបាល បានធ្វើការបង្ក្រាបក្រុមជួញដូរមនុស្សក៏ដោយ ក៏វានៅតែឃើញមានអ្នកសុំទាននៅក្នុងទីក្រុង។

នគរបាលបាននិយាយថា ក្រុមជួញដូរមនុស្សបានចាប់គូស្រ្តីជាមួយកុមារតូចៗ ដែលមិនមានជាប់សាច់ឈាម ដើម្បីទាក់ទាញការអាណិតអាសូរ និងសុំលុយពីអ្នកទេសចរ។ ក្នុងយុទ្ធនាការបញ្ឈប់លំហូរអ្នកសុំទានចូលមកក្នុងទីក្រុង សាលាក្រុង Pattaya-Nongprue សហការជាមួយក្រសួងសុខុមាលភាពសង្គម និងអភិវឌ្ឍន៍មនុស្ស និងមជ្ឈមណ្ឌលការពារជនទុគតខេត្តឈុនបុរី កំពុងស្នើសុំសហគមន៍បញ្ឈប់ការផ្តល់ប្រាក់ដល់អ្នកសុំទាន។ ជាមួយគ្នានេះ អាជ្ញាធរក៏បានស្នើឱ្យប្រជាពលរដ្ឋ ប្រុងប្រយ័ត្នចំពោះសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស មិនថាកុមារ ឬមនុស្សធំនោះទេ។ Pattaya Mail

# ករណីជួញដូរមនុស្សនៅកម្ពុជាត្រូវកកើតជាថ្មីតាមរយៈការចុះផ្សាយរបស់សារព័ត៌មានបរទេស

https://www.rfi.fr/km//20230311?ref=tg_i ចុះផ្សាយនៅថ្ងៃ៖ 11/03/2023 - 07:42

ករណីជួញដូរមនុស្សនៅក្នុងខេត្តព្រះសីហនុ ត្រូវបានកំរើកជាថ្មីម្តងទៀត តាមរយៈការចុះផ្សាយរបស់ស្ថាប័នសារព័ត៌មានអង់គ្លេស BBC។ វីដេអូឯកសារប្រមាណជាង៥០នាទី របស់BBC ដែលបង្ហោះ កាលពីថ្ងៃទី៨មីនា បានបង្ហាញថា ជនរងគ្រោះជាច្រើននៅតែបន្តជាប់ឃុំឃាំង នៅក្នុងទីតាំងបនល្បែងមួយចំនួន នៅក្នុងខេត្តជាប់មាត់សមុទ្រមួយនេះ។ បញ្ហាជួញដូរមនុស្សនៅកម្ពុជា នៅតែបន្តទទួលបានការចាប់អារម្មណ៍ពីបណ្តាសារព័ត៌មានអន្តរជាតិ។ តាមរយៈវីដេអូប្រមាណជាង៥០នាទី BBC បានបង្ហាញថា ជនរងគ្រោះ ជាជនបរទេសដែលត្រូវបានឆបោកមកធ្វើការនៅទីតាំងបនល្បែងកម្សាន្តក្នុងខេត្តព្រះសីហនុ បានអះអាងថា រូបគេត្រូវបានបង្ខំឲ្យធ្វើការរយៈពេល១២ម៉ោងក្នុងមួយថ្ងៃ ដោយគ្មានពេលសម្រាក។ ជាការលួចផ្តិតយកវីដេអូខ្លីៗ ជនរងគ្រោះ ដែលស្រង់សម្តីដោយ BBC បានបញ្ជាក់ថា ពួកគេត្រូវបង្ខំឲ្យធ្វើការ បើពុំដូច្នេះ នឹងត្រូវទទួលពិន័យ តាមរយៈការវាយដំ និងការប្រើប្រាស់ឧបករណ៍ឆក់ជាដើម។

តាមជនរងគ្រោះ ដែលស្រង់សម្តីដោយ BBC គឺពួកគេបានចាញ់បោកឧក្រិដ្ឋជនតាមរយៈបណ្តាញសង្គមនានា ដែលឆបោកពួកគេ ពីឱកាសការងារដែលរកប្រាក់ចំណូលបានខ្ពស់នៅក្នុងខេត្តព្រះសីហនុ។ ក៏ប៉ុន្តែអ្វីដែលជាក់ស្តែង គឺពួកគេត្រូវបានឃុំឃាំងនៅកន្លែងការងារ ដោយមិនអនុញ្ញាតឲ្យចេញមកខាងក្រៅ និងមានទំនាក់ទំនងជាមួយសាច់ញាតិ។ ទោះយ៉ាងណា អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានច្រានចោលអំពីការចុះផ្សាយរបស់សារព័ត៌មាន BBC ថាមិនមែនជាការពិតទាំងស្រុង។ លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃនេះថា រាប់តាំងពីខែសីហាមក ក្រសួងមហាផ្ទៃទទួលបានពាក្យបណ្តឹងពីជនរងគ្រោះប្រមាណជាង ៧៧០ករណី តាមរយៈហ្វេសប៊ុកផេករបស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងផេករបស់អគ្គស្នងការនគរបាលជាតិ។ តាមលោក ខៀវ សុភ័គ អាជ្ញាធរបានចុះបង្ក្រាបទីតាំងចំនួន៥ និងជួយសង្គ្រោះជនរងគ្រោះប្រមាណជាង ១៨០០នាក់។

អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានអះអាងទៀតថា ទីតាំងដទៃនៅក្នុងខេត្តព្រះសីហនុ ក៏កំពុងស្ថិតនៅក្នុងកណ្តាប់ដៃស៊ើបអង្កេតរបស់អាជ្ញាធរ។ បើតាមលោក ខៀវ សុភ័គ ក្រោយការបង្ក្រាបរបស់អាជ្ញាធរ មួយរយៈកាលចុងក្រោយនេះ បានធ្វើឲ្យករណីជួញដូរមនុស្សនៅកម្ពុជា មានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។

នៅទន្ទឹមនេះ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃ១២ធ្នូ ធ្លាប់ថាចរន្តនៃការវិលត្រឡប់មកវិញដោយឥតគ្រោងទុករបស់ពលករកម្ពុជា ពីប្រទេសគោលដៅក្នុងអំឡុងកូវីដ-១៩ បានធ្វើឲ្យជនទេសន្តរប្រវេសន៍បរទេសខុសច្បាប់ជាច្រើន មានឱកាសបន្លំខ្លួនចូលមកកម្ពុជាដោយខុសច្បាប់ និងបានសម្ងំលាក់ខ្លួន ធ្វើការងារជាមួយនិយោជកទុច្ចរិតមួយចំនួន ដែលបង្កើតបានជាបទល្មើសយ៉ាងអាណាធិបតេយ្យលើទឹកដីកម្ពុជា។ សម្រាប់លោក ស ខេង ចំពោះបញ្ហានេះ រដ្ឋាភិបាលកម្ពុជា មិនបានព្រងើយកន្តើយឡើយ គឺបានដាក់ចេញនូវវិធានការប្រតិបត្តិការ ដើម្បីរុករក បង្ក្រាប និងបោសសម្អាតបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធដទៃទៀតយ៉ាងសកម្ម តាមវិធានការច្បាប់ហេតុធ្វើឲ្យកម្ពុជាវិលត្រឡប់មករកស្ថានភាពសុវត្ថិភាព និងសន្តិសុខជាប្រក្រតីឡើងវិញនៅទូទាំងប្រទេស ហើយរដ្ឋាភិបាលនៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនជាពិសេសអំពើជួញដូរមនុស្ស និងបន្តអនុវត្តរាល់បទដ្ឋានដែលជាប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធិ និងកិច្ចការពារសុវត្ថិភាពមនុស្សជាតិ៕

# ថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០២៣

## ច្រករបៀងណង់ចាន់
## ជាច្រកសម្រាប់ពលករខ្មែរទៅរកការងារធ្វើតាមបន្ទាត់ព្រំដែនទៅព្រឹកវិលល្ងាច

https://kohsantepheapdaily.com.kh/article/1700392.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ១១ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ២១:៤២

បន្ទាយមានជ័យ ៖ ច្រករបៀងណង់ចាន់ជាច្រកសម្រាប់ពលករខ្មែរទៅរកការងារធ្វើតាមបន្ទាត់ព្រំដែនទៅព្រឹកវិលល្ងាចដែលស្ថិតភូមិអាងសីលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។ ជាក់ស្តែងនៅល្ងាចថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២៣នេះ នៅច្រកណងចាន់(អាងសីលាខ្មែរ) ឃើញមានប្រជាពលរដ្ឋជាពលរដ្ឋខ្មែរត្រឡប់ពីធ្វើការនៅប្រទេសថៃតាមបន្ទាត់ព្រំដែនទៅព្រឹកវិលល្ងាច១ថ្ងៃ មានប្រមាណជិត១០០នាក់ ដែលជាពលរដ្ឋរស់នៅក្បែរព្រំដែន។

ប្រជាពលរដ្ឋបានប្រាប់ថា ៖ ប្រជាពលរដ្ឋ ដែលរស់ក្បែរព្រំដែនគ្មានមុខរបបអ្វីក្រៅនាំគ្នាឆ្លងដែនទៅរកការងារធ្វើតាមជាយដែន នៃប្រទេសថៃ ដែលធ្វើជាពលករកាប់អំពៅ ដឹកដំឡូងមី និងធ្វើការងារអ្វើផ្សេងទៀតសម្រាប់ជីវិភាពគ្រួសារដែលរកកម្រៃបានក្នុង១ថ្ងៃ ពី៣០០ ទៅ ៤០០បាត ហើយអាចទៅមកព្រឹកវិលល្ងាចដែលថៅកែថៃចាំមកទទួលនៅក្បែរព្រំដែន ។ ប្រជាពលរដ្ឋបានបញ្ជាក់ថា ៖ នៅពេលដែលពួកឆ្លងដែនតាមច្រករបៀងទៅរកការងារធ្វើតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃចេញចូលដែលប្រើតែអត្តសញ្ញាណប័ណ្ណ និងប័ណ្ណចាក់វ៉ាក់សាំងការពារកូវីដ.១៩ ដែលមានយកយល់ពីកងកកម្លាំងកម្ពុជា និងកម្លាំងភាគីថៃដោយចេញចូលទៅរកការងារធ្វើព្រឹកវិលល្ងាច គឺមិនបានអស់លុយនោះទេ ។

ប្រជាពលរដ្ឋបានបញ្ជាក់រំលឹកថា ៖ប្រជាពលរដ្ឋដែលនៅក្បែរព្រំដែនទំនេរពីធ្វើស្រែ និងចម្ការខ្លួនឯងដែលគ្មានការងារធ្វើភាគច្រើនបានឆ្លងដែនទៅរកការងារធ្វើតាមបន្ទាត់ព្រំដែនសម្រាប់ចិញ្ចឹមគ្រួសារដែលគ្រាន់កាន់កាំបិតនិងពូថៅឬចមចូលទៅរកការងារនៅក្បែរព្រំដែនក្នុងទឹកដីថៃបានទៅព្រឹកវិលល្ងាចហើយបាននៅជាមួយក្រុមគ្រួសារ ។ កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនបានបញ្ជាក់ថា ៖ សម្រាប់ប្រជាពលរដ្ឋដែលចេញ.ចូលទៅព្រឹកវិលល្ងាចរកការងារធ្វើតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃគឺគ្មានច្បាប់អោយចេញ.ចូលនោះទេ តែដោយមានការយកយល់ពីកងកម្លាំងជាប់ព្រំដែនកម្ពុជា និងថៃបានសម្របសម្រួលគ្នាអោយប្រជាពលរដ្ឋចេញ.ចូលព្រឹកវិលល្ងាចសម្រាប់ប្រជាពលរដ្ឋរស់នៅជាប់ជាយដែនឃើញមុខរាល់ថ្ងៃទើបអនុញ្ញាត៕

## ក្រុមឆបោកដែលមានមូលដ្ឋាននៅកម្ពុជាបោកបញ្ឆោតមនុស្សចូលក្នុងពាណិជ្ជកម្មអេឡិចត្រូនិកតាមប្រព័ន្ធអ៊ីនធឺណិតក្លែងក្លាយ

https://www.khmertimeskh.com/501253458//?p=1253458 March 12, 2023

នគរបាលវៀតណាម បានចាប់ក្រុមឧក្រិដ្ឋជនមួយក្រុម ដែលជ្រើសរើសមនុស្សឲ្យធ្វើការលើគេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិកក្លែងក្លាយ។ នគរបាលព្រហ្មទណ្ឌក្រសួងសន្តិសុខសាធារណៈបានឲ្យដឹងថា ពួកគេបានសហការជាមួយអាជ្ញាធរកម្ពុជា និងបានចាប់ខ្លួនជនសង្ស័យចំនួន ២៣ នាក់ ដែលសុទ្ធតែជាជនជាតិវៀតណាម។ ជនសង្ស័យនឹងត្រូវស៊ើបអង្កេតពីបទ «ក្លែងបន្លំទ្រព្យសម្បត្តិ»។ នគរបាលបានឲ្យដឹងថា ជនសង្ស័យធ្វើការនៅពេងចក្រមួយក្នុងប្រទេសកម្ពុជារួមជាមួយជនបរទេសដែលមានសញ្ជាតិមិនត្រូវបានគេបង្ហាញឱ្យដឹង។ សកម្មភាពខុសច្បាប់ទាំងអស់របស់ពួកគេត្រូវបានធ្វើតាមប្រព័ន្ធអ៊ីនធឺណិត។ ការស៊ើបអង្កេតបានបង្ហាញថានៅចន្លោះខែមីនា និង

ខែកក្កដាឆ្នាំមុន ក្រុមនេះបានជ្រើសរើសមនុស្សឱ្យធ្វើការតាមអ៊ីនធឺណិតសម្រាប់គេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិកដែលប្រើប្រាស់ដោយខុសច្បាប់នូវឈ្មោះគេហទំព័រស្របច្បាប់ដូចជា Shopee, Lazada និង Tiki ។

ជាក់ស្តែង សមាជិកក្រុមឆបោកបានបង្កើតគេហទំព័រក្លែងក្លាយសម្រាប់គេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិក ដើម្បីធ្វើឱ្យដៃគូគិតថាពួកគេកំពុងធ្វើការនៅលើគេហទំព័រពិតប្រាកដ។ ខ្លឹមសារលម្អិតនៃការងារបានបង្ហាញថាអ្នកសហការនឹងទទួលបន្ទុកបង្កើតការបញ្ជាទិញសម្រាប់ហាងមួយចំនួននៅលើគេហទំព័រក្លែងក្លាយ។ ដូចដែលក្រុមឆបោកបានប្រាប់ដៃគូរបស់ពួកគេ គោលបំណងនៃការបង្កើតការបញ្ជាទិញគឺដើម្បីបញ្ឆោតអតិថិជនពិតប្រាកដឱ្យជឿថាហាងអនឡាញបានលក់ផលិតផលជាច្រើន ដែលជាហេតុធ្វើឱ្យ អតិថិជនមើលទៅលើចំនួនផលិតផលដែលមាន ត្រូវបានលក់ដើម្បីវាយតម្លៃគុណភាពរបស់អ្នកលក់អនឡាញ។ដូច្នេះ អ្នកសហការជឿទាំងស្រុង ហើយគិតថាពួកគេពិតជាធ្វើការសម្រាប់ហាងដែលបានចុះបញ្ជីនៅលើគេហទំព័រស្របច្បាប់។ ដើម្បីត្រូវបានគេជ្រើសរើសអោយធ្វើការ អ្នកសហការដំបូងត្រូវផ្ទេរប្រាក់ចំនួនជាក់លាក់ទៅអោយក្រុមឆបោក។ បន្ទាប់ពីផ្ទេរប្រាក់រួច ក្រុមឆបោកបានផ្ញើកិច្ចសន្យាឱ្យពួកគេតាមរយៈ Telegram ។ បន្ទាប់មកអ្នកសហការត្រូវបង្កើតគណនីនៅលើគេហទំព័រក្លែងក្លាយទាំងនោះដើម្បីធ្វើការបញ្ជាទិញតាមអ៊ីនធឺណិត។

សមាជិកនៃក្រុមឆបោកនឹងកាត់លុយចេញពីចំនួនប្រាក់ ដែលអ្នកសហការបានផ្ទេរនៅពេលណា ដែលអ្នកសហការបង្កើតការបញ្ជាទិញតាមអ៊ីនធឺណិតដោយជោគជ័យ។ ដូចដែលក្រុមឆបោកបានផ្សព្វផ្សាយ អ្នកសហការនឹងត្រូវបានបង់កម្រៃជើងសារដោយផ្អែកលើចំនួននៃការបញ្ជាទិញដែលពួកគេបានដាក់ ហើយប្រាក់ដែលបានចំណាយដើម្បីទិញផលិតផលតាមអ៊ីនធឺណិតនឹងត្រូវបានសងវិញនៅពេលក្រោយ។ ដំបូងឡើយ ក្រុមឆបោកបានសងប្រាក់ទៅអ្នកសហការវិញសម្រាប់ប្រាក់មួយចំនួនដែលពួកគេបានចំណាយដើម្បីទិញផលិតផលរួមជាមួយនឹងកំរៃជើងសារមួយចំនួន ប៉ុន្តែបន្ទាប់ពីការបញ្ជាទិញមួយចំនួន ពួកគេបានលុបគណនីរបស់អ្នកសហការនៅលើគេហទំព័រក្លែងក្លាយ រួមជាមួយនឹងលុយទាំងអស់ដែលអ្នកសហការបានផ្ទេរអោយ។ VNExpress

## ឃាត់ខ្លួនម្ចាស់ហាងជំនោរបឹងលាភ និង KTV 168 ពីបទផ្តល់ទីតាំងសម្រាប់ធ្វើពេស្យាចារ បម្រើផ្លូវភេទលើអនីតិជន

https://cen.com.kh/archives/631659.html Posted ByPen Srey NeatMarch 12, 2023

កណ្ដាល : សមត្ថកិច្ចឃាត់ខ្លួនថៅកែហាង ជំនោរបឹងលាភ ពាក់ព័ន្ធទៅនឹងករណីផ្តល់ទីកន្លែងសម្រាប់ពេស្យាចារ (បម្រើផ្លូវភេទលើអនីតិជនអាយុក្រោម ១៥ឆ្នាំ)។ នៅថ្ងៃសៅរ៍ ទី១១ ខែមីនា ឆ្នាំ២០២៣ ក្រោយពីមានការបញ្ជាផ្ទាល់ពីលោកវរសេនីយ៍ឯក ដួង តេង អធិការនគរបាលស្រុកពញាឮ និងការិយាល័យជំនាញប្រឆាំងការជួញដូរ! ធ្វើការស្រាវជ្រាវ បង្ក្រាបករណី "ករណីការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ" ដែលកើតហេតុនៅថ្ងៃទីពុំចាំ ខែកុម្ភៈ ឆ្នាំ២០២៣ ចំនុចអាហារដ្ឋាន និងខារ៉ាអូខេឃីហោ ជំនោបឹងលាភ168 ភូមិ ទួលព្រិច ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល។

តាមរបាយការណ៍ពីសមត្ថកិច្ចបានឲ្យដឹងថា ករណីឃាត់ខ្លួនជនសង្ស័យពីរនាក់ប្តីប្រពន្ធជាម្ចាស់ហាង ខាងលើ គឺបន្ទាប់ពីមានបណ្តឹងរបស់ក្មេងស្រីវ័យ១៤ឆ្នាំជាអនីតិជន ប្តឹងពីបទបញ្ឈប់បុគ្គលិកមិនបើកប្រាក់ខែ ជេរប្រមាថ បង្ខំឲ្យបំរើផ្លូវភេទ បៀតបៀនកេរ្តិ៍ខ្មាស ជួញដូរផ្លូវភេទ និងឃាត់បិតសិទ្ធិមិនឲ្យចេញក្រៅ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹង កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្សនិងអនិកជន នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ធ្វើការស្រាវជ្រាវ និងបានរកឃើញថាម្ចាស់ហាង KTV ពីរនាក់ប្តីប្រពន្ធ ខាងលើពិតជាបានផ្តល់ទីកន្លែងសម្រាប់ពេស្យាចារ (បម្រើផ្លូវភេទ)។

ជនរងគ្រោះមានចំនួន០៣នាក់ ជាអនីតិជនចំនួន០២នាក់៖ ១-ឈ្មោះ ក.ឈ.អ ភេទ ស្រី អាយុ១៤ឆ្នាំ ០៣ខែ ១៧ថ្ងៃ (មានសំបុត្របញ្ជាក់កំណើត) ជនជាតិ ខ្មែរ មុខរបរ បុគ្គលិកខារ៉ាអូខេ មានទីលំនៅ ភូមិ កន្ទួតគង កាង ឃុំ ថ្នល់ថ្មី ស្រុក ពញាក្រែក ខេត្ត កំពង់ចាម។ ២-ឈ្មោះ វ.ស.ន ភេទ ស្រី អាយុ១៤ ឆ្នាំ ០៦ ខែ (មានសំបុត្របញ្ជាក់កំណើត) មុខរបរ បុគ្គលិកខារ៉ាអូខេ មានទីលំនៅភូមិ ៣៨ ឃុំ លើកដែក ស្រុក ស្អាង ខេត្ត កណ្តាល។ ៣-ឈ្មោះ ឡ.ស.ផ ហៅ ស្រីកា ភេទ ស្រី អាយុ ២១ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ បុគ្គលិកខារ៉ាអូខេ មានទីលំនៅភូមិស្រែក្រសាំង ឃុំ ពពក ស្រុក ស្ទោង ខេត្ត កំពង់ធំ បច្ចុប្បន្នអ្នកទាំង០៣នាក់ខាងលើ ស្នាក់ក្នុងអាហារដ្ឋាន និងខារ៉ាអូខេឃីហោ ជំនោបឹងលាភ168 ភូមិទួលព្រិច ឃុំជ្រៃលាស់ ស្រុក ពញាឮ ខេត្តកណ្តាល។

ជនសង្ស័យ ០២នាក់ ១-ឈ្មោះ ជុំ ជឿន ភេទ ប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ ម្ចាស់អាហារដ្ឋាន និង ខារ៉ាអូខេឃីហោ ជំនោបឹងលាភ 168 ។ ២-ឈ្មោះ ងិន សុខន ភេទ ស្រី អាយុ៣៩ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ ម្ចាស់អាហារដ្ឋាន និង ខារ៉ាអូខេឃីហោ ជំនោបឹងលាភ 168 មានទីលំនៅភូមិ ទួលព្រិច ឃុំ ជ្រៃលាស់ ស្រុក ពញាឮ ខេត្ត កណ្តាល បច្ចុប្បន្នជនសង្ស័យ បានបញ្ជូនទៅតុលាការខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធី។

សូមបញ្ជាក់ដែរថា នារីរងគ្រោះជាអនីតិជនទាំងនោះ ទទួលបានការឧបត្ថម្ភគាំទ្រផ្នែកការពារផ្លូវច្បាប់ ពីអង្គការមេត្រីអន្តរជាតិ AIM ដែលមានលោក ស៊ឹម រិទ្ធីយ៉ា ប្រធានក្រុមស៊ើបអង្កេត ដឹកនាំក្រុមការងារចុះសួរសុខទុក្ខក្មេងៗរងគ្រោះ ថែម ទាំងបានផ្តល់នូវថវិកាមួយចំនួន សម្រាប់ការធ្វើដំណើរវិលទៅស្រុកកំណើតជួបជុំគ្រួសារ។ ក្មេងស្រីដែលរងគ្រោះទាំងនោះ សព្វថ្ងៃនេះមានជីវភាពខ្វះខាតយ៉ាងខ្លាំង ទើបសម្រេចចិត្តមករកការងារធ្វើ ដើម្បីបានលុយផ្តល់ឲ្យគ្រួសារ តែជាអកុសល មានសំណាងមិនល្អ ត្រូវបានថៅកែឲ្យទៅបម្រើការងារផ្លូវភេទ ដោយឲ្យដេកជាមួយភ្ញៀវ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ពលករខ្មែរនៅប្រទេសកូរ៉េខាងត្បូង ត្រូវបានថៅកែកូរ៉េគំរាមបណ្តេញចេញពីការងារ

https://www.rfa.org/khmer/news/human-rights/cambodian-workers-in-south-korea-fired-by-employers-03112023003358.html ដោយ ឡេង ម៉ាលី2023.03.11

ពលករខ្មែរនៅកូរ៉េអំពាវនាវដល់ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ ឱ្យជួយអន្តរាគមន៍ចំពោះពលករដែលមកធ្វើការនៅកូរ៉េកំពុងជួបទុក្ខលំបាកដោយសារថៅកែកូរ៉េរំលោភសិទ្ធិការងារ។ ការលើកឡើងនេះគឺបន្ទាប់ពីថៅកែជនជាតិកូរ៉េម្នាក់ស្តីបន្ទោស និងគំរាមបណ្តេញពលករខ្មែរម្នាក់គឺ កញ្ញា ថៃ ស្រីឡែន ចេញពីការងារទាំងបំពាន។ ពលករខ្មែរជាច្រើនដែលកំពុងធ្វើការនៅប្រទេសកូរ៉េខាងត្បូង តែងតែប្រឈមការរើសអើង ការជេរប្រមាថ និងការរំលោភសិទ្ធិការងារផ្សេងៗ ពីថៅកែជនជាតិកូរ៉េខាងត្បូង។ ជាក់ស្តែង កាលពីថ្ងៃទី៩ មីនា មានម្ចាស់គណនីហ្វេសប៊ុកឈ្មោះ ប៉ា រតនា បានបង្ហោះវីឌីអូ (Video) បង្ហាញពីថៅកែស្រីជនជាតិកូរ៉េម្នាក់ បានយកប្រអប់បាយរបស់ស្ត្រីពលករខ្មែរម្នាក់ ឈ្មោះ ថៃ ស្រីឡែន ទៅបោះចោលតាមផ្លូវ និងបានប្រើពាក្យសំដីសម្លុត ចាប់អូសដៃ ស្តីបន្ទោសខ្លាំងៗនៅក្នុងកសិដ្ឋានរបស់ខ្លួន ដោយសារនាងមិនសូវយល់ការងារ។ បងប្រុសរបស់កញ្ញា ថៃ ស្រីឡែន និងជាពលករនៅកូរ៉េដែរនោះ គឺលោក ថៃ បូរី ឱ្យដឹងថា ប្អូនស្រីរបស់លោក ត្រូវបានថៅកែជនជាតិកូរ៉េស្តីបន្ទោសខ្លាំងៗ និងគំរាមបណ្តាញចេញពីការងារជាច្រើនលើកមកហើយ និងជូនកាលឈានដល់ការប្រើប្រាស់អំពើហិង្សាទៀតផងដោយថានាងធ្វើការមិនសូវបានល្អ។ លោកបន្តថាប្អូនរបស់លោកធ្វើការនៅទីក្រុងមីលយ៉ាំង(Miryang)ក្នុងចម្ការដាំស្លឹកគីនីត (Perilla leaves )។

លោក ថៃ បូរី សោកស្តាយនៅពេលឃើញប្អូនស្រីរបស់លោកត្រូវថៅកែធ្វើបាបហើយបែរជាមិនអាចជួយអ្វីបាន។ លោកបន្តថាប្អូនស្រីរបស់លោក មកធ្វើរយៈពេល៣ខែនេះមិនទាន់មាន កាតសំគាល់ខ្លួនដែលអាចដើរហើរ

បានដោយសេរីនៅឡើយទេ។ ម្យ៉ាងលោកថានៅពេលមានបញ្ហាកន្លែងធ្វើការងារម្តងៗ ប្អូនស្រីលោកតែងស្វែងរកកិច្ចអន្តរាគមន៍ពីស្ថានទូតខ្មែរប្រចាំប្រទេសកូរ៉េ ក៏ប៉ុន្តែមិនទទួលបានការឆ្លើយតបឡើយ ។ លោក ថៃ បូរី៖ «ខាងក្រសួងឬក៏ស្ថានទូតគួរតែយកចិត្តទុកចំពោះពលករចំណាកស្រុកពីព្រោះមិនត្រឹមតែប្រទេសកូរ៉េនៅប្រទេសនានាក៏រងសម្ពាធបែបនឹងដែល ប៉ុន្តែនេះនៅប្រទេសកូរ៉េសុំឱ្យស្ថានទូតកូរ៉េយកចិត្តទុកដាក់ចំពោះពលករ ដែលគ្នាមានបញ្ហាទី១ គឺ គ្នាខលទៅមិនរកដំណោះស្រាយឱ្យទេ ឱ្យយើងទ្រាំឱ្យសម្របសម្រួលពេលខ្លះដំណោះស្រាយឱ្យគ្នាសម្របសម្រួលគ្នាចង់តែស្រួលនឹងឯងប៉ុន្តែបើមានបញ្ហាឱ្យគ្នាស្រួលយ៉ាងម៉េច»។ មកទល់ពេលនេះ លោក ថៃ បូរី មិនទាន់ទទួលដំណឹងពីប្អូនស្រីរបស់ថាត្រូវថៅកែបណ្តេញចេញឬក៏បន្តធ្វើនៅកន្លែងដដែលនោះ ដោយសារគ្មានទូរស័ព្ទដើម្បីទំនាក់ទំនងគ្នា ចំណែកព័ត៌មានដែលលោកទទួលបាននោះគឺមិត្តរួមការងាររបស់ប្អូនលោកផ្ញើឱ្យ។

ទាក់ទិនរឿងនេះវិទ្យុអាស៊ីសេរីមិនអាចសុំការឆ្លើយតបពីមន្ត្រីស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ បានទេនៅថ្ងៃទី១០ មីនា ដោយទូរស័ព្ទហៅចូលពុំមានអ្នកទទួល។

ប្រធានអង្គការវេទិកាសន្តិភាពកម្ពុជានៅប្រទេសកូរ៉េ លោក ស សុខេម មានប្រសាសន៍ថា ស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េ គួរតែចុះត្រួតពិនិត្យកន្លែងធ្វើការរបស់ពលករ ដើម្បីអាចជួយដល់ពលករ ដែលត្រូវការជំនួយឱ្យបានទាន់ពេលវេលា។ លោកបន្តថា ប្រសិនជាស្ថានទូតមិនអើពើជាមួយពលករខ្មែរនោះទេ ពួកគេអាចប្រឈមនឹងការបាក់ទឹកចិត្ត ដោយសារមានថៅកែមួយចំនួនឆ្លៀតឱកាសកេងចំណេញកម្លាំងពលកម្មដោយមិនឱ្យឈប់សម្រាក និងការរំលោភបំពានសិទ្ធិផ្សេងៗ។ លោក ស សុខេម៖ «ខ្ញុំមិនត្រឹមតែថា កម្រទេ សឹងតែមិនដែលឃើញផងថា ជាវ៉ិបសៃត៍ (website) របស់ស្ថានទូត ដែលឃើញបើកបង្រៀនណែនាំប្រជាពលរដ្ឋខ្មែរអី វាអត់មាន។ មានតែអ្នកធម្មតាៗ ដែលគាត់បើកបង្រៀនលក់ដូរអីនាយអាយអ៊ីចឹងទៅ។ តែបើជាស្ថានទូត គឺមិនមានទេ»។

ពលករនៅកូរ៉េមួយចំនួន ឲ្យដឹងថា កន្លងមកមានពលករជាច្រើននាក់ត្រូវបានថៅកែគំរាមកំហែងប្រើហិង្សា ហើយជួនកាលឈានដល់ការបៀតបៀនផ្លូវភេទដែលផ្ទុយពីច្បាប់ការងារ ប៉ុន្តែពួកគេមិនអាចស្នើសុំកិច្ចអន្តរាគមន៍ពីមន្ត្រីស្ថានទូតកម្ពុជាបានឡើយ។ ពលករអះអាងថា មន្ត្រីស្ថានទូតទាំងនោះចុះទៅម្តងម្កាលដែរ ប៉ុន្តែមិនមែនចុះទៅដោះស្រាយបញ្ហាឱ្យពលករឡើយ ផ្ទុយវិញបែរជាបង្ខំសម្លុតពលករឱ្យសម្រួលជាមួយថៅកែ ហើយលុបរូបថត ឬវីឌីអូដែលថៅកែធ្វើបាបនោះចោល។

ស្ថានទូតខ្មែរប្រចាំប្រទេសមួយចំនួនដូចជា កូរ៉េ (S-Korea) ថៃ (Thai) និងម៉ាឡេស៊ី (Malaysia) ជាដើម រងការរិះគន់ជាយូរមកហើយថា អសកម្ម និងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ហើយតែងចុះ យកមុខមាត់ ឬចុះឃោសនាពង្រឹងនយោបាយឲ្យគណបក្សកាន់អំណាច ដោយមិនសូវយកចិត្តទុកដាក់អំពីសុខទុក្ខរបស់ពលកររស់នៅក្រៅប្រទេសដូចជាស្ថានទូតប្រទេសដទៃឡើយ។ របាយការណ៍ក្រសួងការងារ បង្ហាញថា មកទល់ពេលនេះ ពលករកម្ពុជា កំពុងធ្វើការនៅក្រៅប្រទេសជាង ១លាន ៣សែននាក់ (១.៣២១.៥០៦) ក្នុងនោះនៅប្រទេសកូរ៉េខាងត្បូងចំនួនជិត ៥ម៉ឺននាក់ (៤៩.៧៣៨) ។ ប៉ុន្តែរបាយការណ៍ពីអង្គការសង្គមស៊ីវិលមួយចំនួន បង្ហាញថា ពលករកម្ពុជានៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់អាចមានច្រើនជាងនេះ ដោយគ្រាន់តែនៅប្រទេសថៃមានជាង ២លាននាក់។ ថ្វីត្បិតតែរដ្ឋាភិបាល លោក ហ៊ុន សែន បង្ហាញមោទនភាពចំពោះការបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសកើនឡើងជាបន្តបន្ទាប់ក្តី ក៏ពលករខ្មែរជាច្រើន តែងត្អូញត្អែរពីបញ្ហាទុក្ខលំបាកជាច្រើនដែលពីថៅកែបរទេសធ្វើបាប ដូចជា ការរំលោភបំពានផ្លូវភេទ ការរើសអើង ការប្រើអំពើហិង្សា ការផ្តាច់ទំនាក់ទំនងជាមួយគ្រួសារ ការបណ្តេញចេញពីការងារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការមិនបើកប្រាក់ខែ និងមានពលករខ្លះទទួលរងការធ្វើបាបរហូតបាត់បង់ជីវិតទៀតផង៕

# ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិ.ង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

https://cen.com.kh/archives/632228.html Posted ByPen Srey NeatMarch 13, 2023

ភ្នំពេញ ៖ មន្ទីរកិច្ចការនារីរាជធានីភ្នំពេញ និងអង្គភាពការពារកុមារ សហការជាមួយរដ្ឋបាលខណ្ឌជ្រោយចង្វារនៅព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣នេះ បានបើកវគ្គអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារនិងកិច្ចកាពារជនរងគ្រោះ។ វគ្គអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់ អំពើហិ.ង្សាក្នុងគ្រួសារនិងកិច្ចកាពារជនរងគ្រោះ នៅថ្ងៃនេះមានការចូលរួម ពីសំណាក់តំណាងរដ្ឋបាលខណ្ឌជ្រោយចង្វារ និង លោកស្រី តំណាងក្រុមប្រឹក្សាខណ្ឌ រួមជាមួយ លោកស្រី សោម ម៉ានី អនុប្រធានមន្ទីរកិច្ចការនារីរាជធានីភ្នំពេញនិងតំណាងមកពីអង្គភាពការពារកុមារ។

លោកស្រីលីវ៉ូ ហ្សាមី អភិបាលរងខណ្ឌជ្រោយចង្វារ មានប្រសាសន៍ផ្តាំផ្ញើ នូវការសួរសុខទុក្ខពីសំណាក់លោកអភិបាលខណ្ឌ ចំពោះលោក លោកស្រី ជាមេភូមិ អនុប្រធានភូមិ មេប៉ុស្តិ៍ មេប៉ុស្តិ៍រង ក៏ដូចជាលោក-លោកស្រីចៅសង្កាត់រង មន្រ្តីនគរបាល មន្រ្តីកងរាជអាវុធហត្ថខណ្ឌផងដែរ ។ លោកស្រីអភិបាលរងខណ្ឌជ្រោយចង្វារ បានបញ្ជាក់ថា អំពើហិ.ង្សា ចែកជា៤ ប្រភេទរួមមាន អំពើហិ.ង្សាលើរាងកាយ ,អំពើហិ.ង្សាផ្លូវចិត្ត,អំពើហិ.ង្សាផ្លូវភេទ និងអំពើហិ.ង្សាផ្នែកសេដ្ឋកិច្ច ចំពោះអ្នកដែលប្រព្រឹត្តអំពើហិ.ង្សាទាំងនេះគឺជាសកម្មភាពល្មើសច្បាប់រដ្ឋ។ ទាក់ទងនិងកិច្ចការពារជនរងគ្រោះជាស្រ្តីនិងកុមារ គឺមន្រ្តីនគរបាលយុត្តិធម៌ នៅមូលដ្ឋានរួមមាន មន្រ្តីនគរបាលប៉ុស្តិ៍ មន្រ្តីកងរាជអាវុធហត្ថ និង មន្រ្តីសង្កាត់ មេភូមិ អនុភូមិនិងប្រជាពលរដ្ឋ មានសិទ្ធិចូលរួមការពារជនរងគ្រោះគ្រប់ តាមរយៈផ្តល់ព័ត៌មានទៅអាជ្ញាធរ មានសមត្ថកិច្ចនៅមូលដ្ឋានផ្ទាល់។

លោកស្រីលីវ៉ូ ហ្សាមី អភិបាលរងខណ្ឌបានបញ្ជាក់ថា បន្ទាប់ពីមានការអប់រំផ្សព្វផ្សាយច្បាប់ ពីសំណាក់ស្ថាប័នពាក់ព័ន្ធនិងអង្គការដៃគូ ប្រជាពលរដ្ឋ ជាពិសេសស្ត្រី ក៏ដូចជាកុមាររងគ្រោះ បានយល់ដឹងពីច្បាប់ ហ៊ានចេញមុខស្វែងរកវិធីសាស្រ្ត ឬអន្តរាគមន៍ប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬអ្នកជិតខាងឲ្យរកជំនួយផ្លូវច្បាប់ជួយដល់ពួកគាត់ជាអ្នករងគ្រោះ ឲ្យបានទាន់ពេលវេលា។ ក្នុងគោលបំណង ផ្សព្វផ្សាយច្បាប់បញ្ច្រាបការ យល់ដឹងនិង ដើម្បីឲ្យអ្នកចូលរួមទទួលបាននូវបរិបទថ្មី កែប្រែផ្នត់គំនិត អាកប្បកិរិយា ដល់ជនមុខសញ្ញាសម្របសម្រួលតាមវិធីសាស្រ្តទប់ទំហឹងព្រមទាំងបង្កើតកិច្ចសហការជួយអន្តរាគមន៍ ដល់ជនរងគ្រោះឲ្យកាន់តែមានប្រសិទ្ធភាព ពិសេសស្ត្រី កុមារ។

សូមបញ្ជាក់ថា ក្រោមកិច្ចសហការជាមួយអង្គភាពការពារកុមារ ជាដៃគូសហការល្អ មន្ទីរកិច្ចការនារី រាជធានីភ្នំពេញបានបើកវគ្គអប់រំផ្សព្វផ្សាយ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិ.ង្សាក្នុងគ្រួសារ និងកិច្ច ការពារជនរងគ្រោះ ច្បាប់ប្រឆាំងការជួញដូរមនុស្ស ។ល។ នៅតាមបណ្តាខណ្ឌទាំង១៤នៅរាជធានីភ្នំពេញ ដែលនេះជាគោលនយោបាយ ភូមិ- សង្កាត់ មានសុវត្ថិភាព ដែលរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញកន្លងមក ក្រោមការដឹកនាំប្រកប ដោយភាពឈ្លាសវៃ និងប៉ិនប្រសព្វរបស់មគ្គុទេសក៍ គឺសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណា ចក្រកម្ពុជា ៕ រក្សាសិទ្ធិដោយ ៖ សុវណ្ណារិទ្ធ

# ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០២៣

## សម្តេច ស ខេង ណែនាំពលរដ្ឋ ចូលរួមប្រយុទ្ធប្រឆាំង អំពើជួញដូរគ្រប់ទម្រង់ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស

https://dap-news.com/national/2023/03/14/318712/ ByPH104Posted on March 14, 2023

**ភ្នំពេញ ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំប្រជាពលរដ្ឋទាំងអស់ ចូលរួមប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស ដោយសហការជាមួយកម្លាំង សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ក្រាប និងទប់ស្កាត់ទាន់ពេលវេលា។

ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសមិទ្ធផលនានា នៅវត្តមេលប់ ស្ថិតនៅភូមិមេលប់ ឃុំកា ស្រុកពារាំង ខេត្តព្រៃវែង នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ សម្តេច ស ខេង បានថ្លែងថា «ស្នើប្រជាពលរដ្ឋទាំងអស់ ចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស ដោយសហការយ៉ាងមានប្រសិទ្ធភាពជាមួយកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ក្រាបនឹងទប់ស្កាត់បានទាន់ពេលវេលា»។ សម្តេច បន្តថា ទន្ទឹងនឹងនេះ ពលរដ្ឋ ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣កុំ ៣ការពារ និងជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញ ឲ្យបានគ្រប់ៗគ្នា ដើម្បីបង្ការ ដើម្បីទប់ស្កាត់ការផ្ទុះឆ្លងរាតត្បាតឡើងវិញក្នុងសហគមន៍ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងសកម្មភាពសេដ្ឋកិច្ច សង្គម ដែលកំពុងដំណើរការពេញលេញ ក្នុងពេលបច្ចុប្បន្ននេះ»។

សម្តេច ស ខេង ក៏បានលើកទឹកចិត្តអាជ្ញាធរ ជំរុញសកម្មភាពត្រួតពិនិត្យ និងផ្សព្វផ្សាយអប់រំដល់យុវជន អំពីការជួញដូរ និងប្រើប្រាស់គ្រឿងញៀន តាមគោលការណ៍ «បីកុំ មួយរាយការណ៍» គឺកុំពាក់ព័ន្ធ៖ កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិត និងកុំប្រើប្រាស់គ្រឿងញៀន។ លើសពីនេះ សម្តេច ឧបនាយករដ្ឋមន្ត្រី បានណែនាំអាជ្ញាធរមានសមត្ថកិច្ច កងកំលាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់ ត្រូវរួមគ្នាដើម្បីការពារសន្តិភាព ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព និងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកអោយបានខ្ជាប់ខ្ជួន ស្របតាមពាក្យស្លោករបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី «ថ្ងៃនេះ ថ្ងៃស្អែក កុំអោយមាន គ្រោះថ្នាក់ចរាចរណ៍»៕

## ពីរនាក់ប្តី-ប្រពន្ធបើកហាងខារ៉ាអូខេ បែកគំនិតបង្ខំឱ្យយុវតីក្នុងហាងបម្រើផ្លូវភេទជាមួយភ្ញៀវ ត្រូវបានតុលាការឃុំខ្លួនជាបណ្តោះអាសន្ន

https://cen.com.kh/archives/632287.html Posted ByPen Srey NeatMarch 13, 2023

ខេត្តកណ្តាល៖ បុរសស្ត្រីពីរនាក់ប្តី-ប្រពន្ធ ជាម្ចាស់ហាងខាងរ៉ាអូខេមួយកន្លែង ត្រូវបានចៅក្រមសាលាដំបូងខេត្តកណ្តាល បង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្ន កាលពីល្ងាចថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ពាក់ព័ន្ធនឹងសញ្ញកម្មអនីតិជិជន, ការឃុំខ្លួននេះធ្វើឡើងបន្ទាប់ពីកម្លាំងប៉ុស្តិ៍នគរបាលឃុំជ្រៃលាស់ ឃាត់ខ្លួនកាលពីព្រឹកថ្ងៃសៅរ៍ចុងសប្តាហ៍មុននេះ ពាក់ព័ន្ធបង្ខំឱ្យយុវតីបម្រើការងារក្នុងហាង បម្រើផ្លូវភេទជាមួយភ្ញៀវ ដោយបង្ខាំងបង្ខំ។ ជនសង្ស័យពីរនាក់ប្តី-ប្រពន្ធដែលឃាត់ខ្លួននេះ មានឈ្មោះ ជុំ ជឿន ភេទ ប្រុស អាយុ៤៤ និងប្រពន្ធឈ្មោះ ធិន សុខន អាយុ៣៩ ឆ្នាំ ជាថៅកែហាងផឹកស៊ី និងខារ៉ាអូខេ បឹងលាភ168 ស្ថិតនៅក្នុងភូមិទួលព្រិច ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល។

នារីរងគ្រោះមានគ្នា ៣នាក់ រួមមាន ទី១ ឈ្មោះ ក.ឈ.អ ភេទស្រី អាយុ១៤ឆ្នាំ មានស្រុកកំណើត ភូមិកន្ទួតកោងកាង ឃុំថ្នល់ថ្មី ស្រុកពញាក្រែក ខេត្តកំពង់ចាម, ទី២-ឈ្មោះ វ.ស.ន ភេទស្រី អាយុ១៤ឆ្នាំ ស្រុកកំណើតភូមិ៣៨ ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល, និងទី៣-ឈ្មោះ ឡ. ស.ផ ហៅ ភេទស្រី អាយុ២១ឆ្នាំ ស្រុកកំណើតភូមិស្រែក្រសាំង ឃុំពពក ស្រុក ស្ទោង ខេត្តកំពង់ធំ។

លោកវរៈសេនីយ៍ឯក រស់ សារិន នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីជន ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល ឱ្យដឹងថា អាយុវតីក្មេងៗខាងលើ គឺពួកនាងទើបមកបម្រើការងារនៅក្នុងហាងខារ៉ាអូខេនេះថ្មីៗតែប៉ុណ្ណោះ ថៅកែបើកប្រាក់ខែឱ្យមិនគ្រប់ ហើយថែមទាំងជេរប្រមាថ បៀតបៀនកេរ្តិ៍ខ្មាស បង្ខំបម្រើផ្លូវភេទ ជួញដូរផ្លូវភេទ បំបិទសិទ្ធិមិនឱ្យចេញក្រៅហាង និងចុងក្រោយបញ្ឈប់ពួកនាងដោយមិនបើកប្រាក់ខែឱ្យថែមទៀត។ នារីខារ៉ាអូខេទាំងបីនាក់ខាងលើ និយាយដូចៗគ្នាថា កាលពីពេលថ្មីៗនេះ ពូនាងទាំងបីនាក់រួមនឹងមេការម្នាក់ បានសុំច្បាប់ទៅចូលរួមបុណ្យសាច់ញាតិ១ថ្ងៃ ប៉ុន្តែ ថៅកែស្រី មិនឱ្យទៅ តែពួកនាងនៅតែនាំគ្នាទៅ។ លុះត្រឡប់មកវិញសុំថៅកែបើកប្រាក់ខែ ថៅកែមិនបើកឱ្យ ហើយថែមទាំងជេរប្រមាថ និងពន្យុះឱ្យពួកនាងទៅប្ដឹងដល់ណាក៏ប្ដឹងទៅទៀតផង ទើបពួកនាងនាំគ្នាទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំជ្រៃលាស់តែម្ដង។

យ៉ាងណាក៏ដោយ ក្រោយការស្រាវជ្រាវ ព្រះរាជអាជ្ញាសាលាដំបូងខេត្តកណ្ដាល បានការធ្វើការចោទប្រកាន់ ពី បទ "ផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារកុមារ" , បន្ទាប់មកលោកចៅក្រម នៅល្ងាចថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២៣ បានបង្គាប់ឱ្យឃុំខ្លួនថៅកែហាង២នាក់ប្ដី-ប្រពន្ធនេះ ដាក់ពន្ធនាគារខេត្តកណ្ដាលជាបណ្ដោះអាសន្ន រង់ចាំនីតិវិធីបន្ត៕ រក្សាសិទ្ធិដោយ ៖ ឈុនហ៊ាត

## ពលករខ្មែរប្រុសស្រី៧នាក់ បម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ

https://kohsantepheapdaily.com.kh/article/1701149.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ១៣ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ១០:២២

ខេត្តបន្ទាយមានជ័យ ៖ ពលករប្រុសស្រីចំនួន៧នាក់ ដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ បានត្រូវសមត្ថកិច្ចចាប់ឃាត់កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣កន្លងទៅ នៅក្បែរព្រំដែនក្នុងភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

លោកវរសេនីយ៍ត្រី ពៅ រតនា នាយប៉ុស្ដិ៍នគរបាលម៉ាឡៃ បានឱ្យដឹងថា នៅពេលកងកម្លាំងចេញល្បាត ក៏ប្រទះឃើញពលករទាំង៧នាក់ក្នុងនោះស្ត្រី៣នាក់ ដែលមានសម្ភារៈនិងខោអាវ ក្នុងបំណងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ក៏បានចាប់ឃាត់នាំយកមកប៉ុស្ដិ៍ដើម្បីសាកសួរ ។

លោកវរសេនីយ៍ត្រី លី ស៊ាងយ៉ាង មេបញ្ជាការរងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ថ្លែងថា នៅពេលសាកសួរត្រូវបានប្រាប់ថា ពួកគាត់មានបំណងឆ្លងដែនទៅប្រទេសថៃ ដើម្បីរកការងារធ្វើ តាមរយៈមេខ្យល់ក្នុង១នាក់៥.០០០បាត ទៅ៦.០០០បាត ដោយឱ្យលុយមុន ទើបគេជូនទៅរកការងារធ្វើដល់កន្លែងតែនៅពេលជូនដល់ព្រំដែន ក៏ត្រូវបានកម្លាំងសមត្ថកិច្ចចាប់ឃាត់។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ថ្លែងថា ក្រោយពីចាប់ឃាត់និងសាកសួរពួកគាត់ប្រាប់ថា មកពីខេត្តកំពត១នាក់ ខេត្តបាត់ដំបង២នាក់ ខេត្តកំពង់ចាម៣នាក់ ខេត្តបន្ទាយមានជ័យ១នាក់ ។ បន្ទាប់ពីសាកសួររួច ក៏បានធ្វើកិច្ចសន្យា ហើយឱ្យត្រឡប់ទៅស្រុកកំណើតវិញ និងព្រមានថា បើចាប់បានលើកក្រោយនឹងមានវិធានការតាមច្បាប់ ។ ចំណែកមេខ្យល់ សមត្ថកិច្ចកំពុងស្រាវជ្រាវចាប់ខ្លួនចាត់ការតាមច្បាប់ ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣នាក់

https://freshnewsasia.com/index.php/en/localnews/282122-2023-03-13-14-28-43.html 2023-03-13 09:28pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៨៦ករណី មានមនុស្ស ១,៩៩១នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៥៨សំណើ និងបិទសំណុំរឿង ២៥៨សំណើ (រកឃើញមនុស្ស ១,១៦៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៤នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៨ករណី៕

# ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២៣

## គិតត្រឹមថ្ងៃទី១៥ ខែមីនា សមត្ថកិច្ចកម្ពុជា ទទួលបានបណ្តឹង ៧៨៦បណ្តឹង ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១,៩៩១នាក់

https://freshnewsasia.com/index.php/en/localnews/282397-2023-03-16-04-27-59.html 2023-03-16 11:27am

**(ភ្នំពេញ)៖** គិតមកដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ៧៨៦ករណី ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១,៩៩១នាក់ មាន១៦សញ្ជាតិ។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៦៣សំណើ និងបិទសំណុំរឿង ២៥៩សំណើ (រកឃើញមនុស្ស ១,១៧៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៤នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**២៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៣ករណី៕

## ជប៉ុន បន្តផ្តល់ឱកាសដល់ប្រជា ពលរដ្ឋកម្ពុជាទៅបំពេញការងារនៅប្រទេសរបស់ខ្លួន

https://www.information.gov.kh/articles/99718 ចេញផ្សាយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២៣ វិទ្យុជាតិកម្ពុជា

ភ្នំពេញ៖រដ្ឋាភិបាលជប៉ុន បានបន្តផ្តល់ឱកាសដល់ប្រជាពលរដ្ឋកម្ពុជាបានទៅបំពេញការងារនៅប្រទេសរបស់ខ្លួន ជាពិសេសបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែជិត ស្និទ្ធលើការបណ្តុះបណ្តាលបច្ចេក ទេសនិងវិជ្ជាជីវៈ និងគម្រោងសុខ ភាពបន្តពូជសម្រាប់កម្មការិនីក្នុង វិស័យកាត់ដេរ។ ក្នុងជំនួបសំដែងការគួរសម និងពិភាក្សាការងារវវាង ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា នៅទីស្តីការក្រសួង នាព្រឹកថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០២៣ថា ពាក់ព័ន្ធនឹងកម្ម សិក្សាការី និងប្រព័ន្ធបញ្ជូន ភាគីទាំងពីរនឹងបន្តពង្រឹងការគ្រប់គ្រងឱ្យកាន់តែប្រសើរថែមទៀត ដើម្បីបន្តផ្តល់ឱកាសដល់ប្រជាពលរដ្ឋកម្ពុជា បានទៅបំពេញការងារជាកម្មសិក្សាការី និងជាពលករ ហើយពេលដែលពួកគេត្រឡប់មកកម្ពុជាវិញ យកចំណេះដឹង និងជំនាញរបស់ពួកគេមកចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ទាក់ ទាញអ្នកវិនិយោគទុនជប៉ុនកាន់តែច្រើនទៀតមកកម្ពុជា។

ជាពិសេសភាគីទាំងពីរបានសំដែងនូវការពេញ ចិត្ត នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែជិតស្និទ្ធថែមទៀតលើការជួយកែលម្អវគ្គបណ្តុះបណ្តាល ការបំពាក់សម្ភារៈសិក្សាតាមគ្រឹះ ស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការបញ្ជូនអ្នកជំនាញឯកទេសជនជាតិជប៉ុន ក្រោមគម្រោង JICA។ បន្ថែមពីនេះ ភាគីទាំងពីរនឹងបន្តកិច្ចសហប្រតិបត្តិការលើគម្រោង ២ទៀត គឺទី១ គម្រោងជួយធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនៃកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជាគម្រោងអាស៊ាន/ជប៉ុន និងទី២ គម្រោងសុខភាពបន្តពូជសម្រាប់កម្មការិនីក្នុងវិស័យកាត់ដេរ៕

# ថ្ងៃទី២០ ខែ មីនា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៦នាក់

https://freshnewsasia.com/index.php/en/localnews/282575-2023-03-17-08-38-41.html 2023-03-17 03:38pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៥ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៦នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៨៦ករណី មានមនុស្ស ១,៩៩១នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៦៦សំណើ និងបិទសំណុំរឿង ២៥៩សំណើ (រកឃើញមនុស្ស ១,១៧០នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២០ករណី៕

# តុលាការកំពូលជម្រះបណ្ដឹងសាទុក្ខ ប្ដីប្រពន្ធបង់ក្លាដេស-ខ្មែរម្នាក់ ពាក់ព័ន្ធការរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់ មកធ្វើការនៅកម្ពុជា

https://cen.com.kh/archives/635213.html Posted ByPen Srey NeatMarch 17, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២៣នេះ បានធ្វើការ ជំនុំជម្រះលើបណ្ដឹងសាទុក្ខរបស់បុរស ជនជាតិបង់ក្លាដេសម្នាក់ និង ស្ត្រីខ្មែរម្នាក់ ដែលជាប្ដីប្រពន្ធនឹងគ្នា ដែលជាប់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធ ពលករជនជាតិ បង់ក្លាដេស ចំនួន១៦ នាក់ ឆ្លងដែនខុសច្បាប់ មកធ្វើការក្នុងប្រទេសកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ២០២០។

លោក សឹង បញ្ញាវុឌ្ឍ ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទ២នាក់ ខាងលើមាន ឈ្មោះ ៖ ១- ឈ្មោះ ម៉ម សុខុម ភេទស្រី អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ ។ ២- ឈ្មោះ MOHAMMED JAHANGIA ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិបង់ក្លាដេស មានមុខរបរមុនចាប់ខ្លួន ជានាយកក្រុមហ៊ុន CEB BIC CIES CO,Lld ។ ពួកគេទាំង២ នាក់ គឺ ត្រូវជាប្ដីប្រពន្ធនឹងគ្នា និង មានទីលំនៅមុនចាប់ខ្លួន ផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្មគោល២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ផ្ដន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ : លក់ដូរមនុស្សសម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ៨ និង មាត្រា ១២ នៃ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ។

ពួកគេ ប្ដឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍ រាជធានីភ្នំពេញ បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល ។ ពួកគេ ក៏បានបន្តប្ដឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៣០ខែ កក្កដា ឆ្នាំ ២០២១ នៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

សំណុំរឿងក្ដីនេះ, តុលាការកំពូលបានលើកពេល ប្រកាសសាលដីកា នៅព្រឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២៣ ខាងមុខ នេះ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

# ក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែង ប្រជុំរៀបចំកម្មវិធីជួបសំណេះសំណាលជាមួយកម្មករ ពលករចំណាកស្រុក ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ

https://freshnewsasia.com/index.php/en/localnews/282583-2023-03-17-09-04-12.html 2023-03-17 04:04pm

**(ភ្នំពេញ)៖** លោក ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែង បានដឹកនាំកិច្ចប្រជុំត្រៀមសម្រាប់ការជួបសំណេះសំណាល ជាមួយបងប្អូនកម្មករ ពលករចំណាកស្រុក ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នាពេលខាងមុខ។ កិច្ចប្រជុំនេះ បានប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៣ នៅសាលប្រជុំក្រសួងមុខងារសាធារណៈ ដោយមានការអញ្ជើញចូលរួមពីលោកលោកស្រីជាប្រធាន អនុប្រធាន សមាជិកនិងក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែងសរុបចំនួនជិត៦០នាក់។

បន្ទាប់ពីលោក ទេព ភារុន អនុប្រធានលេខាធិការដ្ឋានក្រុមការងារកម្មករ ពលករចំណាកស្រុកនៃខេត្តព្រៃវែង អានសេចក្ដីណែនាំស្ដីពីកម្មវិធី និងខ្លឹមសារនៃគម្រោងជំនួបសំណេះសំណាលជាមួយកម្មករ ពលករចំណាកស្រុកនេះរួចមក លោករដ្ឋមន្ត្រី ព្រុំ សុខា បានស្នើឱ្យក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែង ម្ចាស់ការរៀបចំកម្មវិធីជួបសំណេះសំណាលនេះ នៅតាមភូមិ ឃុំ និងស្រុក នៅពេលដែលកម្មករ និងពលករចំណាកស្រុក

វិលត្រឡប់ទៅលេងស្រុកកំណើតវិញ នៅក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនាពេលខាងមុខ។ លោករដ្ឋមន្ត្រីប្រធានក្រុមការងារបានផ្តាំផ្ញើជាពិសេសដល់ក្រុមការងារត្រូវចុះជួបសួរសុខទុក្ខកម្មករ ពលករចំណាកស្រុកដោយផ្ទាល់នៅតាមខ្នងផ្ទះតែម្តង។

ក្នុងឱកាសនោះដែរ លោករដ្ឋមន្ត្រី ព្រុំ សុខា ប្រធានក្រុមការងារកម្មករ ពលករចំណាកស្រុកនៃខេត្តព្រៃវែង បានថ្លែងមតិរំលឹកពីការចូលរួមចំណែកផ្នែកសេដ្ឋកិច្ច នយោបាយ របស់កម្មករចំណាកស្រុករយៈពេលកន្លងមក ពិសេសការលើកស្ទួយជីវភាពរបស់ក្រុមញាតិគ្រួសារ ការចូលរួមប្រយុទ្ធគ្រប់គ្រងកូវីដ និងការបោះឆ្នោតឃុំសង្កាត់ ជូនគណបក្សប្រជាជនកម្ពុជាបានទទួលជ័យជំនះដ៏ត្រចះត្រចង់នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២។ សម្រាប់ការបោះឆ្នោតជាតិ ក្រុមការងារគ្រប់ថ្នាក់ត្រូវផ្សារភ្ជាប់ជាប្រចាំជាមួយបងប្អូនកម្មករ ពលករចំណាកស្រុក ដើម្បីពង្រឹងជំនឿជាក់ និងក្តីស្រលាញ់ដោយបេះដូងរបស់បងប្អូនមកលើគណបក្សប្រជាជនកម្ពុជា និងបន្តបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ឱ្យឈ្នះរៀងរហូត ដើម្បីសុខសន្តិភាព វឌ្ឍនភាព វិបុលភាព របស់មាតុភូមិ និងប្រជាជនយើង។

សូមជម្រាបជូនថា ក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែង ត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០១៧។ ខេត្តព្រៃវែង មានកម្មករ ពលករចំណាកស្រុកសរុបចំនួន១៨៩.២៧៦នាក់ ស្រី១០១.១៤៧នាក់ ក្នុងនោះមានកម្មករ ពលករចំណាកស្រុកក្នុងប្រទេសចំនួន ១៦៨.១០០នាក់ ស្រី ៩២.៥០៣នាក់ និងកម្មករ ពលករចំណាកស្រុកក្រៅប្រទេសចំនួន ២១.១៧៦នាក់ ស្រី ៨.៦៤៤នាក់៕

## ការិយាល័យស៊ើបអង្កេតជាតិហ្វីលីពីនចាប់ខ្លួន "អ្នកជួញដូរជនជាតិហ្វីលីពីនមកកម្ពុជា"

https://www.khmertimeskh.com/501257509//?p=1257509 Khmer Times March 18, 2023

អ្នកជ្រើសរើសពលករខុសច្បាប់ម្នាក់ត្រូវបានចាប់ខ្លួនដោយការិយាល័យស៊ើបអង្កេតជាតិ (NBI) នៅអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino (NAIA) ពីបទជាប់ពាក់ព័ន្ធក្នុងការជួញដូរជនជាតិហ្វីលីពីនមកកម្ពុជា។ NBI បានកំណត់អត្តសញ្ញាណជននោះថាជា Mona Almerah Kozay ដែលត្រូវបានស្ទាក់ចាប់ដោយមន្ត្រីអន្តោប្រវេសន៍ជាមួយនឹងជនរងគ្រោះពីការជួញដូររបស់នាងនៅស្ថានីយ NAIA Terminal 1 ។ NBI បាននិយាយក្នុងសេចក្តីថ្លែងការណ៍មួយថា "បន្ទាប់ពីការស៊ើបអង្កេត NBI-NAIA បានចាប់ខ្លួន Kozay ហើយត្រូវបាននាំខ្លួនសម្រាប់ដំណើរការសាកសួរនៅថ្ងៃទី៣ ខែមីនាឆ្នាំ២០២៣ នៅចំពោះមុខព្រះរាជអាជ្ញានៃទីក្រុង Pasay ចំពោះការបំពានលើផ្នែកទី 4-A (ការប៉ុនប៉ងជួញដូរមនុស្ស) នៃច្បាប់សាធារណរដ្ឋលេខ 9208 ដូចដែលបានធ្វើវិសោធនកម្ម និងការបំពានលើចំនុច R.A. 8042 (ការជ្រើសរើសបុគ្គលិកខុសច្បាប់លក្ខណៈទ្រង់ទ្រាយធំ)" ។

មុនពេលចាប់ខ្លួន Kozay NBIបានទទួលព័ត៌មានថា "មនុស្សមួយចំនួនហៀបនឹងចាកចេញនៅស្ថានីយ NAIA Terminal 1 ឆ្ពោះទៅប្រទេសសិង្ហបុរី ប៉ុន្តែជាក់ស្តែងឆ្ពោះទៅប្រទេសកម្ពុជាក្នុងគោលបំណងធ្វើការងារនៅកន្លែងល្បែងស៊ីសងក្រៅប្រទេស" ។ វាបាននិយាយថា "ព័ត៌មានត្រូវបានបញ្ជូនបន្តទៅការិយាល័យអន្តោប្រវេសន៍ (BI) ដើម្បីជូនដំណឹងដល់បុគ្គលទាំងនោះ" ។ មន្ត្រីអន្តោប្រវេសន៍នៅអាកាសយានដ្ឋានអន្តរជាតិ Ninoy Aquino Terminal 1 បានស្ទាក់ចាប់ក្រុម និងរារាំងពួកគេមិនឱ្យចាកចេញពីប្រទេស។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ជាមួយក្រុមនោះត្រូវបានចាប់ខ្លួនបញ្ជូនទៅភ្នាក់ងារ NBI ដែលនាំនាងទៅកាន់ការិយាល័យព្រះរាជអាជ្ញាក្រុង Pasay ដើម្បីធ្វើការសាកសួរ។ វាបានបន្ថែមថា "នៅពេលដែលបុគ្គលទាំងនោះមកដល់ស្ថានីយ NAIA 1 មន្ត្រី BI បានបដិសេធការចាកចេញរបស់ពួកគេ ហើយរួមជាមួយអ្នករត់ការរបស់ពួកគេឈ្មោះ Kozay ពួកគេត្រូវបានប្រគល់ឱ្យ NBI-IAID (ផ្នែកស៊ើបអង្កេតអាកាសយានដ្ឋានអន្តរជាតិ)" ។ *Manila Bulletin/Manila Times*

# រដ្ឋាភិបាលបង្ការ
# មិនឱ្យមានការប្រើប្រាស់ពលកម្មដោយបង្ខំក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា

https://www.kampucheathmey.com/local-news/481155 ថ្ងៃអាទិត្យ ១៩ មីនា ២០២៣ដោយ Sophal Tuon

មន្ត្រីក្រសួងពាណិជ្ជកម្ម បានប្រាប់សមាគមសម្លៀកបំពាក់-ស្បែកជើងអាមេរិក និងក្រុមហ៊ុន VF Corporation ថា រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្ការមិនឱ្យមានការប្រើ ប្រាស់ពលកម្ម ដោយបង្ខំនៅ កម្ពុជានោះទេ។ នៅក្នុងកិច្ចប្រជុំរវាងគណៈកម្មការគ្រប់គ្រងកិច្ចសន្យាជួលផលិតបន្ត ក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង ជាមួយសមាគមសម្លៀកបំពាក់-ស្បែកជើងអាម៉េរិក និងក្រុមហ៊ុន VF Corporation ដែលចេញផ្សាយ នៅរសៀលថ្ងៃទី ១៨ មីនា លោក សុខ សុភ័ក្រ្ត រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការគ្រប់ គ្រងកិច្ចសន្យាជួលផលិតបន្តក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង បានមានប្រសាសន៍ថា រាជរដ្ឋាភិបាល កម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្ការមិនឱ្យមានការប្រើប្រាស់ពលកម្ម ដោយបង្ខំនៅកម្ពុជា ហើយក៏បានយកចិត្តទុកដាក់ផងដែរ ចំពោះការព្រួយបារម្ភរបស់សមាគម AAFA និង VF Corporation ដែល សង្ស័យថា មានការប្រើប្រាស់ពលកម្ម ដោយបង្ខំនៅកម្ពុជា ដើម្បីផលិតទំនិញនាំចេញ តាមរយៈការរៀបចំឱ្យមាន គណៈកម្មការអន្តរក្រសួងតាំងពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១កន្លងទៅ ហើយបានកែសម្រួលសមាសភាពគណៈកម្មការ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ ដោយពង្រីកវិសាលភាពការងារ និងបន្ថែមសមាជិកជាន់ខ្ពស់ មកពីក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបើកការស៊ើបអង្កេតជាពិសេស លើករណីសង្ស័យថាមានការប្រើប្រាស់ពលកម្មដោយបង្ខំ ដែលផ្ទុយនឹងមាត្រាច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ លោកប្រធានគណៈកម្មការ ក៏បានគូសបញ្ជាក់ផងដែរអំពីកាតព្វកិច្ចដែលកម្ពុជាត្រូវអនុវត្តក្រោមច្បាប់របស់ជាតិ និងច្បាប់អន្តរជាតិ ព្រមទាំងបានពន្យល់លម្អិតអំពីលទ្ធផលនៃការស៊ើបអង្កេត និងវិធានការដែលបានដាក់ចេញដោយគណៈកម្មការអន្តរក្រសួងលើក្រុមហ៊ុ នដែលមានការពាក់ព័ន្ធដោយយោងតាមប្រកាសអន្តរក្រសួងលេខ ពិសេសអន្តរស្ថាប័ន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ស្តីពីការហាមឃាត់ការប្រើប្រាស់ពលកម្មជនជាប់ឃុំក្នុងពន្ធនាគារដើម្បីផលិតទំនិញនាំចេញ។ ក្នុងនោះដែរ គណៈកម្មការបាន និងកំពុងបន្តធ្វើការផ្សព្វផ្សាយអំពីបទប្បញ្ញត្តិជាតិ និងអន្តរជាតិទាក់ទងនឹងការប្រើប្រាស់ពលកម្មដោយបង្ខំ ជូនដល់បណ្តារោងចក្រ-សហគ្រាស សំដៅដើម្បីជៀសវាងការអនុវត្តខុសគោលការច្បាប់ដោយវិស័យឯកជន ដែលជាហេតុនាំឱ្យមានការផាកពិន័យ, ការដាប់ទោសទណ្ឌ, ខូចខាតដល់ផលប្រយោជន៍រោងចក្រ-សហគ្រាស និងកិត្តិនាមកម្ពុជាផងដែរ។ បន្ថែមលើនេះ លោកប្រធានគណៈកម្មការ បានបន្តទៀតថា កម្ពុជានឹងរៀបចំជាអនុក្រឹត្យ ដើម្បីកែលម្អយន្តការដែលមានស្រាប់ ដោយបន្ថែមនូវនីតិវិធីលម្អិត យន្តការគ្រប់គ្រងជាអចិន្ត្រៃយ៍ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនពាក់ព័ន្ធជាពិសេសអ្នកចុះកិច្ចសន្យាជួលផលិតបន្តច្រើនជាន់ថ្នាក់ (Sub and Sub-contract) ដោយកំណត់ឱ្យបានច្បាស់លាស់ និងញែកឱ្យដាច់រវាងកម្មវិធីស្តារនីតិសម្បទាទណ្ឌិត ជាមួយនឹងការចុះកិច្ចសន្យាជួលផលិតបន្តដើម្បីធ្វើពាណិជ្ជកម្ម ។

ជាការឆ្លើយតប សមាគម AAFA និង VF Corporation សម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា និងស្នើឱ្យគណៈកម្មការបន្តស៊ើបអង្កេតបន្ថែមទៀតលើក្រុមហ៊ុនពាក់ព័ន្ធ ជាបន្តទៀត ដោយ AAFA និង VF Corporation នឹងសហការផ្តល់ព័ត៌មានបន្ថែមក្នុងករណីចាំបាច់ ដើម្បីការពារដល់កេរ្តិ៍ឈ្មោះផលិតផលរបស់កម្ពុជា៕ អត្ថបទ៖ សំអឿន

# ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០២៣

## ស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាល ទប់ស្កាត់អំពើជួញដូរមនុស្សឆ្លងដែន

http://nokorwatnews.com/archives/979059 20/03/2023

ខេត្តបន្ទាយមានជ័យ៖ នៅព្រឹកថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៣ នេះ នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បាន បើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សឆ្លងដែន ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេតប្រមូលភស្តុតាង និងបង្ក្រាបករណីជួញដូរមនុស្ស រយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាព លោក ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ លោក នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ។

ការបើកវគ្គខាងលើមានការចូលរួមពីលោក លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ ស្នងការរង លោកនាយការិយាល័យ លោក Damian Robustelli នាយកប្រចាំតំបន់អាស៊ី នៃអង្គការ OPERATION UNDERGROUND RAILROAD នាយការិយាល័យ និងសិក្ខាកាម មកពី អធិការដ្ឋាននគរបាលស្រុកក្រុងទាំង៩ បញ្ជាការវរទាំង៤ និងសិក្ខាក្នុងស្នងការដ្ឋានជាច្រើនរូប ។

លោក ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិបានមានប្រសាសន៍ថា ការបង្កើនវគ្គបណ្តុះបណ្តាលគឺជាការចាំបាច់ ហើយជាតម្រូវការដល់សមត្ថកិច្ចដែលជាមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធនៅក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងកង្វល់របស់ប្រជាពលរដ្ឋ ហើយការបើកវគ្គបណ្តុះបណ្តាលនេះយើងអាចចែករំលែក និងបទពិសោធន៍ចំណេះដឹងពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ ក្រៅប្រពន្ធ័អនឡាញ និងអំពើជួញដូរមនុស្សតាមរូបភាពកេងប្រវ័ញ្ចពលកម្ម ក៏ដូចជាអំពើជួញដូរមនុស្សតាមរូបភាពផ្សេងៗគ្នា និងមានទម្រង់ពាកព័ន្ធជាច្រើនទៀត ដែលយើងត្រូវរួមគ្នាដឹង រួមគ្នាបង្ការទប់ស្កាត់ និងបង្ក្រាបផងដែរ ៕

# ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០២៣

## កម្ពុជា-ឡាវ បង្កើនកិច្ចសហការបង្ក្រាប បទល្មើស រត់ពន្ធជួញដូរមនុស្ស និងគ្រឿងញៀន

https://dap-news.com/national/2023/03/21/320151/ ByPH104Posted on March 21, 2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា និងនាយឧត្តមសេនីយ៍ វិល័យ ឡាខាំហ្វង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសន្តិសុខឡាវ បានប្តេជ្ញាបង្កើនកិច្ចសហការផ្លាស់ប្តូរព័ត៌មានទាន់ពេលវេលា ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ឆ្លងដែនគ្រប់ប្រភេទ ជាពិសេស អំពើរត់ពន្ធជួញដូរមនុស្សឆ្លងដែន ឬសកម្មភាពជួញដូរ និងដឹកជញ្ជូនគ្រឿងញៀន ។

យោងតាមសេចក្តីប្រកាស ព័ត៌មានរបស់ក្រសួងមហាផ្ទៃ បានឱ្យដឹងថា ក្នុងស្មារតីបន្តលើកកម្ពស់កិច្ច សហប្រតិបត្តិការអនុវត្តច្បាប់រវាងភាគីទាំងពីរ ជាពិសេស កិច្ចសហប្រតិបត្តិការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម សម្តេច ស ខេង និង នាយឧត្តមសេនីយ៍ វិល័យ ឡាខាំហ្វង បានចុះហត្ថលេខា លើកំណត់ហេតុ ស្តីពីកិច្ចសហប្រតិបត្តិការ ឆ្នាំ២០២៣ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាឡាវ និងបានឯកភាព យកចិត្តទុកដាក់អនុវត្តកិច្ចការសំខាន់ៗមួយចំនួន រួមមាន៖ បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរខេត្តជាប់ព្រំដែន និងកងកម្លាំងអនុវត្តច្បាប់នៃ ភាគីទាំងពីរ សំដៅរួមគ្នាថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និង សុវត្ថិភាពសង្គម

ព្រមទាំងសហការ បង្កលក្ខណៈសមស្រប ដល់ពលរដ្ឋចេញ-ចូលស្របច្បាប់តាមច្រកទ្វារព្រំដែន ដើម្បីធ្វើធុរកិច្ច ទេសចរណ៍ និងសួរសុខទុក្ខគ្រួសារ រួមចំណែកជំរុញការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ។

លើសពីនេះ ភាគីទាំងពីរ បង្កើនកិច្ចសហការផ្លាស់ប្តូរព័ត៌មានទាន់ពេលវេលា ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ឆ្លងដែនគ្រប់ប្រភេទ ជាពិសេស អំពើរត់ពន្ធ-ជួញដូរមនុស្សឆ្លងដែន សកម្មភាពជួញដូរ និងដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ដែលកើតមាននៅតាមតំបន់ព្រំដែន។ ភាគីទាំងពីរ ក៏បន្តកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន ផ្អែកលើច្បាប់ និងកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ និងសហការដោះស្រាយបញ្ហានានាដោយសន្តិវិធី ផ្អែកលើ គោលការណ៍គោរពឯករាជ្យ អធិបតេយ្យ និងបូរណភាពគ្នាទៅវិញទៅមក ព្រមទាំងលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែនអំពីបទប្បញ្ញត្តិព្រំដែន ដើម្បីចៀសវាងធ្វើ សកម្មភាព ឬបង្កបាតុភាពអសកម្មផ្សេងៗ នាំឲ្យប៉ះពាល់ដល់ស្ថានភាពដើមនៅតំបន់មិនទាន់ កំណត់ខណ្ឌសីមា។

ជាមួយគ្នានេះដែរ ភាគីទាំងពីរ បានបន្តកិច្ចសហការជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបម្រើឲ្យការប្រារព្ធនូវព្រឹត្តិការណ៍ជាតិ និងអន្តរជាតិសំខាន់ៗ នៅព្រះរាជាណាចក្រកម្ពុជា និងនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជា មានិតឡាវ ក្នុងឆ្នាំ២០២៣ និងបណ្តាឆ្នាំខាងមុខ ឲ្យប្រព្រឹត្តទៅដោយជោគជ័យ។

សូមបញ្ជាក់ថា តបតាមការអញ្ជើញរបស់ នាយឧត្តមសេនីយ៍ វិល័យ ឡាខាំហ្វង ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសន្តិសុខឡាវ និងដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំគណៈ ប្រតិភូជាន់ខ្ពស់កម្ពុជា អញ្ជើញបំពេញទស្សនកិច្ចការងារ ចាប់ពីថ្ងៃទី ១៨-២០ ខែមីនា ឆ្នាំ២០២៣ នៅ រដ្ឋធានីវៀងចន្ទន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ៕

## អង្គការសង់ត្រាល់
## បន្តផ្សព្វផ្សាយពីសុវត្ថិភាពចំណាកស្រុកដល់ពលរដ្ឋនៅតាមខេត្តមួយចំនួន

https://www.postkhmer.com/national/2023-03-20-1936-248210.html ជា សុខនី | Publication date 20 March 2023 | 19:36 ICT

**ភ្នំពេញៈ** មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) នៅតែបន្តសកម្មភាពធ្វើការអប់រំផ្សព្វផ្សាយ ពីសុវត្ថិភាពចំណាកស្រុកដល់ប្រជាពលរដ្ឋ នៅតាមបណ្តាខេត្តមួយចំនួន ខណៈនៅតែមានពលរដ្ឋខ្មែរជាច្រើននៅតែបន្តធ្វើចំណាកស្រុកតាមរយៈមេខ្យល់ដោយខុសច្បាប់។

មន្ត្រីកម្មវិធីនៃអង្គការសង់ត្រាល់ លោក ឌីថេ ហូយ៉ា បានប្រាប់ឱ្យដឹងនៅថ្ងៃទី១៩ ខែមីនា ថា ក្រុមអ្នកស្ម័គ្រចិត្តប្រឹក្សាយោបល់សុវត្ថិភាពចំណាកស្រុកហៅកាត់ថា SMA របស់អង្គការសង់ត្រាល់ បានចុះធ្វើការអប់រំ ផ្សព្វផ្សាយពីសុវត្ថិភាពចំណាស្រុក ដល់ប្រជាពលរដ្ឋនៅតាមខេត្តជាប់ព្រំដែន ដោយក្នុងនោះនៅតែបន្តរកឃើញពីបញ្ហាប្រឈមទាក់ទងនឹងពលករចំណាកស្រុក។ ពលរដ្ឋដែលទទួលបានការអប់រំ ផ្សព្វផ្សាយនេះ មានដូចជា នៅខេត្តសៀមរាប បន្ទាយមានជ័យ កំពង់ធំ និងបាត់ដំបងជាដើម។ លោក ឌីថេ ហូយ៉ា ថ្លែងថា ៖ «ក្រុមការងារ បានរកឃើញនូវបញ្ហាប្រឈមមួយចំនួន គឺពលករចំណាកស្រុកដោយគ្មានលិខិតឆ្លងដែន ឬឯកសារត្រឹមត្រូវតាមច្បាប់ ដែលត្រូវបានថៅកែមិនបើកប្រាក់ខែ និងត្រូវទទួលរងការកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ពលករ ជួញដូរមនុស្សផងដែរ»។

លោកថា ការបន្តចុះអប់រំនេះ ដោយសារតែមើលឃើញថា ការធ្វើចំណាកស្រុកគឺមិនអាចហាមឃាត់បានឡើយពីព្រោះវាជាជម្រើសរបស់អ្នកធ្វើចំណាកស្រុក ហើយពលរដ្ឋដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ពួកគាត់អត់មានព័ត៌មានច្បាស់លាស់ឡើយ។ មន្ត្រីកម្មវិធីរូបនេះបញ្ជាក់ថា ៖ «ការធ្វើចំណាកស្រុករបស់ពួកគាត់ មានភាពប្រថុយប្រថាន និងមានហានិភ័យខ្ពស់ក្នុងការចាញ់បោកមេខ្យល់ ដែលនឹងធ្វើឱ្យពួកគាត់បាត់បង់ថវិកាអស់ជាច្រើន ព្រមទាំងត្រូវប្រឈមជាមួយអំពើជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងប្រឈមជាមួយនឹងការចាប់ខ្លួនពីអាជ្ញាធរ »។

តាមរយៈការចុះផ្សព្វផ្សាយនៅតាមមូលដ្ឋាន របស់ក្រុមអ្នកស្ម័គ្រចិត្តប្រឹក្សាយោបល់សុវត្ថិភាពចំណាកស្រុករបស់អង្គការសង់ត្រាល់ បានរកឃើញថា នៅតែមានចំនួនប្រជាពលរដ្ឋខ្មែរច្រើន បានធ្វើចំណាកស្រុក ពី១ថ្ងៃទៅ១ថ្ងៃ និងពី១ខែទៅ១ខែផងដែរ។ នេះបើតាមលោក ឌីថេ ហូយ៉ា។ លោកបញ្ជាក់ថា ភាគច្រើនពលរដ្ឋដែលចំណាកស្រុក ច្រើនតែទៅតាមរយៈសាច់ញាតិ មេខ្យល់ ឬដោយខ្លួនឯង និងក្រៅពីនេះ មានតិចតួចណាស់ ដែលពួកគាត់ទៅតាមរយៈក្រុមហ៊ុនឯកជន។

លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការលីកាដូ បានឱ្យដឹងថា រូបលោកមានការព្រួយបារម្ភចំពោះករណីឆបោក ឬមេខ្យល់ដែលមានបំណងបោកប្រាស់ក្នុងការជ្រើសរើសពលករទៅធ្វើការក្រៅប្រទេស ឬការជួញដូរកម្លាំងពលកម្មដោយរូបភាពខុសច្បាប់។ លោកបញ្ជាក់ថា ស្ថានភាពបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរភាគច្រើន បានជឿលើក្រុមមេខ្យល់ ដោយសារកត្តា ជីវភាពរបស់ពួកគាត់ តម្រូវការការងារ និងការមិនបានទទួលព័ត៌មានគ្រប់គ្រាន់ ពីការជ្រើសរើសពលករ ឬក្រុមហ៊ុនស្របច្បាប់ មុននឹងពួកគាត់សម្រេចចិត្តចុះឈ្មោះ ឬយល់ព្រមជាមួយគេ។ លោក អំ សំអាត បាននិយាយថា៖ «អ៊ីចឹងអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ត្រូវចាត់វិធានការផ្លូវច្បាប់ ឱ្យបានតឹងរ៉ឹងដើម្បីទប់ស្កាត់ និងបង្ក្រាបមេខ្យល់ក្នុងការជ្រើសរើសពលករខុសច្បាប់ ហើយប្រជាពលរដ្ឋយើង ក៏គួរតែជ្រើសរើសការធ្វើចំណាកស្រុករកការងារដោយស្របច្បាប់ កុំជ្រើសរើសចំណាកស្រុកដោយខុសច្បាប់ដែលនាំឱ្យមានគ្រោះថ្នាក់»។

លោកស្រី រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យ ជាខេត្តដែលមានពលករធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃច្រើន បានប្រាប់ថា មិនថា សកម្មភាពរបស់អង្គការណានោះទេឱ្យតែជាការធ្វើឡើង ដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋ គឺអាជ្ញាធរខេត្ត នឹងធ្វើការគាំទ្រចំពោះសកម្មភាពការងាររបស់ពួកគាត់ទាំងអស់។ លោកស្រីបន្តថា ចំពោះការចុះអប់រំផ្សព្វផ្សាយ ស្តីពីសុវត្ថិភាពការធ្វើចំណាកស្រុករបស់អង្គការសង់ត្រាល់នេះ វាគឺជារឿងល្អ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីការចេះការពារខ្លួនរបស់ពួកគាត់ ឱ្យមានសុវត្ថិភាពនៅពេលដែលពួកគាត់ធ្វើចំណាកស្រុក និងជាពិសេសនៅពេលដែលពួកគាត់រងគ្រោះពីការកេងប្រវ័ញ្ច និងការជួញដូរ ពួកគាត់នឹងដឹងថា ត្រូវទាក់ទងអ្នកណា ហើយត្រូវដោះស្រាយបញ្ហានេះយ៉ាងម៉េច ដើម្បីឱ្យអ្នកពាក់ព័ន្ធមកជួយអន្តរាគមន៍ពួកគាត់ឱ្យទាន់ពេលវេលា។ លោកស្រី រស់ សុផានី បានថ្លែងថា៖ «បើនិយាយពីការផ្សព្វផ្សាយនេះ វាមិនអាចធ្វើឱ្យមានអត្រានៃការធ្វើចំណាកស្រុកដោយសុវត្ថិភាពបានទាំងស្រុងនោះទេ ប៉ុន្តែយ៉ាងហោចណាស់ ក៏វាអាចកាត់បន្ថយ បានខ្លះដែរនៃការធ្វើចំណាកស្រុកដោយមិនស្របច្បាប់ ដើម្បីបងប្អូនប្រជាពលរដ្ឋយើង ហើយវាក៏ជាកត្តាល្អសម្រាប់យើងដែរ»៕

# ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០២៣

## សម្តេចក្រឡាហោម ស ខេង ស្នើលេខាធិការដ្ឋាន គ.ជ.ប.ជ ស្រង់គ្រប់ព័ត៌មានទាំងឡាយពាក់ព័ន្ធការជួញដូរមនុស្ស ដើម្បីរួមគ្នារិះរកគ្រប់មធ្យោបាយឆ្លើយតបឱ្យទាន់ពេលវេលា

https://www.information.gov.kh/articles/100298 ចេញផ្សាយ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានស្នើលេខាធិការដ្ឋាន គ.ជ.ប.ជ ស្រង់គ្រប់ព័ត៌មានទាំងឡាយពាក់ព័ន្ធការជួញដូរមនុស្ស រាប់ទាំងព័ត៌មានចេញដោយក្រសួងការបរទេសអាម៉េរិក ដើម្បីរួមគ្នារិះរកគ្រប់មធ្យោបាយឆ្លើយតបឱ្យបានសមស្រប និងទាន់ពេលវេលាចំពោះបញ្ហាជួញដូរមនុស្សនេះ។

ការស្នើរបស់សម្តេចក្រឡាហោមបែបនេះ អញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃព្រហស្បតិ៍ ២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា ប្រសិនបើថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធទាំងអស់ខិតខំអនុវត្តន៍ទៅតាមទិសដៅដែលបានដាក់ចេញ ប្រាកដណាស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នឹងទទួលបានលទ្ធផលកាន់តែប្រសើរនៅឆ្នាំ២០២៣នេះ។ សម្តេចក្រឡាហោមបានគូសបញ្ជាក់ថា ថ្វីត្បិតលទ្ធផលការងារឆ្នាំ២០២២ មានភាពប្រសើរច្រើនធៀបនឹងឆ្នាំ២០២១ ប៉ុន្តែបញ្ហានេះនៅតែស្ថិតក្នុងស្ថានភាពប្រឈមដែលទាមទារការយកចិត្តទុកដាក់អនុវត្តន៍ជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព ដ្បិតការងារនេះមិនទាន់បញ្ចប់ និងមិនទាន់មានការពេញចិត្តនៅឡើយទេ ពិសេសការងារបង្ក្រាប ការជួយសង្គ្រោះជនរងគ្រោះ ការចាប់ជនល្មើសមកផ្តន្ទាទោស និងការបិទអាជីវកម្មពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។

សម្តេចក្រឡាហោម បានគូសបញ្ជាក់ទៀតថា រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខ មានឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តច្បាស់លាស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយទាមទារឱ្យភាគីពាក់ព័ន្ធទាំងអស់គោរពតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរួមគ្នាដោះស្រាយបញ្ហានេះ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. បានធ្វើរបាយការណ៍អំពីការលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆ្នាំ២០២២ ក្នុងនោះ សមត្ថកិច្ចបង្ក្រាបបាន១៦៦ករណី ធៀបនឹងឆ្នាំ២០២១ មាន៣៥៩ ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន២០២នាក់ ក្នុងនោះ ជនសង្ស័យ ជាជនបរទេសចំនួន៣៣នាក់។ លោកជំទាវបន្តថា សមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ ៣៥៨នាក់ ក្នុងនោះស្រីចំនួន២៦៥នាក់ ដោយប្រគល់ជូនមន្ទីរសង្គមកិច្ច និងក្រុមគ្រួសារ។

ក្នុងឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានអះអាងដែរថា ក្រោយមានកិច្ចប្រតិបត្តិការយ៉ាងក្តៅគគុកពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច បញ្ហាជួញដូរមនុស្ស ពិសេសករណីនៅខេត្តព្រះសីហនុ បានថមថយច្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែសម្តេចព្រួយបារម្ភថាពួកឧក្រិដ្ឋជន អាចចេញទៅជ្រកនៅតាមខេត្តផ្សេងទៀត ដែលទាមទារឱ្យយកចិត្តទុកដាក់ទាំងមន្ត្រី និងវិស័យឯកជន។ សម្តេចក្រឡាហោមបានថ្លែងអំណរគុណភាគីពាក់ព័ន្ធ រួមមានជនរងគ្រោះ វិស័យឯកជនរួមទាំងម្ចាស់ទីតាំងអាជីវកម្ម អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាប្រទេសជា

ដៃគូ ដែលបានផ្តល់កិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសការឈានទៅបង្ក្រាបអំពើល្មើសប្រកបដោយជោគជ័យជាបន្តបន្ទាប់ ៕ ដោយៈ ចាន់ សុធីវង្ស

## សម្តេច ស ខេង
## អញ្ជើញផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://dap-news.com/national/2023/03/23/320515/ ByKD102Posted on March 23, 2023

**ភ្នំពេញ៖ សម្តេច ស ខេង ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣នេះ បានអញ្ជើញផ្សព្វផ្សាយរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ គ.ជ.ប.ជ ដែលពិធីនេះប្រារព្ធធ្វើឡើង នៅវិទ្យាស្ថានជាតិអប់រំ។**

យោងតាមរបាយការណ៍ ឆ្នាំ២០២២ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣ បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ ផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមដ៏ធំធេង និងខិតខំការពារ សន្តិសុខក្នុងប្រទេស និងក្នុងតំបន់ ខិតខំរកដំណោះស្រាយបញ្ហា ដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា ការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហការក្នុងតំបន់ ដាក់ស្តែង ជោគជ័យនៃការដោះស្រាយបញ្ហា តំបន់ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២នេះ។

របាយការណ៍ដដែល បន្តថា ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែង ដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការដោះស្រាយភាពប្រឈម ដែលជះឥទ្ធិពលអវិជ្ជមាន ដល់ជីវភាពប្រជាពលរដ្ឋ និងបង្កភាពរាំងស្ទះដល់ការ អនុវត្តសកម្មភាពអភិវឌ្ឍគ្រប់វិស័យ រាជរដ្ឋាភិបាលកម្ពុជា ដែល មានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការនៅគ្រប់កម្រិត បានរៀបចំយុទ្ធសាស្រ្ត និង ដាក់ចេញនូវវិធានការចម្រុងៗជាច្រើន រាប់ទាំងការកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តទាំងឡាយ ដើម្បី ការពារប្រជាពលរដ្ឋពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា។

ប្រភពដដែលបន្ថែមថា ក្នុងស្ថានភាពដ៏អាក្រក់ នៃភាពប្រឈមនឹងការស្វែងរកការងារ នៅក្រៅប្រទេសដោយប្រថុយប្រថាន ក្នុងឋានៈជាពលករមិនស្របច្បាប់ រាជរដ្ឋាភិបាលកម្ពុជា តែងស្វះស្វែងក្នុងរកដំណោះស្រាយជាមួយប្រទេស ពាក់ព័ន្ធដើម្បីកាត់បន្ថយភាពរងគ្រោះ និងលើកកម្ពស់ សុវត្ថិភាពពលករចំណាកស្រុក ព្រមទាំងដោះស្រាយភាពប្រឈម របស់ពលករវិលត្រឡប់រាប់សិបម៉ឺននាក់ និងប្រជាពលរដ្ឋក្នុងស្រុកដែលប្រឈមនឹងវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញនូវ គោលនយោបាយសន្តិសុខសង្គម យ៉ាងទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ភាពទ័លច្រក និងប្រថុយប្រថានរបស់ប្រជាពលរដ្ឋ ដែលជឿលើការអូស ទាញរបស់ឧក្រិដ្ឋជនឲ្យធ្លាក់ក្នុងភាពរងគ្រោះ៕

# សម្ដេចក្រឡាហោម ស ខេង៖
# អ្នកដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានជនបរទេស ៨៧១នាក់

https://freshnewsasia.com/index.php/en/internationalnews/283690-2023-03-23-03-57-15.html

2023-03-23 10:57am

**(ភ្នំពេញ)៖** ចាប់ពីខែសីហា ឆ្នាំ២០២២ ដល់អំឡុងខែមីនា ២០២៣ មានបណ្ដឹងជាច្រើន ដែលបានផ្ញើចូលមក ដោយបានធ្វើចំណាត់ការពាក់ព័ន្ធបន្តទៅខេត្តចំនួន១១ និង រកឃើញមនុស្សពាក់ព័ន្ធ ១៣សញ្ជាតិ។ ក្នុងនោះ អ្នកដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានជនបរទេស ៨៧១នាក់ មកពី ១២ប្រទេស ដែលក្នុងនោះ មាន ១៦២នាក់ ត្រូវបានកំណត់អត្តសញ្ញាណរកឃើញថា មានពាក់ព័ន្ធនឹងអំពើរត់ពន្ធ និងជួញដូរមនុស្ស ហើយ ៨០នាក់ទៀត ត្រូវបានកំណត់ថា ជាជនសង្ស័យប្រព្រឹត្តបទល្មើស ដែលត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការ។ នេះបើតាមការបញ្ជាក់របស់សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ នៅសាលសន្និបាត វិទ្យាស្ថានជាតិអប់រំ។

សម្ដេចក្រឡាហោម ក៏បានថ្លែងទៀតថា ភាគច្រើន គឺករណីធ្វើអន្តោប្រវេសន៍ខុសច្បាប់ ធ្វើការងារខុសច្បាប់ និងចូលរួមក្នុងអំពើល្មើសដោយស្ម័គ្រចិត្ត (ឧទាហរណ៍ បង្កើតកម្មវិធីបោកជនរងគ្រោះ ការងារឆបោកអ្នកដទៃដោយទទួលបានបៀវត្សរ៍ ឬកម្រៃខ្ពស់...) ដែលត្រូវបានអនុវត្តតាមច្បាប់អន្តោប្រវេសន៍កម្ពុជា ធ្វើការបណ្ដេញចេញចំនួន ២.៤៥៥នាក់។ ចំណែកប្រជាពលរដ្ឋកម្ពុជា ដែលបានធ្វើទេសន្តរប្រវេសន៍ ទៅធ្វើការក្នុងប្រទេសក្រៅ ជាពិសេស ក្នុងប្រទេសថៃ មានរាប់សែននាក់ ដែលផុតសុពលភាពឯកសារ និងត្រូវប្រឈមនឹងការធ្វើការងារខុសច្បាប់បន្តទៀត ដែលចាំបាច់ត្រូវមានកិច្ចសហការដើម្បីរកនីតិវិធីសមស្រប ដើម្បីដោះស្រាយ ជៀសវាង ការវិលមករកបញ្ហាដដែលៗ ដូចដែលកើតមានជាយូរមកហើយ និងកាន់តែធ្ងន់ធ្ងរទៅ។

សម្ដេចក្រឡាហោម បានសង្កត់ធ្ងន់ថា ទាំងនេះជាកង្វល់ ដែលរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ ក្នុងការដោះស្រាយបញ្ហា ដោយបង្កើនការអប់រំផ្សព្វផ្សាយ រឹតបន្តឹងផ្នែកច្បាប់ និងពង្រីកកិច្ចសហការជាមួយបណ្ដាដៃគូ និងប្រទេសពាក់ព័ន្ធ ដើម្បីរួមគ្នាទប់ស្កាត់សកម្មភាពដែលឆ្ពោះទៅកាន់ភាពរងគ្រោះទាំងនោះ។ សម្ដេចក្រឡាហោម បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ បង្កើនការយកចិត្តទុកដាក់ក្នុងការស្ដាប់ការណែនាំរបស់មន្ត្រីជំនាញ ចូលរួមពិភាក្សាក្នុងវេទិកាសាធារណៈឱ្យបានច្រើន ដើម្បីបានស្ដាប់មតិយោបល់ពីអ្នកដទៃ និងព្យាយាមស្វែងរកជម្រើស ក្នុងការរស់នៅដែលល្អប្រសើរ មិនប្រថុយប្រថាន មិនចាកចោល ឬបោះបង់គ្រួសារ ឬអ្នកនៅក្រោមអាណាព្យាបាល ដោយដើរផ្សងព្រេងមិនច្បាស់លាស់ ដែលនាំឲ្យប្រឈមនឹងគ្រោះថ្នាក់នោះឡើយ។

បើតាមសម្ដេចក្រឡាហោម រាជរដ្ឋាភិបាលកម្ពុជា បានបង្កលក្ខណៈ ផ្ដល់បណ្ដុះបណ្ដាលជំនាញបច្ចេកទេស ដែលឆ្លើយតបទៅនឹងទីផ្សារការងារ ដែលកំពុងតែមានតម្រូវការទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ជូនដល់ពលរដ្ឋដែលត្រូវការជំនាញ ការងារ និងមុខរបរ ជៀសវាងការប្រថុយប្រថាន ផ្សងព្រេងដោយខុសច្បាប់ ដែលប្រឈមនឹងភាពរងគ្រោះ ឬការកេងប្រវ័ញ្ច៕

## សមត្ថកិច្ច សង្គ្រោះជនរងគ្រោះ
## ពីអាជីវកម្មផ្លូវភេទ ២២៥នាក់ និងឃាត់ខ្លួនជនសង្ស័យ ១៤៩នាក់

https://dap-news.com/national/2023/03/23/320536/ ByKD102Posted on March 23, 2023

**ភ្នំពេញ ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានលើកឡើងថា ក្នុងឆ្នាំ២០២២ សមត្ថកិច្ច ធ្វើការបង្ក្រាបអំពើអាជីវកម្មផ្លូវភេទចំនួន១៣០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៤៩នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ២២៥នាក់។**

ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២២ នៅថ្ងៃ២៣ មីនា លោកស្រី ជូ ប៊ុនអេង បានថ្លែងថា «ករណីធ្វើអាជីវកម្មផ្លូវភេទ បង្ក្រាបបាន ១៣០ករណី/១២៤ករណី (កើន៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១៤៩នាក់ អនីតិជន ១៩នាក់ និងជនបរទេស១០នាក់ មាន៣សញ្ជាតិ»។ លោកស្រីបន្តថា សង្គ្រោះជនរងគ្រោះចំនួ ២២៥នាក់ មានអាយុក្រោម១៥ឆ្នាំ ចំនួន ១២៤នាក់ , អាយុ១៥-១៧ឆ្នាំ ចំនួន ៣១នាក់ និងអាយុ១៨ឆ្នាំឡើង ៧០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ៤៨នាក់ និងប្រគល់ឲ្យគ្រួសារ ១៧៧នាក់)។

លោកស្រីរដ្ឋលេខាធិការបន្ថែមថា ដោយឡែក ការដាក់ចេញផែនការប្រតិបត្តិការបង្កើន ការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ របស់គ.ជ.ប.ជ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ជាលទ្ធផលដល់ត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ សមត្ថកិច្ច បានរកឃើញជនបរទេស ៨៧១នាក់ មកពី១២ប្រទេស ក្នុងនោះ មាន ១៦២នាក់ ត្រូវបានកំណត់អត្តសញ្ញាណរកឃើញពាក់ព័ន្ធនឹងអំពើរត់ពន្ធ និងជួញដូរមនុស្ស ហើយ ៨០នាក់ទៀត ត្រូវបានកំណត់ជាជនសង្ស័យប្រព្រឹត្តបទល្មើស ដែលត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការ៕

## សម្តេច ស ខេង ៖
## សមត្ថកិច្ច បង្ក្រាបបទល្មើសជួញដូរមនុស្សបានច្រើន តែមិនផ្សាយជាសាធារណៈ

https://dap-news.com/national/2023/03/23/320609/ ByPH104Posted on March 23, 2023

**ភ្នំពេញ ៖ ថ្លែងចំពោះមុខបណ្តាឯកអគ្គរាជទូតនានា ប្រចាំកម្ពុជា សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានលើកឡើងថា សមត្ថកិច្ចរបស់កម្ពុជា មានឆន្ទះ និងបង្ក្រាបបទល្មើស អំពើជួញដូរមនុស្ស គ្រប់ទម្រង់បានយ៉ាងច្រើន ប៉ុន្តែមិនបានផ្សព្វផ្សាយជាសាធារណៈ។**

សម្តេច ស ខេង លើកឡើងបែបនេះ ក្រោយពីឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ចោទសួរសម្តេច ស ខេង អំពីការជួញដូរមនុស្សថា «អត់មានព័ត៌មានចេញផ្សាយ អំពីករណីបង្ក្រាបបទល្មើសជួញដូរមនុស្ស»។ ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ នាថ្ងៃ២៣ មីនា សម្តេច ស ខេង បានឲ្យដឹងថា ជនរងគ្រោះបានដាក់ពាក្យបណ្តឹងតាមរយៈហ្វេសប៊ុកសម្តេចផ្ទាល់ គិតមកដល់ថ្ងៃនេះ មានជាង៨០០ពាក្យបណ្តឹង ភាគច្រើនសមត្ថកិច្ចបានជួយសង្គ្រោះជនរងគ្រោះ និងដោះស្រាយបានច្រើន។

សម្តេចបញ្ជាក់ថា «ប៉ុន្តែប្រហែលជាព័ត៌មានដើម្បីផ្សព្វផ្សាយហ្នឹង ព្រោះមន្ត្រីយើងពូកែធ្វើដែរ មិនមែនអន់ទេ ប៉ុន្តែមិនសូវធ្វើរបាយការណ៍ រាយការណ៍ប៉ុន្មានទេ? ប៉ុន្តែអ្នកខ្លះអត់ពូកែធ្វើ ប៉ុន្តែពូកែរាយការណ៍ ប៉ុន្តែអ្នកខ្លះធ្វើច្រើន ប៉ុន្តែអត់រាយការណ៍។ ឯកឧត្តម ឯកអគ្គរាជទូតអាមេរិកលើកឡើងថា បញ្ហានេះ អត់មានព័ត៌មាន។ យើងធ្វើហើយ តែអត់បានផ្សាយទេ»។ សម្តេចក៏បានណែនាំដល់សមាជិក គ.ជ.ប.ជ ត្រូវប្រមូលផ្តុំបញ្ហាទាំងអស់ ដើម្បីធ្វើ

ការចាត់ចែងផ្សព្វផ្សាយ ក្នុងការផ្តល់ព័ត៌មានឲ្យសាធារណជនបានដឹង ហើយឲ្យបានជាប់ជាប្រចាំ។ សម្តេចបានថ្លែងអំណរគុណចំពោះព័ត៌មានទាំងឡាយ ទោះបីជាព័ត៌មានជាតិ និងអន្តរជាតិ សម្តេចស្វាគមន៍ជានិច្ច ដើម្បីយកមកធ្វើការសិក្សា និងរួមគ្នាធ្វើការដោះស្រាយ ទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សម្តេច ស ខេង ឲ្យដឹងទៀតថា ឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ នៅតែតាំងចិត្ត និងប្តេជ្ញាយ៉ាងមុតមាំ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូច្នេះភាគីពាក់ព័ន្ធទាំងអស់ ត្រូវគោរពតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបន្ថែមទៀត។

សូមរំលឹកថា ក្នុងឆ្នាំ២០២២ កន្លងទៅនេះ សមត្ថកិច្ចកម្ពុជា បានធ្វើការបង្ក្រាបអំពើអាជីវកម្មផ្លូវភេទចំនួន ១៣០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៤៩នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ២២៥នាក់៕

## សម្តេចក្រឡាហោម ស ខេង បន្តអំពាវនាវដល់ភាគីពាក់ព័ន្ធរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស ឱ្យបានសកម្មបន្ថែមទៀត

https://btv.com.kh/article/21464 2023/03/23 11:27:23 am

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បន្តអំពាវនាវយ៉ាងទទូចដល់គ្រប់ អាជ្ញាធររាជធានី-ខេត្តវិស័យឯកជន និងប្រទេសជាមិត្តទាំងអស់រួមគ្នាបង្ការ និងទប់ស្កាត់ការជួញដូរមនុស្សឱ្យបានសកម្មបន្ថែមទៀត ខណៈករណីនេះនៅតែមានបញ្ហានៅឡើយ បើទោះបីជារាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈខ្ពស់ក្នុងការទប់ស្កាត់ និងបង្ក្រាបយ៉ាងណាក៏ដោយនោះ។

ក្នុងឱកាសអញ្ជើញផ្សព្វផ្សាយរបាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ គ.ជ.ប.ជ ដែលពិធីនេះប្រារព្ធធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំ នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣នេះ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា នាពេលបច្ចុប្បន្ន នេះរាជរដ្ឋាភិបាលកម្ពុជាបានកំពុងយកចិត្តទុកដាក់ និងសកម្មយ៉ាងខ្លាំងក្នុងការទប់ស្កាត់ បង្ក្រាបអំពើ ជួយដូរមនុស្ស ហើយយុទ្ធនាការនេះទទួលបានលទ្ធផលជាផ្លែផ្កា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះដោយធ្វើការឃាត់ខ្លួនជនសង្ស័យបានជាច្រើននាក់ ប៉ុន្តែឧក្រិដ្ឋជនមួយចំនួនទៀតកំពុងគេចខ្លួន ដូច្នេះ ទាមទារឲ្យភាគីពាក់ព័ន្ធទាំងអស់ធ្វើការសហការគ្នាដើម្បីស្វែងរកចាប់ខ្លួនយកមកផ្តន្ទាទោសទៅតាមច្បាប់ ជាធរមាន។

សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ការបង្ក្រាប និងទប់ស្កាត់អំពើជួញដូរមនុស្សនេះ បើពុំមានការជួយសហការគ្នាពីភាគីពាក់ព័ន្ធ បណ្តាក្រុមហ៊ុនឯកជនទេ គឺយើងនឹងមិនអាចទទួលបានលទ្ធផលល្អ ប្រសើនោះទេ ដូច្នេះករណីនេះត្រូវតែខិតខំបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាកុំឲ្យកម្ពុជាមានឈ្មោះជាប្រទេសត្រូវបានគេយកធ្វើជាជម្រកនៃការជួញដូរមនុស្ស។

បើតាមលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានឲ្យដឹងថា ក្នុងឆ្នាំ២០២២ កន្លងទៅនេះ សមត្ថកិច្ច ធ្វើការបង្ក្រាបអំពើអាជីវកម្មផ្លូវភេទចំនួន ១៣០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៤៩នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ២២៥នាក់។ ដោយឡែក ការដាក់ចេញនូវ ផែនការប្រតិបត្តិការបង្កើនការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ របស់គ.ជ.ប.ជ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ជាលទ្ធផលដល់ត្រឹមថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ ២០២២ សមត្ថកិច្ច បានរកឃើញជនបរទេស ៨៧១នាក់ មកពី ១២ប្រទេស ក្នុងនោះ មាន ១៦២នាក់ ត្រូវបានកំណត់អត្ត

សញ្ញាណរកឃើញថា ពាក់ព័ន្ធនឹងអំពើរត់ពន្ធ និងជួញដូរមនុស្ស ហើយ ៨០នាក់ទៀត ត្រូវបានកំណត់ថា ជាជនសង្ស័យប្រព្រឹត្តបទល្មើស ដែលត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការផងដែរ។ នេះបើតាមការ បញ្ជាក់ពីលោកជំទាវ ជូ ប៊ុនអេង៕អត្ថបទ៖ បាន ចក់

## មន្ទីរការងារខេត្ត បើកវគ្គផ្សព្វផ្សាយ ស្តីពី ការងារគ្រប់គ្រងហត្ថពលកម្មបរទេស នៅព្រះរាជាណាចក្រកម្ពុជា ដល់រោងចក្រ សហគ្រាស គ្រឹះស្ថាននានា ទូទាំងខេត្តសៀមរាប !

https://www.information.gov.kh/articles/100243 ចេញផ្សាយ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

នៅព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣នេះ វគ្គផ្សព្វផ្សាយ ស្តីពី ការងារគ្រប់គ្រងហត្ថពលកម្មបរទេស នៅព្រះរាជាណាចក្រកម្ពុជា ដល់រោងចក្រ សហគ្រាស គ្រឹះស្ថាននានា ទូទាំងខេត្តសៀមរាប ដែលរៀបចំឡើងដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នៅសាលាប្រជុំសាលាខេត្តសៀមរាប។ លោក ច័ន្ទ សុខុមចិត្តា ប្រធានមន្ទិរការងារខេត្ត បានបង្ហាញថា ការបើកវគ្គផ្សព្វផ្សាយ នាពេលនេះគឺមានគោលបំណង ដើម្បីពង្រឹងការគ្រប់គ្រងជនបរទេស ដែលមកប្រកបមុខរបរ និងបំរើការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសនៅខេត្តសៀមរាប ឲ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ព្រមទាំងសំដៅបង្កើនការយល់ដឹង និងចូលរួមអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីកាត់បន្ថយជាអតិបរមានូវការប្រើប្រាស់ហត្ថពលកម្មបរទេស ដែលមិនស្របច្បាប់នៅក្នុងខេត្តសៀមរាប ។

លោក បានបន្តថា ចំពោះលទ្ធផលការងារ ដែលមន្ទីរការងារ បានធ្វើសកម្មភាពពាក់ព័ន្ធការងារជនបរទេស នាពេលកន្លងមក និងក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសខេត្តសៀមរាប ដោយបានអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងស្នងការដ្ឋាន នគរបាលខេត្ត ចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ជារៀងរាល់ឆ្នាំហើយ តាមរយៈនៃការចុះធ្វើអធិការកិច្ចនេះ និយោជក ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ភាគច្រើន បានយល់ដឹង និងចូលរួមអនុវត្តច្បាប់បានល្អប្រសើរ។

លោក លី សំរិទ្ធ អភិបាលរងខេត្តសៀមរាប មានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានធានារក្សាបាននូវសន្តិភាព ស្ថេរភាពនយោបាយ និងសុវត្ថិភាពសង្គមបានយ៉ាងល្អប្រសើរ ដែលជាការបង្កលក្ខណៈអំណោយផល ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បានទាក់ទាញការវិនិយោគទាំងនៅក្នុង និងក្រៅប្រទេស ព្រមទាំងលំហូរ នៃទេសចរណ៍បរទេសមកទស្សនាកម្ពុជា រាប់លាននាក់ក្នុងមួយឆ្នាំៗ ដែលបានធ្វើឱ្យកម្ពុជា សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេលជាងមួយទសវត្សចុងក្រោយនេះ។

លោក អភិបាលរងខេត្ត បានបន្តទៀតថា តាមរយៈការផ្សព្វផ្សាយដ៏មានសារសំខាន់នាឱកាសនេះ លោកសង្ឃឹមថា លោក លោកស្រី នាយក ម្ចាស់អាជីវកម្ម តំណាងរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលបានចូលរួមនឹងយល់ជ្រួតជ្រាបអំពីគោលបំណង នៃពិធីផ្សព្វផ្សាយនេះ ហើយចូលរួមផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយ និងចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយជាអតិបរមា និងឈានទៅលុបបំបាត់ នូវរាល់ការប្រើប្រាស់ហត្ថពលកម្មបរទេសមិនស្របច្បាប់ ព្រមទាំងចូលរួមចំណែកគាំទ្រដល់ប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បទល្មើសពាក់ព័ន្ធល្បែងស៊ីសងខុសច្បាប់ ការឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀតសំដៅចូល

រួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមជាដើម៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឃាត់ខ្លួនប្ដីប្រពន្ធ២នាក់ ពាក់ព័ន្ធនឹងការ ធ្វើទារុ.ណកម្មលើកុមារ ក្រោមអាយុ ១៨ ឆ្នាំ នៅក្រុងតាខ្មៅ

https://cen.com.kh/archives/637893.html Posted ByPen Srey NeatMarch 23, 2023

ខេត្តកណ្តាល៖ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាល ខេត្តកណ្តាល កាលពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣ បានចុះបង្ក្រាប និងឃាត់ខ្លួនប្តីប្រពន្ធ២នាក់ ពាក់ព័ន្ធនឹងបទល្មើសកេងប្រវ័ញ្ច ពលកម្ម និងទារុណកម្មលើកុមារ ប្រព្រឹត្តនៅផ្ទះរបស់ជនសង្ស័យ ស្ថិតនៅភូមិ ព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅខេត្តកណ្តាល ។

សមត្ថកិច្ចនគរបាលបានឲ្យដឹងថា ជនសង្ស័យប្តីប្រពន្ធ២នាក់ខាងលើមាន៖ ១- ឈ្មោះ សុខ សូជា ភេទប្រុស អាយុ ៥៥ ឆ្នាំ មុខរបរ ម៉ោការសំណង់ ។២ -ឈ្មោះ គីម ឡេង ភេទស្រីអាយុ ៤៩ ឆ្នាំ មុខរបរលក់ដូរ បាយម្ហូប អ្នកទាំងពីរនាក់ មានទីលំនៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅខេត្តកណ្តាល។ ចំណែកឯ ជនរងគ្រោះមានចំនួន ពីរនាក់ មាន៖១- ក្មេងប្រុស អាយុ១៨ឆ្នាំ និង២ – ក្មេងស្រី អាយុ១៦ឆ្នាំ អ្នកទាំងពីរ មានទីលំនៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

បច្ចុប្បន្ន, ជនសង្ស័យទាំងពីរនាក់ ប្តីប្រពន្ធ ខាងលើ ត្រូវបានបញ្ជូនទៅកាន់ការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រៀបចំបែបបទ និងកសាងសំណុំរឿង បញ្ជូនបន្តទៅកាន់តុលាការ ចាត់ការតាមនីតិវិធីច្បាប់ ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

# ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២៣

## សម្តេច ស ខេង ព្រួយបារម្ភថាពួកឧក្រិដ្ឋជន អាចចេញទៅរកនៅតាមខេត្តផ្សេងទៀត ចំពោះករណីអំពើជួញដូរមនុស្ស

https://cen.com.kh/archives/638022.html Posted ByPen Srey NeatMarch 23, 2023

ភ្នំពេញ៖ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយ របាយការណ៍ជាតិស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រារព្ធនៅវិទ្យាស្ថានជាតិអប់រំ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. បានធ្វើរបាយការណ៍អំពីការលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆ្នាំ២០២២ ក្នុងនោះសមត្ថកិច្ចបង្ក្រាបបាន១៦៦ករណី ធៀបនឹងឆ្នាំ២០២១ មាន៣៥៩ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន២០២នាក់ ក្នុងនោះជនសង្ស័យជាជនបរទេសចំនួន៣៣នាក់។ លោកជំទាវ បន្តថាសមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ៣៥៨នាក់ ក្នុងនោះស្រីចំនួន២៦៥នាក់ ដោយប្រគល់ជូនមន្ទីរសង្គមកិច្ច និងក្រុមគ្រួសារ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍អបអរសាទរ និងកោតសរសើរចំពោះលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆ្នាំ២០២២កន្លងទៅ។ សម្តេច បានឯកភាពចំពោះទិសដៅការងាររបស់ គ.ជ.ប.ជ ដោយសង្កត់

ធូន់ថា ប្រសិនបើថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធទាំងអស់ខិតខំអនុវត្តទៅតាមទិសដៅដែលបានដាក់ចេញ ប្រាកដណាស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នឹងទទួលបានលទ្ធផលកាន់តែប្រសើរនៅឆ្នាំ២០២៣។ ថ្វីត្បិតលទ្ធផលការងារឆ្នាំ២០២២ មានភាពប្រសើរច្រើនធៀបនឹងឆ្នាំ២០២១ ប៉ុន្តែសម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថាបញ្ហានេះនៅតែស្ថិតក្នុងស្ថានភាពប្រឈមដែលទាមទារការយកចិត្តទុកដាក់អនុវត្តជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព ដ្បិតការងារនេះមិនទាន់បញ្ចប់ និងមិនទាន់មានការពេញចិត្តនៅឡើយទេ ពិសេសការងារបង្ក្រាប ការជួយសង្គ្រោះជនរងគ្រោះ ការចាប់ជនល្មើសមកផ្តន្ទាទោស និងការបិទអាជីវកម្មពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។

សម្តេច បានស្នើលេខាធិការដ្ឋាន គ.ជ.ប.ជ ស្រង់គ្រប់ព័ត៌មានទាំងឡាយ ពាក់ព័ន្ធការជួញដូរមនុស្ស រាប់ទាំងព័ត៌មានចេញដោយក្រសួងការបរទេសអាមេរិក ដើម្បីរួមគ្នារិះរកគ្រប់មធ្យោបាយឆ្លើយតបឱ្យបានសមស្រប និងទាន់ពេលវេលាចំពោះបញ្ហានេះ។ សម្តេចក្រឡាហោម បានគូសបញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខ មានឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តច្បាស់លាស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយទាមទារឱ្យភាគីពាក់ព័ន្ធទាំងអស់គោរពតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរួមគ្នាដោះស្រាយបញ្ហានេះ។ សម្តេច ក៏បានសង្កត់ធ្ងន់ដែរថាក្រោយមានកិច្ចប្រតិបត្តិការយ៉ាងក្តៅគគុកពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច បញ្ហាជួញដូរមនុស្ស ពិសេសករណីនៅខេត្តព្រះសីហនុ បានថមថយច្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែសម្តេចព្រួយបារម្ភថាពួកឧក្រិដ្ឋជន អាចចេញទៅជ្រកនៅតាមខេត្តផ្សេងទៀត ដែលសម្តេចទាមទារឱ្យយកចិត្តទុកដាក់ទាំងមន្ត្រី និងវិស័យឯកជន។

នាឱកាសនោះដែរ សម្តេចក្រឡាហោម ស ខេង ក្នុងនាមរាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានថ្លែងអំណរគុណភាគីពាក់ព័ន្ធ រួមមានជនរងគ្រោះ វិស័យឯកជនរួមទាំងម្ចាស់ទីតាំងអាជីវកម្ម អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាប្រទេសជាដៃគូ ដែលបានផ្តល់កិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសការឈានទៅបង្ក្រាបអំពើល្មើសប្រកបដោយជោគជ័យជាបន្តបន្ទាប់ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ដំណឹងល្អសម្រាប់ការងារ ! ខែក្រោយកម្ពុជានឹងបញ្ជូនពលករទៅធ្វើការនៅថៃ និងជប៉ុន ប្រមាណជិត ៤ពាន់នាក់

http://nokorwatnews.com/archives/980608 24/03/2023

ភ្នំពេញ ៖ រយៈពេល ២ខែដើម ឆ្នាំ២០២៣នេះ កម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅថៃចំនួន ៥.២០០នាក់ និងទៅជប៉ុនចំនួន ១.៥៤៤នាក់ ហើយនៅខែមេសាខាងមុខនេះ នឹងបញ្ជូនទៅបន្ថែមប្រមាណជិត ៤ពាន់នាក់ទៀត ក្នុងនោះទៅថៃចំនួន ៣.០០០នាក់ និង ៨០០នាក់ទៅជប៉ុន។

នេះជាការបញ្ជាក់ពី លោក អន ប៊ុនហាក់ ប្រធាន សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា នៅព្រឹកថ្ងៃទី២៣ មីនា ឆ្នាំ២០២៣ នេះ ។ លោក អន ប៊ុនហាក់ បានបន្ថែមថា តាមផែនការនៅក្នុងឆ្នាំ២០២៣នេះ កម្ពុជាគ្រោងនឹងបញ្ជូនពលករ និងកម្មសិក្សាការីទៅធ្វើការនៅប្រទេសថៃ និងជប៉ុនប្រមាណ ១៣ម៉ឺននាក់ កើនឡើងជាងឆ្នាំមុនដែលមានប្រមាណជាង ១១ម៉ឺននាក់ ក្នុងនោះនៅបញ្ជូនទៅប្រទេសថៃប្រមាណ ១០ម៉ឺននាក់ និងទៅប្រទេសជប៉ុនប្រមាណ ៣ម៉ឺននាក់។ លោកបានបន្តថា ពលករខ្មែរទៅធ្វើការនៅប្រទេសថៃភាគច្រើនទៅធ្វើការនៅតាមបណ្តារោងចក្រចំណីអាហារ និងក្រុមហ៊ុន សំណង់ សេវាកម្ម និងកសិកម្ម។ ចំណែកនៅប្រទេសជប៉ុនវិញ ភាគច្រើនជាកម្មសិក្សាការី។ រីឯពលករជំនាញមានប្រមាណតិចតួចទេដោយពួកគេទៅធ្វើការលើផ្នែកការវេចខ្ចប់ សំណង់ ចំណី

អាហារ សេវាកម្ម សណ្ឋាគារភោជនីដ្ឋាន កសិកម្មដាំដុះ និងចិញ្ចឹមសត្វ។ លោកបានបន្តទៀតថា ចំពោះនីតិវិធីការបញ្ជូនពលករមិនមានលក្ខខណ្ឌស្មុគស្មាញដូចកាលរាតត្បាតជំងឺកូវីដ-១៩នោះទេ គឺពលករដែលទៅធ្វើការនៅជប៉ុនតម្រូវឱ្យសិក្សាភាសាជប៉ុនរយៈពេល៦ខែ និងទៅថៃមិនតម្រូវឱ្យសិក្សាភាសាថៃទេប៉ុន្តែពលករត្រូវមានសុខភាពល្អ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង ១លាន ៣សែននាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះនៅថៃមានច្រើនជាងគេរហូតដល់ទៅ ១,២២លាននាក់ នៅកូរ៉េខាងត្បូងមានជាង ៤៥ ០០០នាក់ នៅម៉ាឡេស៊ីមាន ២៣ ០២៧នាក់ នៅជប៉ុនមាន ១១ ៤៥៣នាក់ នៅសិង្ហបុរីមាន ៨២១នាក់ នៅចិនហុងកុងមាន ២០២នាក់ និងអារ៉ាប៊ីសាអូឌីត ៤៣នាក់ ដោយក្នុង១ឆ្នាំៗបានផ្ញើថវិកាមកក្រុមគ្រួសារវិញប្រមាណជាង ៣ពាន់លានដុល្លារ។ សូមបញ្ជាក់ថា : ការផ្តល់កម្លាំងពលកម្មឲ្យពលរដ្ឋខ្មែរមានការងារធ្វើនៅក្រៅប្រទេស ជាលក្ខណៈពិសេសល្អបំផុត សម្រាប់ឲ្យពួកគាត់ទទួលបាននូវប្រាក់ចំណូល តាមរយៈកម្លាំងពលកម្ម ដើម្បីជួយសម្រាលដល់ស្ថានភាពគ្រួសារ ក៏ដូចជាគោលនយោបាយកាត់បន្ថយភាពក្រីក្រដែលរាជរដ្ឋាភិបាលដាក់ចេញជាគោលការណ៍។

ប្រទេសកម្ពុជា មានសន្តិភាព ប្រជាពលរដ្ឋគ្រប់រូប មានឱកាសស្វែងរកការងារធ្វើ តាមជំនាញ សមត្ថភាព ចំណេះដឹង បទពិសោធន៍ ទទួលបានចំណូល ដើម្បីឲ្យពួកគាត់ មានជីវភាពល្អប្រសើរ ៕

## បិទវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សឆ្លងដែន ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេតប្រមូលភស្តុតាងនិងបង្ក្រាបករណីជួញដូរមនុស្ស

https://www.gdlf-kh.com/2023/03/23/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ បន្ទាប់ពីបើកវគ្គសិក្សាអស់រយៈពេល០៣ថ្ងៃ នៅសាលប្រជុំនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃពុធ ១ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ វគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សឆ្លងដែន ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេតប្រមូលភស្តុតាងនិងបង្ក្រាបករណីជួញដូរមនុស្ស ត្រូវបានរៀបចំពិធីបិទក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងមានការចូលរួមពី លោក លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ ស្នងការរង នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងសិក្ខាកាមមកពីអធិការដ្ឋាននគរបាលក្រុងស្រុកទាំង០៩ វរសេនាតូចការពារព្រំដែនគោកទាំង០៤ ប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែត បញ្ជាការដ្ឋានសិករងខេត្តនិងបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ សរុបចំនួន៣៣រូប ។

ថ្លែងនៅក្នុងពិធីបិទវគ្គនោះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ បានថ្លែងនូវការកោតសរសើរដល់សិក្ខាកាមទាំងអស់ ដែលបានយកចិត្តទុកដាក់ខិតខំត្រង់ត្រាប់ស្តាប់រៀនសូត្រ លើការងារជំនាញ ច្បាប់ពាក់ព័ន្ធ នីតិវិធីស្រាវជ្រាវស៊ើបអង្កេត ការបង្ការទប់ស្កាត់សកម្មភាពជួញដូរមនុស្សឆ្លងដែន ការអន្តរាគមន៍ជួយជនរងគ្រោះ និងការស្រាវជ្រាវបង្ក្រាបករណីជួញដូរមនុស្ស។ ឯកឧត្តម អគ្គស្នងការរង បានបញ្ជាក់ថា ៖ ក្នុងរយៈពេល០៣ថ្ងៃនេះ យើងបានចែករំលែកនូវបទពិសោធន៍ និងចំណេះដឹងទៅវិញទៅមកក្នុងគោលបំណងបង្កើនសមត្ថភាពយល់ដឹងដើម្បីយកទៅអនុវត្តច្បាប់នៅសហគមន៍ ចូលរួមបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន ការរំលោភបំពានផ្លូវភេទកុមារដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចពលកម្ម ពពោះជំនួសក្នុងគោលបំណងលក់ដូរទារក អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ទម្រង់ផ្សេងទៀតនៃអំពើជួញដូរមនុស្ស និងបទល្មើសព្រហ្មទណ្ឌដ៏ទៃទៀត។

យើងទាំងអស់គ្នាត្រូវចូលរួមបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើស ដើម្បីការពារសន្តិភាព ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ នៅមូលដ្ឋានឲ្យបានល្អ។ ជាចុងក្រោយឯកឧត្តម ក៏បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ក្រោយពីទទួលបានបទពិសោធន៍ និងចំណេះដឹងនេះ ពេលត្រឡប់ទៅអង្គភាពវិញ សូមយកចំណេះដឹងទាំងនេះទៅចែករំលែកដល់សហការីរួមការងារ ពិសេសគឺផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋកុំឲ្យចូលរួមប្រព្រឹត្តបទល្មើស និងត្រូវចូលរួមការពារកូនចៅ កុំឲ្យចាញ់បោកជនល្មើសដែលអាចធ្លាក់ខ្លួនទៅជាជនរងគ្រោះនៃបទល្មើសផ្សេងៗ៕

## កម្ពុជា និងវៀតណាម ឯកភាពពន្លឿនការងារប្រយុទ្ធប្រឆាំងការលាងលុយកខ្វក់ និងជួញដូរមនុស្សឆ្លងដែន

https://www.khmertimeskh.com/501261663/ ហង្ស ពណ្ណរាយ / Khmer Times March 24, 2023

ភាគីកម្ពុជា និងវៀតណាម បានឯកភាពគ្នាពន្លឿនការងារប្រយុទ្ធប្រឆាំងពាក់ព័ន្ធនឹងការលាងលុយកខ្វក់ ការជួញដូរមនុស្ស និងអំពើឧក្រិដ្ឋកម្មឆ្លងដែននានា ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសឧក្រិដ្ឋកម្មនាំចូល និងនាំចេញនៅតាមព្រំដែនប្រទេសទាំងពីរ។ ក្នុងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងវៀតណាម កាលពីថ្ងៃទី២០ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ បានឱ្យដឹងថា ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅប្រទេសវៀតណាម រយៈពេល៣ថ្ងៃ ភាគីទាំងពីរបានឯកភាពសហប្រតិបត្តិការការងារសំខាន់ៗជាច្រើន ដើម្បីលើកកម្ពស់វិស័យវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសេដ្ឋកិច្ច ឱ្យកាន់តែរីកចម្រើន និងជឿនលឿន។ ក្រសួងបញ្ជាក់ថា ក្នុងកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ប្រទេសទាំងពីរបានឯកភាពពន្លឿនការសម្រប សម្រួលដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសឧក្រិដ្ឋកម្មគ្រឿងញៀន ការឆបោក ពាណិជ្ជកម្ម ការលាងលុយកខ្វក់ ការជួញដូរមនុស្ស ការឆ្លងដែនខុសច្បាប់ ឧក្រិដ្ឋកម្មបច្ចេកវិទ្យា ការកាប់ព្រៃឈើ និងដឹកជញ្ជូនឈើខុសច្បាប់។

ក្រសួងបន្ថែមថា ភាគីទាំងពីរក៏ធ្វើការរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មធនធានធម្មជាតិ ការនេសាទខុសច្បាប់ ការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ ការជួញដូរគ្រឿងញៀន និងសារធាតុគីមី ជាពិសេស ការជួញដូរ និងការរត់ពន្ធអាវុធ គ្រឿងផ្ទុះ និងឧក្រិដ្ឋកម្មឆ្លងដែននានា។ ក្រសួងបន្តថា ក្នុងជំនួបរវាងភាគីកម្ពុជា និងវៀតណាម រយៈពេល៣ថ្ងៃ ប្រទេសទាំងពីរបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយគ្នាលើវិស័យបរិស្ថាន ធនធានទឹក និងធាពសាស្ត្រ រៀបចំដែនដី និងនគរូបនីយកម្ម និងសំណង់ ពន្ធគយ ឧស្សាហកម្ម និងសហគ្រាសធនតូចនិងមធ្យម ការបោះពុម្ពផ្សាយ សារព័ត៌មាន និងការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដើម្បីបង្កើនប្រសិទ្ធភាពការងារផងដែរ។ សួងថា ក្នុងកិច្ចសហប្រតិបត្តិការនេះ ក៏បានលើកឡើងអំពីវប្បធម៌ និងកីឡា ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សង្គមកិច្ច និងការអភិវឌ្ឍ បញ្ហាព្រំដែន កំណត់ត្រា និងបណ្ណាសារ កិច្ចការជនជាតិ និងសាសនា ការពារជាតិ កិច្ចការច្បាប់ និងយុត្តិធម៌ អធិការកិច្ច កិច្ចការកុងស៊ុល និងប្រជាជននៅក្រៅប្រទេស ជាពិសេស កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន និងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា ឡាវ និងវៀតណាម។

ក្នុងសេចក្តីប្រកាសព័ត៌មានបន្ថែមថា ភាគីទាំងពីរបានជំរុញការងារអភិបាលកិច្ចតាមប្រព័ន្ធអ៊ីនធឺណែតសន្តិសុខព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធឌីជីថល បដិវត្តកម្មឌីជីថល ដើម្បីឆ្ពោះទៅរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថលសម្រាប់ថ្ងៃអនាគត់ ជាពិសេស ឯកភាពពង្រឹងទេសចរណ៍រួមដោយអនុញ្ញាតឱ្យបើកបរដោយខ្លួនឯង ជាមួយនឹងនីតិវិធីឆ្លងដែនមានភាពងាយស្រួល។ពក្នុងនោះ ប្រទេសទាំងពីរ បានឯកភាពពង្រឹងទំនាក់ទំនងរវាងកងទ័ពកម្ពុជា និងវៀតណាម តាមរយៈការអនុវត្តពិធីសារស្តីពីកិច្ចសហប្រតិបត្តិការការពារជាតិទ្វេភាគី ដើម្បីផ្លាស់ប្តូរទស្សនកិច្ចគ្រប់កម្រិត និងអាហារូបករណ៍ប្រចាំឆ្នាំ ដែលរួមចំណែកដល់សន្តិភាព ស្ថិរភាព និងសន្តិសុខនៅក្នុងតំបន់ និង

ពិភពលោក។ ក្នុងជំនួបរវាងភាគីកម្ពុជា និងវៀតណាម ប្រទេសវៀតណាម បានសម្រេចបន្តផ្តល់អាហារូបករណ៍បន្ថែមដល់និស្សិតកម្ពុជាលើជំនាញវិស្វកម្មឧស្សាហកម្ម ព័ត៌មាន និងបច្ចេកវិទ្យាគមនាគមន៍ និងមេកាត្រូនិច ការអភិវឌ្ឍកម្មវិធី វិស្វកម្ម អេឡិចត្រូនិច រូបវិទ្យា វិទ្យាសាស្ត្រទិន្នន័យ គណិតវិទ្យា និងការអប់រំ STEM។

ភាគីទាំងពីរបានរួមគ្នាពង្រឹងអនាម័យ ដើម្បីការពារការរីករាលដាលឆ្លងដែននៃសត្វល្អិត និងជំងឺឆ្លងផ្សេងៗជាដើម ជាពិសេស បានឯកភាពអនុវត្តឱ្យមានប្រសិទ្ធភាពនូវការងារកសិកម្មរវាងប្រទេសទាំងពីរៀងដែរ។ ដំណើរទស្សនកិច្ចផ្លូវការនេះ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោក ប្រាក់ សុខុន បានឱ្យដឹងថា កម្ពុជា និងវៀតណាម បានបញ្ជាក់ពីគោលបំណងសិក្សាគម្រោងបង្កើតខ្សែរថភ្លើងពីភ្នំពេញ បាវិត-ម៉ុកបាយ-ហូជីមិញ ជាពិសេស កំណត់នូវចំណុចតភ្ជាប់នៃផ្លូវល្បឿនលឿនភ្នំពេញ-បាវិត ម៉ុកបាយ-ហូជីមិញ ផងដែរ។

លោក ប្រាក់ សុខុន បានបញ្ជាក់ថា៖ «ការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងគ្នាជាញឹកញាប់រវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវស្មារតីភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី ការជឿជាក់ទៅវិញទៅមក កិច្ចសហប្រតិបត្តិការគ្រប់វិស ័យ និងស្ថិរភាពយូរអង្វែង»។ លោកបន្ថែមថា ក្រៅពីសមិទ្ធផលខាងលើ ភាគីទាំងពីរបានឯកភាពជំរុញឱ្យមានដំណើរទស្សនកិច្ច និងកិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងពីរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។

កាលពីឆ្នាំ២០២២ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធនៅទូទាំងប្រទេស ជាពិសេស អាជ្ញាធរនៅតាមព្រំដែន ត្រូវបង្កើនការត្រួតពិនិត្យ និងចុះបង្ក្រាបរាល់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែន។ លោកបញ្ជាក់ថា ចំពោះបទល្មើសពាក់ព័ន្ធនឹងជួញដូរមនុស្ស និងលាងលុយកង្វក់ គឺជាអំពើមួយដែលមិនគួរកើតមាននៅលើទឹកដីកម្ពុជា ដូច្នេះ អាជ្ញាធរត្រូវបង្កើនទប់ស្កាត់ និងបង្ក្រាបដោយមិនអាចលើកលែងបានឡើយ៕

## ក្មេងស្រីដែលដង្ហោយរកជំនួយសុំត្រឡប់ពីប្រទេសចិន មកផ្ទះវិញ បានត្រឡប់ដល់ផ្ទះដោយសុវត្ថិភាព

http://nokorwatnews.com/archives/980813 25/03/2023

ខេត្តតាកែវ ៖ នៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្មេងស្រី វៀត វៀង ដែលបងប្អូនបានឃើញនាងដង្ហោយរកជំនួយជួយនាងត្រឡប់មកផ្ទះវិញ កាលពីដើមខែ មករា ២០២៣ ត្រូវបាន ក្រសួងសង្គមកិច្ច ស្ថានទូតកម្ពុជានៅប្រទេសចិន សហ ការ ជាមួយស្ថានទូតចិន បានសម្របសម្រួលបញ្ជូនត្រឡប់ មកប្រទេសកម្ពុជាវិញតាមរយៈការជួយគាំទ្រពីអង្គការ វតនៈអ៊ិនធើណាសិនណាល់ កាលពីថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ឥលូវនេះ វៀត វៀង បានត្រឡប់ទៅដល់ផ្ទះ ហើយដោយសុវត្ថិភាព ជាមួយនឹងការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោកប្រធានមន្ទីរសង្គមកិច្ចខេត្ត លោកអភិបាលស្រុក បូរីជលសារ លោកមេឃុំកំពង់សាំង លោក មេភូមិ សង្គមមានជ័យ និង ឪពុកម្តាយរបស់នាង ។

សូមបញ្ជាក់ថា, បច្ចុប្បន្ននេះ ទោះជាកម្មករ ទៅធ្វើការនៅប្រទេសណាក៏ដោយ ពេលមានបញ្ហាអី ទាំងខាងអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅក្រៅប្រទេសនីមួយៗ បានយកចិត្តទុកដាក់ ជួយទាន់ពេលវេលា ខណៈមានព័ត៌មានជាច្រើន ដែលទូតកម្ពុជា ផ្តល់ដំណឹងពីការទំនាក់ទំនងគ្នា ជាប្រចាំ ៕

# ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០២៣

## ឯកសារចំនួន២ ទាក់ទងនឹង ការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ត្រូវបានចុះហត្ថលេខា ក្រោយជំនួបនាយករដ្ឋមន្ត្រីកម្ពុជា-ម៉ាឡេស៊ី

https://freshnewsasia.com/index.php/en/localnews/284109-2023-03-27-06-37-03.html 2023-03-27 01:37pm

**(ភ្នំពេញ)៖** យ៉ាងហោចណាស់ មានឯកសារចំនួន២ ត្រូវបានចុះហត្ថលេខា នៅវិមានសន្តិភាព នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣នេះ ក្រោយជំនួបពិភាក្សាទ្វេភាគីរវាង សម្តេចតេជោ ហ៊ុន សែន និងលោកដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៉ីប្រាហ៉ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា។ ឯកសារទាំងពីរនោះ រួមមាន៖ ទី១៖ អនុស្សារណយោគយល់គ្នារវាងរដ្ឋាភិបាលម៉ាឡេស៊ី និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករការងារផ្ទះ និងទី២៖ អនុស្សារណយោគយល់គ្នារវាងរដ្ឋាភិបាលម៉ាឡេស៊ី និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។

លោក អាន់វ៉ា ប៊ីន អ៉ីប្រាហ៉ីម បានដឹកនាំគណៈប្រតិភូអញ្ជើញមកដល់កម្ពុជា នៅព្រឹកថ្ងៃទី២៧ ខែមីនា ដើម្បីបំពេញទស្សនកិច្ចតបតាមការអញ្ជើញរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។ អំឡុងបំពេញទស្សនកិច្ចនេះ លោកនឹងចូលក្រាបបង្គំគាល់ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងព្រះបរមរាជវាំង ហើយនឹងមានជំនួបសម្តែងការគួរសមដាច់ដោយឡែកជាមួយសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាកម្ពុជាផងដែរ៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៩ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣២នាក់

https://freshnewsasia.com/index.php/en/localnews/283901-2023-03-24-13-01-59.html 2023-03-24 08:01pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៩ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨០៧ករណី មានមនុស្ស ២,០២២នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៧១សំណើ និងបិទសំណុំរឿង ២៦៣សំណើ (រកឃើញមនុស្ស ១,១៧៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៥នាក់, បិទក្រុមហ៊ុន ៩ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៦ករណី៕

# តុលាការវៀតណាមដាក់ពន្ធនាគារមនុស្ស៨នាក់ពីបទបញ្ជូនជនជាតិខ្លួន៣៧នាក់មកកម្ពុជាដើម្បីលក់ក្រលៀន

https://www.khmertimeskh.com/501262112// March 25, 2023

តុលាការនៅទីក្រុងហូជីមិញ បានកាត់ទោសដាក់ពន្ធនាគារដល់មនុស្ស ៨ នាក់ ដែលជាប់ពាក់ព័ន្ធក្នុងក្រុមជួញដូរក្រលៀន ដែលបានបញ្ជូនជនជាតិវៀតណាម ៣៧ នាក់មកកម្ពុជាក្នុងនាមជាអ្នកបរិច្ចាគសរីរាង្គ។ ជនជាប់ចោទទាំងប្រាំបីនាក់ម្នាក់ៗជាប់ពន្ធនាគារពី ១០ ទៅ ១៦ឆ្នាំ ក្រោមការចោទប្រកាន់ទោសពីបទ "ជួញដូរសរីរាង្គមនុស្ស" ។ ពួកគេទាំងអស់បានធ្វើការជាឈ្មួញកណ្តាលឱ្យក្រុមជួញដូរក្រលៀន ដែលជាចំនួនដ៏ធំបំផុតមិនធ្លាប់មានដែលនគរបាលវៀតណាមបានបង្ក្រាប។ មេក្លោង ឈ្មោះTon Nu ThiHuyenអាយុ ៤៦ឆ្នាំបានស្លាប់ដោយសារជំងឺខ្សោយតម្រងនោមអំឡុងពេលស៊ើបអង្កេត។

យោងតាមសាលក្រមក្នុងឆ្នាំ២០០៩ឈ្មោះ Huyen បានទៅប្រទេសចិន ដើម្បីធ្វើការប្តូរក្រលៀនដោយខុសច្បាប់ ហើយនាងបានជួបបុរសម្នាក់ឈ្មោះ Dao Thanh Nhan។ នៅឆ្នាំ ២០១៦ នាងបានមកប្រទេសកម្ពុជាដើម្បីជួប ឈ្មោះ Nhan ហើយគាត់បានណែនាំនាងឱ្យស្គាល់វេជ្ជបណ្ឌិតជនជាតិសិង្ហបុរីដែលកំពុងធ្វើការនៅមន្ទីរពេទ្យមួយក្នុងទីក្រុងភ្នំពេញ។ គ្រូពេទ្យនោះបានប្រាប់ Huyenឱ្យស្វែងរកមនុស្សដែលចង់លក់ក្រលៀនរបស់ពួកគេ ហើយនាំពួកគេមកប្រទេសកម្ពុជាដើម្បីធ្វើការវះកាត់។ បន្ទាប់មក Huyen បានត្រឡប់ទៅប្រទេសវៀតណាមវិញ ហើយបានភ្ជាប់ទំនាក់ទំនងជាមួយ Viet ដែលនាងបានសុំឱ្យស្វែងរកអ្នកដែលបាននិយាយក្នុងបណ្តាញសង្គមថាពួកគេចង់លក់ក្រលៀន។ សម្រាប់រាល់ការប្តូរក្រលៀន Huyenទទួលបាន ៧០លានដុង (២,៩៧៣ដុល្លារ) ដែលក្នុងនោះនាងបានចែករំលែក ពី១៥ទៅ២៥លានដុងជាមួយឈ្មោះViet។ អ្នកដែលមកកម្ពុជាដើម្បីលក់ក្រលៀនរបស់ពួកគេដោយជោគជ័យបានត្រឡប់ទៅប្រទេសវៀតណាមវិញហើយបានណែនាំមនុស្សបន្ថែមទៀតដល់ឈ្មោះ Huyenនិង Viet ។

ដោយទាញយកប្រយោជន៍ពីក្រុម Facebook ដែលមានឈ្មោះថា Hoi hien than (ក្រុមបរិច្ចាគក្រលៀន ) Huyenនិង Viet បានដាក់ឈ្មោះមនុស្សរបស់ពួកគេទៅក្នុងបញ្ជីអ្នកបរិច្ចាគ ដូច្នេះពួកគេនឹងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យធំៗក្នុងទីក្រុងហូជីមិញ ដើម្បីធ្វើតេស្តជាច្រើនតាមតម្រូវការសម្រាប់ ការប្តូរក្រលៀន។ បន្ទាប់មក Huyen បានបញ្ជូនលទ្ធផលតេស្តទាំងអស់ទៅកាន់វេជ្ជបណ្ឌិតសិង្ហបុរី។ ពេលគ្រូពេទ្យរកបានក្រលៀនដែលត្រូវហើយ Huyenបាននាំអ្នកលក់ក្រលៀនមកកម្ពុជាដើម្បីវះកាត់។ បន្ទាប់ពីលក់ក្រលៀនរួច "អ្នកបរិច្ចាគ" ម្នាក់ៗបានស្នាក់នៅមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញរយៈពេល១២ថ្ងៃ ហើយបានទទួលប្រាក់ពី ២០០ទៅ២១០ លានដុង។ ចន្លោះខែមេសា ឆ្នាំ ២០១៧ ដល់ខែមករា ឆ្នាំ ២០១៩ ក្រុមរបស់ Huyenបានទាក់ទាញអ្នកលក់ក្រលៀនចំនួន ១០០ នាក់ ហើយបានបញ្ជូនពួកគេចំនួន ៣៧ នាក់មកប្រទេសកម្ពុជា ដើម្បីវះកាត់ប្តូរក្រលៀន។

ក្នុងចំណោមអ្នកដែលត្រូវបានបញ្ជូនមកប្រទេសកម្ពុជា មាន ២០ នាក់បានលក់ក្រលៀនរបស់ពួកគេដោយជោគជ័យ ធ្វើឱ្យHuyenរកចំណូលបាន ១,៤ ពាន់លានដុង។ Vietរកចំណូលបាន១៥០លានដុងបន្ទាប់ពីរកបានអ្នកលក់ក្រលៀនចំនួន៤០នាក់ដែល៨នាក់ក្នុងចំណោមនោះ លក់ក្រលៀនដោយជោគជ័យ។ ជនជាប់ចោទទាំងប្រាំពីរនាក់ផ្សេងទៀត រកចំណូលបានពី ៤០ ទៅ ១២០លានដុង ដោយធ្វើជាឈ្មួញកណ្តាល។ អាជ្ញាធរវៀតណាមបានស្នើឲ្យសមភាគីរបស់ខ្លួននៅកម្ពុជាជួយតាមដានវេជ្ជបណ្ឌិតសិង្ហបុរី និងលោក Dao Thanh Nhan។ ជនជាប់ចោទទាំងប្រាំបីនាក់ បានប្រាប់គណៈវិនិច្ឆ័យថាពួកគេដឹងពីបទល្មើសដែលពួកគេបានប្រព្រឹត្ត ប៉ុន្តែពួកគេបានបញ្ជាក់ពីអ្វីដែលពួកគេបានធ្វើដោយហេតុផលថា ពួកគេទាំងអស់សុទ្ធតែស្ថិតក្នុងស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុ

ហើយត្រូវលក់ក្រលៀនរបស់ពួកគេដើម្បីរកប្រាក់។ ពួកគេបាននិយាយថា លុះក្រោយមកទើបគេណែនាំអ្នកជំទៃឲ្យស្គាល់ក្រុមនោះ។ VNExpress

## ការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃការជួញដូរមនុស្ស នឹងត្រូវរដ្ឋបាលខេត្តព្រះសីហនុពិភាក្សាក្នុងសន្និបាតប្រចាំឆ្នាំ

https://www.postkhmer.com/national/2023-03-25-1007-248389.html ភ្នំពេញ ប៉ុស្ដិ៍ | Publication date 25 March 2023 | 10:07 ICT

**ព្រះសីហនុៈ** ការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់មានសុវត្ថិភាព ការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃការជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ និងការធ្វើអធិការកិច្ចហត្ថពលករបរទេស នឹងត្រូវរដ្ឋបាលខេត្តព្រះសីហនុ ធ្វើការពិនិត្យ និងពិភាក្សាគ្នា ដើម្បីដាក់ឱ្យបន្តអនុវត្តនៅក្នុងឆ្នាំ ២០២៣ នេះជាបន្តទៀត។ បន្ថែមពីនេះ ការផ្ដល់សេវារដ្ឋបាល ការដោះស្រាយសំណើ សំណូមពររបស់ប្រជាពលរដ្ឋ នៅអង្គភាពច្រកចេញចូលតែ ១ខេត្ត ក្រុង ស្រុក និងយន្តការច្រកចេញចូលតែ ១ឃុំ សង្កាត់ យន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ យន្តការគាំទ្ររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ការគ្រប់គ្រងកាកសំណល់រឹង រាវ និងអនាម័យបរិស្ថាន និងការងារទេសចរណ៍ ក៏នឹងត្រូវធ្វើការពិភាក្សាតាមក្រុមនីមួយៗ ក្នុងការប្រមូលជាតុចូលយកមកអនុវត្តនៅឆ្នាំបន្តផងដែរ។

ទាំងនេះគឺជាការលើកឡើងរបស់លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ នៅថ្ងៃទី ២៤ មីនា ក្នុងពេលដែលលោកដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ សម្រាប់ការត្រៀមរៀបចំមហាសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់រដ្ឋបាលខេត្តព្រះសីហនុ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៣០-៣១ ខែមីនា ឆ្នាំ ២០២៣។ នេះបើយោងតាមផេកហ្វេសប៊ុក រដ្ឋបាលខេត្តព្រះសីហនុ។

លោក គួច ចំរើន ថ្លែងទៀតថា ដោយឡែកនៅឆ្នាំក្រោយ រដ្ឋបាលខេត្ត នឹងជ្រើសរើសយកប្រធានបទចំនួន ៤ មានដូចជា ១ ការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ២ ការអភិវឌ្ឍមូលដ្ឋាន ៣ ការបម្រើសេវាសាធារណៈ និង៤ ការងារសង្គម ហើយចំណុចទាំង ៤នេះ ជាការទាក់ទងទៅនឹងប្រធានបទដែលរដ្ឋបាលខេត្តត្រូវយកចិត្តទុកដាក់អនុវត្តការងារ នៅឆ្នាំ ២០២២៣ និងឆ្នាំ ២០២៤ ខាងមុខឱ្យកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផលក្នុងការបម្រើការងារអភិវឌ្ឍនៅតាមមូលដ្ឋាន នៃខេត្តព្រះសីហនុ ឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត៕

## ថ្នាក់ដឹកនាំយោធភូមិភាគទី៥ បញ្ជាកងកម្លាំងឈរជើងបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រូវទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់តាមច្រករបៀងផ្សេងៗ

https://freshnewsasia.com/index.php/en/localnews/283968-2023-03-25-08-29-02.html 2023-03-25 03:29pm

**(បន្ទាយមានជ័យ)៖** ឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ និងជាមេបញ្ជាការប្រចាំទិសខេត្តបន្ទាយមានជ័យ បានដាស់តឿនកងកម្លាំងឈរជើងបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រូវសហការទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់តាមច្រករបៀងផ្សេងៗ។

លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ ដាស់តឿនបែបនេះ ក្នុងពិធីបូកសរុបលទ្ធផលការងារយោធាសន្តិសុខឆ្នាំ ២០២១ និងផ្សព្វផ្សាយផែនការសកម្មភាពការងារយោធាសន្តិសុខឆ្នាំ២០២២ នៅទីបញ្ជាការដ្ឋានកងការពារព្រំដែន លេខ៥០៣ (ភ្នំខ្លែងពណ៌) នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។ ឧត្តមសេនីយ៍ បានផ្ដាំផ្ញើដល់កងកម្លាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ចូលរួមអនុវត្តការងារតាមផែនការថ្នាក់ដាក់ចុះ ចូលរួមសហការ

ការងារគ្រប់ស្ថាប័ន គ្រប់កងកម្លាំង ដើម្បីការពារការធ្វើដំណើររបស់ ប្រជាពលរដ្ឋខ្មែរត្រឡប់មកពីធ្វើការប្រទេសថៃ និងទប់ស្កាត់ប្រជាពលរដ្ឋដែលលួចចូលទៅធ្វើការប្រទេសថៃខុសច្បាប់។

លោកបានដាស់តឿនឱ្យចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះធម្មជាតិ ទឹកជំនន់ ខ្យល់កន្ត្រាក់ រលំផ្ទះដោយថាហេតុផ្សេងៗ។ ចូលរួមធ្វើការដឹកនាំបញ្ជា និងការងារត្រៀមប្រយុទ្ធដូចជា ការថែរក្សាស្តារប្រព័ន្ធលេណដ្ឋានដែលមានស្រាប់ និងថែរក្សានូវយុទ្ធោបករណ៍គ្រប់ប្រភេទដែលថ្នាក់លើបានផ្តល់ឲ្យ។ បំផុសចលនាឲ្យកងកម្លាំងចូលរួមរៀនសូត្រ និងធ្វើការហ្វឹកហ្វឺនឲ្យបានគ្រប់តាមផែនការដែលថ្នាក់លើដាក់ឲ្យចូលរួមធ្វើយុទ្ធដំណើរទ័ព និងចូលរួមនៅក្នុងការងារកសាងពង្រឹងអង្គភាពរឹងលើគ្រប់វិស័យ តាមរយៈការងារបង្កបង្កើន ផលដាំបន្លែបង្ការ ដើម្បីបម្រើផ្ទះបាយ ជាពិសេសហូបស្អាតរស់នៅស្អាត៕

## ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជាបាននិយាយថា ទំនាក់ទំនងល្អរវាងម៉ាឡេស៊ី និងកម្ពុជាបានជួយដោះស្រាយបញ្ហាក្រុមឆបោក

https://www.khmertimeskh.com/501262927//?p=1262927 Khmer Times March 27, 2023

ទំនាក់ទំនងដ៏ស្និទ្ធស្នាល ដែលត្រូវបានបង្កើតឡើងតាំងពីយូរយារណាស់មកហើយរវាងម៉ាឡេស៊ី និងកម្ពុជាបានជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់ស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជាក្នុងការដោះស្រាយបញ្ហានៃក្រុមឆបោកការងារ។ ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Datuk Eldeen Husaini Mohd Hashim បាននិយាយថា ទំនាក់ទំនងដ៏ល្អបានជួយសម្រួលដល់ស្ថានទូតក្នុងការជួយសង្គ្រោះជនជាតិម៉ាឡេស៊ីចំនួន ២៨៦ នាក់ ដែលជាជនរងគ្រោះនៃការបោកប្រាស់ការងារចន្លោះឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣។ លោកបានប្រាប់អ្នកយកព័ត៌មាននៅស្ថានទូតម៉ាឡេស៊ីថា "នៅឆ្នាំ២០២២ យើងបានជួយសង្គ្រោះមនុស្សចំនួន ២៥០នាក់ តាមរយៈការសម្របសម្រួលដ៏ល្អរវាងស្ថានទូតម៉ាឡេស៊ី និងនគរបាលកម្ពុជា" លោកបានប្រាប់អ្នកយកព័ត៌មាននៅស្ថានទូតម៉ាឡេស៊ីនៅទីនេះមុនដំណើរទស្សនកិច្ចផ្លូវការរបស់នាយករដ្ឋមន្ត្រី Datuk Seri Anwar Ibrahim នៅទីនេះនៅថ្ងៃស្អែក។ លោក Eldeen Husaini បានបន្តទៀតថា ម៉ាឡេស៊ី និងកម្ពុជា មិនត្រឹមតែមានទំនាក់ទំនងល្អរវាងរដ្ឋាភិបាលទាំងពីរប៉ុណ្ណោះទេ សូម្បីតែទំនាក់ទំនងរវាងប្រជាជន និងប្រជាជនក៏ល្អផងដែរ។

លោកបានបន្ថែមថា ទំនាក់ទំនងដ៏កក់ក្តៅនេះក៏បានឆ្លុះបញ្ចាំងតាមរយៈបេសកកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលបានទៅប្រទេសកម្ពុជាជាញឹកញាប់ដើម្បីជួយសហគមន៍ម៉ាឡេស៊ីឥស្លាមនៅទីនោះ។ លោកបាននិយាយទៀតថា "ក្រៅពីនោះ ប្រជាជនម៉ាឡេស៊ីក៏បានទៅកម្ពុជា ដើម្បីប្រគល់គម្ពីគូអាន ជីកអណ្តូងសម្រាប់អោយសហគមន៍ប្រើប្រាស់ ក៏ដូចជាធ្វើពិធីបូជាផ្សេងៗ"។ លោក Eldeen Husaini បានបន្តទៀតថា ដំណើរទស្សនកិច្ចលើកដំបូងរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ីនៅថ្ងៃនេះ ក៏បានឆ្លុះបញ្ចាំងពីទំនាក់ទំនងជិតស្និទ្ធរវាងទីក្រុងភ្នំពេញ និងទីក្រុងគូឡាឡាំពួ ដែលនឹងបន្តពង្រឹងនៅក្នុងកិច្ចសហប្រតិបត្តិការដែលមានស្រាប់ក្នុងវិស័យផ្សេងៗ។ លោក Eldeen Husaini បន្ថែមទៀតថា ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួនពីររវាងម៉ាឡេស៊ី និងកម្ពុជា ស្តីពីការជ្រើសរើស ការងារ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករកម្ពុជាសម្រាប់ការងារក្នុងស្រុក និងផ្លូវការនៅក្នុងប្រទេសម៉ាឡេស៊ី។

លោកបានបន្តថា៖ «អនុស្សរណៈនៃការយោគយល់គ្នាស្តីពីពលករធ្វើការក្នុងស្រុក និងផ្លូវការគឺមានប្រយោជន៍ណាស់ ដោយសារធ្លាប់ត្រូវបានផ្អាកក្រោមហេតុផលមួយចំនួន ហើយឥឡូវនេះអនុស្សរណៈនៃការយោគយល់គ្នា នឹងជួយម៉ាឡេស៊ីធ្វើអោយមានសេដ្ឋកិច្ចរីកចម្រើន ពីព្រោះយើងនឹងទទួលបានសេវាកម្មពីនយោជិតខ្មែរដែលទៅធ្វើការនៅម៉ាឡេស៊ី»។ លោកបានបន្តថា បច្ចុប្បន្នមានជនជាតិម៉ាឡេស៊ីប្រមាណ ៥០០០ នាក់នៅកម្ពុជា

ហើយពួកគេភាគច្រើនជាអ្នកជំនួញជោគជ័យ។ លោក Eldeen Husaini បាននិយាយថា មានក្រុមហ៊ុនម៉ាឡេស៊ីប្រហែល ៤០០ ក្រុមហ៊ុនកំពុងប្រតិបត្តិការនៅកម្ពុជា។

ដំណើរទស្សនកិច្ចផ្លូវការរយៈពេលមួយថ្ងៃរបស់លោកនាយករដ្ឋមន្ត្រី Anwar មកកាន់ប្រទេសកម្ពុជនឹងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងម៉ាឡេស៊ី និងកម្ពុជា ចាប់តាំងពីឆ្នាំ១៩៥៧ ហើយនេះជាដំណើរទស្សនកិច្ចផ្លូវការនៅបរទេសលើកទី៧ របស់លោកចាប់តាំងពីលោកត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខែវិច្ឆិកាឆ្នាំមុន។ *Bernama*

## នាយករដ្ឋមន្ត្រីម៉ាឡេស៊ី
## នឹងធ្វើជាសាក្សីក្នុងពិធីចុះកិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករកម្ពុជា

https://www.khmertimeskh.com/501262941/-5/ Khmer Times March 27, 2023

កិច្ចព្រមព្រៀងចំនួនពីរស្តីពីការជ្រើសរើសពលករកម្ពុជានឹងត្រូវចុះហត្ថលេខានៅចំពោះមុខលោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី Anwar Ibrahim ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរយៈពេលមួយ១ថ្ងៃនៅប្រទេសកម្ពុជា។ នេះជាដំណើរទស្សនកិច្ចផ្លូវការលើកដំបូងរបស់លោកនៅកម្ពុជា និងជាទស្សនកិច្ចក្រៅប្រទេសជាលើកទី៧របស់លោកចាប់តាំងពីលោកឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីកាលពីឆ្នាំមុន។

លោក Zambry Abdul Kadir រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ី បាននិយាយថា ដំណើរទស្សនកិច្ចនេះគឺតបតាមការអញ្ជើញរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោកនាយករដ្ឋមន្ត្រី Anwar នឹងចូលក្រាបបង្គំគាល់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ ហើយនឹងធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន២ស្តីពីការជ្រើសរើសពលករកម្ពុជា។ លោក Anwar Ibrahim នឹងចូលរួមជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងពិធីលៀងសាយភោជន៍ស្រាយបួសរបស់សាសនិកអ៊ិស្លាមផងដែរ។

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Datuk Eldeen Husaini Mohd Hashim បាននិយាយថា ទំនាក់ទំនងដ៏ស្និទ្ធស្នាលរវាងប្រទេសទាំងពីរបានធ្វើឱ្យស្ថានទូតម៉ាឡេស៊ីនៅទីក្រុងភ្នំពេញជួយសង្គ្រោះប្រជាជនម៉ាឡេស៊ីចំនួន ២៨៦ នាក់ដែលបានចាញ់បោកក្រុមឆបោកការងារ។ លោកបានបន្តថា៖ «នៅឆ្នាំ ២០២២ យើងបានសង្គ្រោះមនុស្សចំនួន ២៥០ នាក់តាមរយៈការសម្របសម្រួលល្អរវាងស្ថានទូតម៉ាឡេស៊ី និងនគរបាលកម្ពុជា។ មានជនជាតិម៉ាឡេស៊ីប្រហែល ៥,០០០ នាក់នៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនជាអ្នកជំនួញជោគជ័យ។ លោកបានបន្ថែមថា មានក្រុមហ៊ុនម៉ាឡេស៊ីប្រហែល ៤០០ កំពុងប្រតិបត្តិការនៅកម្ពុជា។ *freemalaysiantoday*

# ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០២៣

## មន្ត្រីកាកបាទក្រហមកម្ពុជា អំពាវនាវឱ្យយកចិត្តទុកដាក់លើការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញ

https://www.postkhmer.com/national/2023-03-26-1839-248433.html នាង សុគន្ធា | Publication date 26 March 2023 | 18:39 ICT

**បាត់ដំបង:** មន្ត្រីកាកបាទក្រហមកម្ពុជាប្រចាំខេត្តបាត់ដំបង បានអំពាវនាវទៅដល់អាណាព្យាបាល លោកគ្រូអ្នកគ្រូទាំងអស់ ត្រូវយកចិត្តទុកដាក់ និងមានវិធានការការពារកូនៗ យុវជន សិស្សានុសិស្ស ពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។

លោក យ៉ាន ឧត្តម នាយករងសាខាកាកបាទក្រហមកម្ពុជាខេត្តបាត់ដំបង បានធ្វើការអំពាវនាវបែបនេះក្នុងពេលចុះផ្សព្វផ្សាយស្ដីពីការចូលរួមការពារកុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញក្នុងគ្រឹះស្ថានសិក្សា ទៅដល់យុវជន កាកបាទក្រហមកម្ពុជា សិស្សានុសិស្សជាង ៧០នាក់នៃវិទ្យាល័យនេតយ៉ង់ក្រុងបាត់ដំបង នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។ លោកលើកឡើងថា វគ្គផ្សព្វផ្សាយនេះធ្វើឡើងដើម្បីចែករំលែកឱ្យយុវជន កាកបាទក្រហមកម្ពុជា បានយល់ដឹង និងយកចិត្តទុកដាក់ប្រុងប្រយ័ត្នបន្ថែមទៀត ចំពោះកុមារក្នុងសម័យកាលរីកចម្រើនផ្នែកបច្ចេកវិទ្យាទំនើបយ៉ាងទូលំទូលាយ ដែលអាចឱ្យកុមារងាយជឿតាមការអូសទាញ ការលួងលោមចាញ់បោកគេធ្លាក់ចូលក្នុងការរំលោភបំពានផ្លូវភេទ និងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ។

លោក យ៉ាន ឧត្តម មានប្រសាសន៍ថា ៖ «សូមអំពាវនាវឱ្យអាណាព្យាបាលទាំងអស់ គួរមានវិធានការការពារកូនៗពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដោយអប់រំកូនឱ្យយល់អំពីអ្វីជាសុវត្ថិភាព និងគ្មានសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ និងណែនាំកូនឱ្យកត់សម្គាល់មនុស្សដែលអាចនាំគ្រោះថ្នាក់ពេលអនឡាញ»។ លោកបន្តថា ៖ «ត្រូវបង្ហាញកូនៗពីរបៀបការប្រើប្រាស់ឯកជនភាព របស់ពួកគេ តាមអនឡាញ, អាចឱ្យកូនៗដឹងពីបច្ចេកវិទ្យា តែក៏ត្រូវផ្ដល់ដំបូន្មានដើម្បីកែឥរិយាបថ ពួកគេ ពេលអនឡាញ និងបង្ហាញកូនៗពីការយកចិត្តទុកដាក់របស់អ្នក ហើយស្ដាប់ពីបញ្ហារបស់ពួកគេពីការប្រើប្រាស់ប្រព័ន្ធអញឡាញនេះ»។ កុមារដែលរងការរំលោភបំពានឬការកេងប្រវ័ញ្ចផ្លូវភេទ នឹងរងការប៉ះទង្គិចធ្ងន់ធ្ងរ ទាំងលើផ្លូវកាយ និងផ្លូវចិត្ត ដោយពួកគេភាគច្រើន អាចនឹងមានអារម្មណ៍ពិបាក ទុកចិត្តអ្នកដទៃ អស់សង្ឃឹម បាក់ទឹកចិត្ត ឯកា និងភ័យខ្លាចជាដើម។ នេះបើតាម លោក យ៉ាន ឧត្តម។

ការផ្សព្វផ្សាយដូចគ្នានេះដែរ ក៏ត្រូវបានសាខាកាកបាទក្រហមកម្ពុជាខេត្តពោធិ៍សាត់ រៀបចំឡើង មានរយៈពេល៣ថ្ងៃ ស្ដីពី «ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទ តាមអនឡាញ និងឥរិយាបថអវិជ្ជមានរបស់សង្គមលើកុមារមានពិការភាព» ដោយមានការចូលរួមពីយុវជន និងសិស្សានុសិស្សប្រមាណ២០០នាក់។ ទាក់ទងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញនេះ កាលពីចុងខែកញ្ញា ឆ្នាំ២០២២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា បានចេញនូវរបាយការណ៍មួយដែលមានឈ្មោះថា ការបញ្ឈប់គ្រោះថ្នាក់ក្នុងប្រទេសកម្ពុជា (Disrupting Harm in Cambodia)។ ក្នុងរបាយការណ៍នោះបានរកឃើញថា កុមារដែលប្រើប្រាស់អ៊ីនធឺណិតចំនួន១១% អាយុចន្លោះពី ១២-១៧ ឆ្នាំ ធ្លាប់ទទួលរងនូវការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញក្នុងទម្រង់មួយចំនួនជាក់លាក់ នៅឆ្នាំមុនពេលការអង្កេតនេះចាប់ផ្ដើម។

ប្រសិនបើគិតតាមចំនួនប្រជាជនកម្ពុជានៅក្នុងក្រុមអាយុនេះ នោះវាបង្ហាញឱ្យឃើញថា មានកុមារប្រមាណ ១៦០ ០០០ នាក់ធ្លាប់បានទទួលរងការបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ បើតាមរបាយការណ៍នេះ កុមារចំនួន ១៦% បានរងគ្រោះពីការបញ្ចេញមតិពាក់ព័ន្ធផ្លូវភេទមកលើខ្លួន ដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនពេញចិត្ត ហើយក្នុងនោះ មានកុមារចំនួន ៣១% បាននិយាយថា វាបានកើតឡើងនៅលើបណ្តាញផ្សព្វផ្សាយសង្គម។ ប្រភពដដែលថា កុមារចំនួន ១៦% ត្រូវបានគេផ្ញើរូបភាពអាសអាភាសឱ្យ ដែលពួកគេមិនចង់បាន ហើយក្នុងនោះ មានកុមារចំនួន ៣៦% បាននិយាយថា ពួកគេបានទទួលរូបភាពទាំងនោះ នៅលើបណ្តាញផ្សព្វផ្សាយសង្គម៕

## កម្ពុជា-ម៉ាឡេស៊ីចុះអនុស្សារណៈស្តីពីការជ្រើសរើស និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ

https://www.kampucheathmey.com/local-news/485184 ថ្ងៃចន្ទ ២៧ មីនា ២០២៣ដោយ deth leng

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងលោក ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ីនៅព្រឹកថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣ បានអញ្ជើញធ្វើជាសហធិបតីចុះហត្ថលេខាលើឯកសារចំនួន២ បន្ទាប់ពីបញ្ចប់ជំនួបពិភាក្សាទ្វេភាគី ទី១ គឺអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។ ទី២ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករធ្វើការងារផ្ទះ។

ជាមួយគ្នានោះថ្នាក់ដឹកនាំទាំងពីរក៏បានជជែកពិភាក្សាគ្នាអំពី វិនិយោគ ការធ្វើពាណិជ្ជកម្ម ទេសចរណ៍ ថាមពល ក៏ដូចជាការជំរុញលើកទឹកចិត្តការវិនិយោគ រវាងប្រទេសទាំងពីរផងដែរ។ លោក ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី នៅព្រឹកថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣នេះ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា៕

## អង្គការ សមាគមក្រៅរដ្ឋាភិបាលបើកវេទិកាពិភាក្សាការលុបបំបាត់អំពើហិង្សា និងការបៀតបៀនលើស្ត្រី និងក្មេងស្រីនៅកម្ពុជា

https://www.postkhmer.com/national/2023-03-26-1821-248432.html អោម ប៊ុនធឿន | Publication date 26 March 2023 | 18:21 ICT

**ភ្នំពេញៈ** អង្គការ សមាគមក្រៅរដ្ឋាភិបាលចំនួន ៩ រៀបចំវេទិកាស្ត្រីក្រោមប្រធានបទ «លុបបំបាត់អំពើហិង្សា និងការបៀតបៀនលើស្ត្រី និងក្មេងស្រីនៅកម្ពុជា» ធ្វើឡើងនៅភោជនីយដ្ឋានទន្លេបាសាក់ ២ នៅថ្ងៃទី ២៦ ខែមីនានេះ ដើម្បីទាមទារឱ្យលុបបំបាត់រាល់ទម្រង់ នៃអំពើហិង្សា និងការបៀតបៀនលើស្ត្រី និងក្មេងស្រី។

លោកស្រី លាវ លីណា មន្ត្រីកម្មវិធី នៃអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ បានឱ្យដឹងថា វេទិការនេះរៀបចំឡើងដោយ សមាគមមណ្ឌលព័ត៌មានកម្មករ សមាគមក្រុមតន្ត្រីយុវវ័យនាំសារ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា និងអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ សហការជាមួយ បណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ។ លោកស្រីបន្តថា វេទិកានេះដែរធ្វើឡើងក្នុងបំណងទី១ អបអរសាទរទិវាអន្តរជាតិនារីខួបលើកទី១១២ និងរំឭកពីវីរភាពស្ត្រីក្នុងការតស៊ូទាមទារសិទ្ធិ និងសេរីភាពសម្រាប់ស្ត្រីទូទាំងពិភពលោក ទី២ បង្កើតឱកាស ឬលម្ហ ក្នុងការបង្ហាញសំឡេងស្ត្រី អំពីអំពើហិង្សា និង បៀតបៀនលើស្ត្រី និងក្មេងស្រីនៅកម្ពុជា និងទី៣ ទាមទារឱ្យលុបបំបាត់រាល់ទម្រង់ នៃអំពើហិង្សា និងការបៀតបៀនលើស្ត្រី និងក្មេងស្រីផងដែរ។ លោកស្រី លាវ លីណា បានឱ្យដឹងថា ក្នុងវេទិកានេះមានអ្នកចូលរួមប្រមាណ ៣០០នាក់ រួមមានប្រជា

សហគមន៍មូលដ្ឋានមកពីគ្រប់វិស័យ សិស្ស និស្សិត អង្គការដៃគូ រួមទាំងមន្ត្រីរដ្ឋាភិបាលផងដែរ។ អង្គការសមាគមក្រៅរដ្ឋាភិបាលបានស្នើសុំទៅមន្ត្រីរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាមួយចំនួនដូចជា ស្នើសុំឱ្យលុបបំបាត់អំពើហិង្សានិងការបៀតបៀន គ្រប់ទម្រង់និងរូបភាពទៅលើស្ត្រី សកម្មជនដីធ្លីជាស្ត្រី និងក្មេងស្រី និងសូមបញ្ឈប់ប្រើប្រព័ន្ធតុលាការមកលើស្ត្រីជាសកម្មជនដីធ្លី។

ជាមួយគ្នានោះ ក៏មានការស្នើឱ្យពេងចក្ររៀបចំកន្លែងសម្រាប់ស្ត្រីហ៊ាននិយាយចេញពីបញ្ហាការបៀតបៀននៅកន្លែងការងារប្រកបដោយប្រសិទ្ធភាព និងស្នើឱ្យអាជ្ញាធរដែនដីពង្រឹងគោលនយោបាយក្នុងមូលដ្ឋានពីស្ថានភាពរស់នៅរបស់កម្មករឱ្យកាន់តែរឹងមាំសម្រាប់ប្រជាពលរដ្ឋរស់នៅដោយមានសុវត្ថិភាពជានិរន្តរ៍ជាដើម។ លោកស្រី លាវ លីណា មន្ត្រីកម្មវិធី នៃអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ ដែលបានដកស្រង់សម្ដី លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ថ្លែងក្នុងវេទិកានោះថា ជាការឆ្លើយតបចំពោះការស្នើសុំក្រសួងបានដឹងពីបញ្ហាទាំងនោះ និងបាននិងកំពុងដោះស្រាយជាបន្តបន្ទាប់បន្ថែមទៀត។

តាមរបាយការណ៍សង្ខេបពីលទ្ធផលនៃការស្ទង់មតិពី «ស្វែងយល់ពីបទពិសោធន៍ស្ត្រី និងក្មេងស្រីពីការបៀតបៀននៅកម្ពុជា» ដែលរៀបចំដោយ អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ និងសមាគមមណ្ឌលព័ត៌មានកម្មករ ជាមួយស្ត្រី និងក្មេងស្រីចំនួន៣៧០នាក់ បង្ហាញថា ក្នុងចំណោមអ្នកចូលរួម ២៤១នាក់ (៦៤.៨ភាគរយ) ធ្លាប់ទទួលរងការបៀតបៀន។ ក្នុងចំណោមអ្នករងគ្រោះពីការបៀតបៀននេះផងដែរ ស្ត្រី និងក្មេងស្រី ដែលរងគ្រោះពីការបៀតបៀន ស្ត្រីចំនួន១៤៩នាក់ (៦៣.១ភាគរយ) ធ្លាប់ទទួលរងការបៀតបៀនលើសពី ៣ដងមុនពេលនៃការចូលរួមក្នុងការស្ទង់មតិ។ ខេត្តក្រុងដែលអ្នកផ្ដល់កិច្ចសម្ភាសន៍នេះមាន រាជធានីភ្នំពេញ កំពង់ឆ្នាំង កំពង់ចាម ព្រះសីហនុ ត្បូងឃ្មុំ កំពង់ស្ពឺ បាត់ដំបង និង កំពង់ធំ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. ថ្លែងកាលពីថ្ងៃទី២៣ ខែមីនាថា ក្នុងឆ្នាំ២០២២ សមត្ថកិច្ចបង្ក្រាបករណីជួញដូរមនុស្សបាន១៦៦ករណី ធៀបនឹងឆ្នាំ២០២១ មាន៣៥៩ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន២០២នាក់ ក្នុងនោះជនសង្ស័យជាជនបរទេសចំនួន៣៣នាក់។ លោកស្រីបន្តថាសមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ៣៥៨នាក់ ក្នុងនោះស្រីចំនួន២៦៥នាក់ ដោយប្រគល់ជូនមន្ទីរសង្គមកិច្ច និងក្រុមគ្រួសារ។ ការថ្លែងរបស់រដ្ឋលេខាធិការក្រសួងមហាផ្ទៃនេះធ្វើឡើង ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ ២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រារព្ធនៅវិទ្យាស្ថានជាតិអប់រំ៕

## សម្ដេចតេជោ ស្នើម៉ាឡេស៊ី បន្តអនុវត្តយន្តការមានសម្រាប់ ដើម្បីការពារសិទ្ធិពលករកម្ពុជា

https://dap-news.com/national/2023/03/27/321415/ ByTR110Posted on March 27, 2023

ភ្នំពេញ ៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានស្នើម៉ាឡេស៊ី បន្តអនុវត្តយន្តការដែលមានសម្រាប់ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិពលករកម្ពុជា ធ្វើការងារនៅម៉ាឡេស៊ី។

ក្រោយបញ្ចប់ពិធីចុះហត្ថលេខា កម្ពុជា-ម៉ាឡេស៊ី ជាមួយលោក ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម (Anwar bin Ibrahim) នាយករដ្ឋមន្ត្រីម៉ាឡេស៊ី អញ្ជើញធ្វើសន្និសីទរួមគ្នា នាថ្ងៃ២៧ មីនា សម្ដេចតេជោថ្លែងថា «ចំពោះវិស័យការងារ ខ្ញុំក៏បានស្នើបន្តអនុវត្តយន្តការដែលមានសម្រាប់ ដើម្បីលើកកម្ពស់ការការពារសិទ្ធិពលករកម្ពុជាដែលកម្ពុជា ធ្វើការនៅប្រទេសម៉ាឡេស៊ី»។ ក្នុងវិស័យថាមពលរ សម្ដេចតេជោ បានស្នើនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ផ្ដល់ការគាំទ្រដល់ការស្ថាបនាខ្សែរកាប់អគ្គិសនី តាមបាតសមុទ្រ ដែលត្រូវឆ្លងកាត់ដែនសមុទ្រប្រទេសម៉ាឡេស៊ី សម្រាប់គម្រោងពាណិជ្ជកម្មថាមពលប៉ែតងរវាង កម្ពុជា-សង្ហិបូរី។ លើសពីនេះ សម្ដេច នាយករដ្ឋមន្ត្រី ក៏បានលើកទឹកចិត្ត

អ្នកវិនិយោគគិនម៉ាឡេស៊ី ឲ្យចូលរួមអភិវឌ្ឍឧស្សាហកម្ម ផលិតកម្ម ឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មផ្អែកចំណេះដឹង និងបច្ចេកវិទ្យា ជាដើម នៅកម្ពុជា។

ពាក់ព័ន្ធវិស័យការពារ និងសន្តិសុខ ភាគីទាំងពីរ បានឯកភាពគ្នា ពង្រឹងកិច្ចសហប្រតិបត្តិការរវាង ស្ថាប័នពាក់ព័ន្ធ ការផ្លាស់ប្តូរគណៈប្រតិភូជំនាញ ដើម្បីដកពិសោធន៍ការងារប្រឆាំងការរត់ពន្ធ និងជួញដូរមនុស្ស ការងារសម្អាតប្រាក់ ព្រមទាំងពិចារណាឲ្យអនុស្សរណៈយោគយល់គ្នារវាង អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងនគរបាលជាតិម៉ាឡេស៊ី ស្តីពីសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។ សម្តេចតេជោ បន្តថា ក្រៅពីកិច្ចការងារទាំងពីរខាងលើនេះ នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានឯកភាពបន្តជំរុញសហប្រតិបត្តិការលើវិស័យព័ត៌មាន និងវិស័យទូរគមនាគមន៍ សេដ្ឋកិច្ច ឌីជីថល និងប្រព័ន្ធអ៊ីធឺណែតថែមទៀត៕

## ក្រសួងសង្គមកិច្ចនិងJICA
## ប្តេជ្ញាពង្រឹងកិច្ចសហការលើគម្រោងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://btv.com.kh/article/21629 2023/03/27 04:22:57 pm

ភ្នំពេញ៖ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅព្រឹកថ្ងៃទី២៧ ខែមីនានេះ បានទទួលពិភាក្សាការងារ ជាមួយលោកស្រី Kamei Haruko ប្រធានតំណាងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA) ប្រចាំនៅកម្ពុជា មុននឹងលោកស្រីបញ្ចប់អាណត្តិនៅកម្ពុជា។

នៅក្នុងឱកាសនោះលោកស្រី Kamei Haruko មានប្រសាសន៍ថា លោកស្រីមានក្តីសោមនស្សរីករាយជាពន់ពេក ដោយឆ្នាំនេះជាខួបលើកទី៧០ នៃចំណងមិត្តភាពរវាងប្រទេសជប៉ុន និងកម្ពុជា ហើយលោកស្រីពិតជាមានក្តីរំភើបរីករាយដែលបានមកបំពេញបេសកម្មនៅប្រទេសកម្ពុជា។ លើសពីនេះ លោកស្រីបានស្នើរដល់មន្ត្រីក្រសួងសង្គមកិច្ច ពង្រឹងកិច្ចសហការជាមួយអ្នកជំនាញ JICA បន្ថែមទៀតលើគម្រោងពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដើម្បីឱ្យគម្រោងនេះ ទទួលបានផលជាវិជ្ជមាននៅពេលអនាគត។

ជាការឆ្លើយតប ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានប្រសាសន៍ថា ការជួញដូរមនុស្សជារឿងមួយដ៏ស្មុគស្មាញដែលទាមទារឱ្យភាគីពាក់ព័ន្ធត្រូវចូលរួមទាំងអស់គ្នា ព្រោះថាករណីជួញដូរមនុស្ស ប្រព្រឹត្តិទៅជាប្រព័ន្ធពីប្រទេសមួយទៅប្រទេសមួយ។ តែយ៉ាងណាក្តីក្រសួងសង្គមកិច្ច នឹងបន្តពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ រាប់បញ្ចូលទាំងអង្គការJICAដែរ ដើម្បីទប់ស្កាត់ការជួយដូរមនុស្ស។

ក្រៅពីនេះ ឯកឧត្តមរដ្ឋមន្ត្រី បានថ្លែងអំណរអរគុណដល់អង្គការJICA តំណាងរាជរដ្ឋាភិបាលជប៉ុន ដែលកន្លងទៅតែជួយប្រជាជន និងប្រទេសកម្ពុជា។ ប្រទេសកម្ពុជា និងប្រទេសជប៉ុន បានបង្កើតទំនាក់ទំនងការទូតផ្លូវការនៅឆ្នាំ១៩៥៣។ ចាប់តាំងពីការបង្កើតទំនាក់ទំនងនេះមក ប្រទេសជប៉ុនបានផ្តល់ជំនួយជាច្រើនដល់ប្រទេសកម្ពុជា ដែលក្នុងនោះរួមមាន៖ ការកសាងផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ និងការបណ្តុះធនធានមនុស្សជាដើម៕ អត្ថបទ៖ទូច សោភ័ណ

# កម្ពុជា និងម៉ាឡេស៊ី ឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការប្រឆាំង នឹងការរត់ពន្ធ ការជួញដូរមនុស្ស និងសំអាតប្រាក់

https://cen.com.kh/archives/640038.html Posted ByPen Srey NeatMarch 27, 2023

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ នេះ បន្ទាប់ពីពិធីទទួលបដិសណ្ឋាកិច្ចរួចរាល់នោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី បានអញ្ជើញជួបប្រជុំទ្វេភាគី ដែលធ្វើឡើងនៅវិមានសន្តិភាព។ ក្នុងជំនួបប្រជុំទ្វេភាគីនោះផងដែរ នាយករដ្ឋមន្ត្រីប្រទេសទាំងពីរ បានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅទៅលើការពង្រឹងទំនាក់ទំនងទ្វេភាគី ឲ្យកាន់តែប្រសើរឡើងបន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរបានរិះរកវិធីសាស្ត្រថ្មីៗ សំដៅធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត នូវទំនាក់ទំនងទ្វេភាគីដ៏យូរលង់ ដែលគ្របដណ្តប់លើកិច្ចសហប្រតិបត្តិការ គ្រប់វិស័យ ដូចជា៖ នយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គម និងវប្បធម៌ជាដើម។ នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈគ្នា ទៅវិញទៅមកលើបញ្ហាអនុតំបន់ តំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ និងក្តីបារម្ភរួមផងដែរ។

ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ក៏បានបញ្ជាក់ថា ឯកឧត្តមពិតជារីករាយដែល បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា និងអរគុណដល់សម្តេចតេជោ ដែលបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជាទីបំផុត។ ឯកឧត្តមបានមានប្រសាសន៍បន្តថា សម្តេចតេជោ ហ៊ុន សែន ជាថ្នាក់ដឹកនាំដ៏មានបទពិសោធន៍ទូលំទូលាយ និងបានចូលរួមដោះស្រាយបញ្ហាស្មុគស្មាញភាគច្រើន ដូចជាបញ្ហាមីយ៉ាន់ម៉ា ជាពិសេសការរក្សាបានសន្តិភាពនៅកម្ពុជា ហើយប្រសិនបើប្រៀបធៀបទៅនឹងស្ថានភាពនៅមីយ៉ាន់ម៉ា បច្ចុប្បន្ននេះ នេះជាឧទាហរណ៍ ១ដ៏ល្អអស្ចារ្យ ដែលកម្ពុជាជាប្រទេសមួយដែលធ្លាប់ញាំញីដោយសង្គ្រាមស៊ីវិល ហើយទីបំផុតទទួលបានសន្តិភាពយ៉ាងពេញលេញ ហើយឯកឧត្តមក៏ទន្ទឹងរង់ចាំការចូលរួមចំណែករបស់សម្តេច នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន នាពេលខាងមុខ ដើម្បីពិភាក្សាផ្តល់នូវទស្សនៈមួយចំនួននៅក្នុងក្របខណ្ឌគ្រប់ជ្រុងជ្រោយ ដើម្បីបង្ហាញការដោះស្រាយបញ្ហាមីយ៉ាន់ម៉ា អំពីរដ្ឋបាលយោធា របស់មីយ៉ាន់ម៉ា ឲ្យយល់អំពីថា បញ្ហានេះ មិនត្រូវបន្តដោយមិនមានដំណោះស្រាយនោះទេ ហើយបញ្ហាសមុទ្រចិនខាងត្បូង បញ្ហារុស្ស៊ី អ៊ុយក្រែន បញ្ហាឧបទ្វីបកូរ៉េ បញ្ហាតៃវ៉ាន់ និងចិនជាដើម គឺសម្តេច និងឯកឧត្តម ពិតជាមានទស្សនៈដូចគ្នា។ ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម បានថ្លែងនូវការកោតសរសើរ ការដឹកនាំរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលធ្វើឲ្យប្រទេសកម្ពុជាបានបញ្ចប់នូវសង្គ្រាម និងមានភាពរីកចម្រើន។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា កម្ពុជា និងម៉ាឡេស៊ី បានធ្វើការពិភាក្សាលើកិច្ចការជាច្រើន ក្នុងនោះបានឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការប្រឆាំង នឹងការរត់ពន្ធ ការជួញដូរមនុស្ស និងសំអាតប្រាក់រួមទាំងការពិចារណាបង្កើតឱ្យមានអនុស្សារណៈយោគយល់គ្នារវាងនគរបាលនៃប្រទេសទាំង២ផងដែរ។ ជាមួយគ្នានោះ ថ្នាក់ដឹកនាំទាំងពីរ ក៏បានលើកឡើងយ៉ាងទូលំទូលាយពាក់ព័ន្ធទៅនឹងបញ្ហាសេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគក៏ដូចជាបញ្ហាតំបន់ និងអន្តរជាតិផងដែរ។ សម្តេចតេជោ ហ៊ុន សែន បានស្នើទៅកាន់ប្រទេសម៉ាឡេស៊ី តាមរយៈឯកឧត្តមនាយករដ្ឋមន្ត្រី អាន់វ៉ា អ៊ីប្រាហ៊ីម ឱ្យបង្កើនការទិញអង្ករ គ្រាប់ស្វាយចន្ទី ក៏ដូចជាកសិផលផ្សេងទៀតពីប្រទេសកម្ពុជា ហើយកម្ពុជាក៏នឹងជំរុញបង្កើនការនាំចេញទៅប្រទេសម៉ាឡេស៊ីបន្ថែមទៀតឱ្យបានច្រើនឡើង។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានស្នើប្រទេសម៉ាឡេស៊ី ជួយគាំទ្រដល់ការស្ថាបនាខ្សែកាបអគ្គិសនីតាមបាតសមុទ្រ ដែលត្រូវឆ្លងកាត់ដែនសមុទ្រប្រទេសម៉ាឡេស៊ី សម្រាប់គម្រោងពាណិជ្ជកម្មថាមពលបៃតងរវាងកម្ពុជា-សិង្ហបុរី។

សម្តេចតេជោបានថ្លែងរំលឹកដល់អនុស្សាវរីយ៍ដ៏គួរឲ្យចងចាំ គឺជាការស្គាល់គ្នាជាមួយឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី តាំងពីឆ្នាំ១៩៩៦មកម្ល៉េះ ដែលកាលនោះឯកឧត្តម អាន់វ៉ា បានរៀបចំពិសាអាហារមួយពេលជូនសម្តេចនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ហើយបើគិតមកដល់ពេលនេះ មានរយៈពេល ២៧ឆ្នាំមកហើយ។ សម្តេចតេជោបានផ្តាំផ្ញើតាមរយៈឯកឧត្តមអាន់វ៉ា ផ្តាំផ្ញើនូវការសាកសួរសុខទុក្ខពីភរិយាសម្តេច ជូនដល់ភរិយាឯកឧត្តម អាន់វ៉ា ផងដែរ ព្រោះតែភរិយានាយករដ្ឋមន្ត្រីទាំងពីរ មានជោគវាសនាប្រហាក់ប្រហែលគ្នា នៅពេលប្តីជួបទុក្ខលំបាក ភរិយាត្រូវទទួលអំរែកទាំងអស់ក្នុងគ្រួសារ។ ថ្នាក់ដឹកនាំទាំងពីរក៏បានជជែកពិភាក្សាគ្នាអំពី វិនិយោគ ការធ្វើពាណិជ្ជកម្ម ទេសចរណ៍ ថាមពល ក៏ដូចជាការជំរុញលើកទឹកចិត្តការវិនិយោគ រវាងប្រទេសទាំងពីរផងដែរ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

# ថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០២៣

## នាយករដ្ឋមន្ត្រីម៉ាឡេស៊ី អរគុណកម្ពុជាដែលបានជួយពលករខ្លួនចាញ់បោកគេជាង ៣០០នាក់

https://www.rfi.fr/km//20230327-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 27/03/2023 - 13:47

ជំនួបទ្វេភាគីរវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម (Anwar Ibrahim)នៅវិមានសន្តិភាពនាថ្ងៃចន្ទនេះ ភាគីទាំងពីរបានពិភាក្សាលើរបៀបវារៈជាច្រើន និងមានការវាយតម្លៃខ្ពស់លើទំនាក់ទំនងកម្ពុជា-ម៉ាឡេស៊ី ព្រមទាំងប្តេជ្ញាលើកកម្ពស់បន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ ជំនួបទ្វេភាគីនេះ បានធ្វើឡើងខណៈដែលលោក អាន់វ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីថ្មីម៉ាឡេស៊ី បានធ្វើទស្សនកិច្ចរយៈពេល១ថ្ងៃនៅកម្ពុជា។ ក្នុងចំណោមវិស័យសំខាន់ៗ ដែលនាយករដ្ឋមន្ត្រីទាំងពីរលើកយកមកពិភាក្សា បញ្ហាការងារ និងភាពរងគ្រោះរបស់ពលករនៃប្រទេសទាំងពីរក៏ត្រូវបានយកមកជជែកគ្នាផងដែរ។

## ជីវិតពលករខ្មែរធ្វើការលើទូកនេសាទនៅប្រទេសថៃ

https://www.rfa.org/khmer/news/social-economy/the-life-of-cambodian-workers-on-fishing-boat-in-thailand-03262023123043.html ដោយ សេក បណ្ឌិត2023.03.26

ពលករខ្មែរធ្វើការងារជាកម្មករនេសាទនៅប្រទេសថៃ ប្រឹងលក់កម្លាំង ដើម្បីបានកម្រៃផ្ញើប្រាក់ឱ្យសាច់ញាតិនៅស្រុកកំណើត។ យ៉ាងហោចណាស់ពលករខ្មែរជិត ៧.០០០នាក់ បានរងគ្រោះនៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងរងការជួញដូរជាដើម។ នៅលើសមុទ្រល្វឹងល្វើយ ទូកនេសាទរាប់រយគ្រឿងចតនៅផែមួយកន្លែងក្នុងខេត្តរ៉ាយ៉ង(RAYONG) ប្រទេសថៃ ត្រៀមចេញនេសាទ។ ពលករខ្មែរមួយក្រុម កំពុងធ្វើការងារយ៉ាងញាប់ដៃញាប់ជើង រៀបចំគ្រឿងសម្ភារៈដាក់ឡើងទូកត្រៀមចេញនេសាទ។

កំពុងចាក់ខ្សែចងដែកដាក់ជើងសំណាញ់លោក ឆេង ចាន់ណា អាយុ ៣៣ឆ្នាំ មកធ្វើលើទូកនេសាទនៅប្រទេសថៃ ជាង ២ឆ្នាំមកហើយ។ ពលករខ្មែរមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំងរូបនេះ ឱ្យវិទ្យុអាស៊ីសេរីដឹងថា ទូកនេសាទដែលលោកធ្វើការនេះ ចេញនេសាទម្តងៗពី ៨ថ្ងៃ ទៅ១០ថ្ងៃ។ លោកថា ការងារនេះប្រើកម្លាំងច្រើន ប៉ុន្តែបើជួបថៅកែល្អ ទោះហត់បន្តិចក្តីតែលោកអាចទទួលបានប្រាក់ឈ្នួលត្រឡប់មកវិញ។ លោក ឆេង ចាន់ណា ៖ «ពេលត្រីបានច្រើនហត់បងការងារនេះ»។ ការងារនៅលើទូកនេសាទនេះ ក្រុមពលករធ្វើការងារតាមជំនាញ និង

តាមចង្អុលបញ្ហាពីមេការខ្មែរគ្រប់គ្រងលើទូកនេះ។ ពេលពួកគាត់ធ្វើការងារជុំគ្នាម្ដងៗ ពួកគាត់ស្រែកជាសំនៀងពីរោះម្យ៉ាងដែរ។ ពួកគាត់ម្នាក់ៗចូលចិត្តពាក់ក្រវិល ចាក់សាក់នៅលើដៃ ឬដងខ្លួនមើលទៅរាងកាច តែតាមពិតពួកគាត់រួសរាយរាក់ទាក់ណាស់។

ពលករម្នាក់ទៀត លោក ឆាយ ស៊ីឡែន រៀបរាប់ថា លោកទទួលបានកម្រៃពីការងារគិតប្រាក់សរុបជាង ១ម៉ឺនបាត ឬជាង៣០០ដុល្លារក្នុងមួយខែ។ ទោះយ៉ាងណាលោកថា ថៅកែបើកប្រាក់ឱ្យលោក មួយខែតែជាង ៥ពាន់បាតទេ ដោយប្រាក់នៅសល់ផ្សេងទៀង ថៅកែទុកទូទាត់នៅរៀងរាល់ចុងឆ្នាំ។ លោកឱ្យដឹងទៀតថា ប្រាក់ឈ្នួលនៅទីនេះ បើទូកនៅមិនទាន់ចេញនេសាទ ថៅកែផ្ដល់ប្រាក់១០០បាតក្នុងមួយថ្ងៃ សម្រាប់ពលករម្នាក់ តែបើទូកចេញនេសាទអាចទទួលបានកម្រៃពី៤០០បាត ទៅ ៥០០បាតក្នុងមួយថ្ងៃ។ លោក ឆាយ ស៊ីឡែន៖ «ពេលយើងចាយៗយើងកត់បញ្ជីខ្លួនឯង ដល់ថ្ងៃយើងយកបញ្ជីទៅសរុបជាមួយគេ យើងចាយប៉ុន្មាន ១៨ខែ ឬ ១៥ខែហ្នឹងចាយអស់ប៉ុន្មាន ឧទាហរណ៍ថា បាន៣សែនបាតអ៊ីចឹងយើងចាយ ១សែនបាត នៅសល់ ១សែនជាង»។ ការគ្រប់គ្រងការងារលើទូកនេសាទនេះ ក្រៅពីមានកម្មករនេសាទ ក៏មានមេការមើលការខុសត្រូវដែរ។ នៅលើទូកនេះមេការជាជនជាតិខ្មែរដែរ។ នៅពេលផ្ដល់បទសម្ភាស ក្រុមកម្មករហាក់មានភាពភ័យខ្លាច ក្នុងការផ្ដល់សម្ភាស ទាក់ទងការបើកប្រាក់ឈ្នួល ការគោរពសិទ្ធិពលករ និងហូបចុកជាដើម។ ចំណែកមេការគ្រប់គ្រងលើទូកនេះ បានមកឈរតាមឃ្លាំមើលកម្មករនេសាទផ្ដល់សម្ភាសមកវិទ្យុអាស៊ីសេរី។

មេការទូកនេសាទលោក យាន រិទ្ធិ ជាអ្នកចាត់ចែងការងារទូទៅលើទូកនេះ។ លោក យាន រិទ្ធិ ឱ្យដឹងថា ទូកនេសាទនេះមានកម្មករជាង៤០នាក់ ដែលស្ទើរទាំងអស់ជាពលករខ្មែរ។ លោកថា ក្នុងនាមលោកជាមេការតែងតែយោគយល់ដល់កម្មករ ហើយបើអ្នកមកថ្មីមិនសូវចេះធ្វើការ លោកជួយណែនាំ។ មេការរូបនេះអះអាងទៀតថា ទូកនេសាទរបស់លោកនេះ តម្រូវគ្រប់កម្មករមានឯកសារគ្រប់គ្រាន់ ហើយក៏គ្មានការបង្ខិតបង្ខំប្រើគ្រឿងញៀនដើម្បីឱ្យមានកម្លាំងដើម្បីធ្វើការងារនោះដែរ ។ លោកថា បើថៅកែដឹងថា កម្មករណាលួចប្រើគ្រឿងញៀន គេនឹងបញ្ឈប់ពីការងារ។ លោក យាន រិទ្ធ៖ «ប្រឹងប្រែងហ្នឹងហើយព្រោះធ្វើការយកលុយ រកលុយយើងបានលុយច្រើនដែរដល់ពេលមិនសូវធ្វើការមិនសូវបានដែរ គ្រាន់តែមើលប្រាប់ថា ធ្វើការម៉េច ធ្វើការអ៊ីចេះ ធ្វើការអ៊ីចុះយើងដែរហ្នឹង»។ កម្មករលើទូកនេសាទនេះ អាចទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃពីថៅកែ។ អាហារពេលល្ងាចរបស់ក្រុមពលករថ្ងៃនេះ គឺមួយបាយឆ្នាំងធំសម្រាប់ហូបរួមគ្នា ចំណែកម្ហូបវិញ គឺភ្លៅមាន់ និងស្លាបមាន់បំពង។

បុរសមាឌធំ និងរូបសាក់លើដងខ្លួនផងនោះ គឺលោក ធន រិទ្ធិ ពលកររូបនេះ កំពុងទទួលអាហារទំនងឆ្ងាញ់ណាស់ ក្រោយលោកធ្វើការងារហត់នឿយពេញមួយថ្ងៃនេះ។ លោក ធន រិទ្ធិ មានអាយុ២៩ឆ្នាំ មកពីខេត្តសៀមរាបមកធ្វើការងារនៅនេះបាន ២ឆ្នាំហើយ។ លោកថា ថ្ងៃខ្លះបាយម្ហូបដែលថៅកែរៀបចំនេះលោកហូបមិនឆ្អែត ដែលលោកត្រូវទិញបាយម្ហូបពីក្រៅ មកហូបបន្ថែម។ លោកយល់ថា ជីវិតកម្មករនេសាទនៅលើសមុទ្រនេះ មិនមែនជាការងារងាយស្រួលព្រោះត្រូវធ្វើការងារទាំងឈឺទាំងជាដើម្បីបានប្រាក់កម្រៃ។ លោក ធន រិទ្ធិ៖ «ជួនកាលបើថាយើងខ្ជិលហូបបាយនៅហ្នឹងបើយើងមានលុយ យើងទៅក្រៅក៏បានដែរទៅហូបគុយទាវ មួយចានប្រាំពាន់រៀល។ ពិបាកយើងធ្វើការងារយប់អ៊ីចឹងជួនកាលរលក ជួនកាលអត់ស្រួល។ ចំណាប់អារម្មណ៍បើនៅខ្មែរគេឱ្យថ្លៃសមរម្យយើងអាចទៅ ប៉ុន្តែបើនៅយ៉ាប់យ៉ឺនយើងចង់នៅថៃ»។

កម្មករទូកនេសាទគឺជាការងារមួយស្ថិតចំណោមការងារមានហានិភ័យខ្ពស់ផ្សេងទៀត ដោយការងារនេះប្រឈម ការប្រើអំពើហិង្សា ការរំលោភសិទ្ធិ ថៅកែបើកលុយមិនគ្រប់ចំនួន និងត្រូវបង្ខិតបង្ខំឱ្យធ្វើការងារហួសកម្លាំងជាដើម។ កម្មករទូកនេសាទខ្លះធ្វើការងាររាប់ឆ្នាំលើទូកនេសាទ សល់ត្រឹមជីវិតមកជួបប្រពន្ធកូននៅស្រុកកំណើត។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ប្រាប់ថា នៅប្រទេសថៃសព្វថ្ងៃ អាជ្ញាធរថៃបានត្រួតពិនិត្យតឹងរ៉ឹងលើឯកសារការងាររបស់ពលករដើម្បីជួយពង្រឹងការគោរពសិទ្ធិការងាររបស់ពលករ។ ទោះយ៉ាងណា លោកសង្កេតឃើញថា ពលករខ្មែរចុះនេសាទនៅប្រទេសនេះ នៅតែជួបការរំលោភសិទ្ធិ ករណីថៅកែមិនបើកប្រាក់ឈ្នួល ថៅកែមិនធ្វើឯកសារគ្រប់គ្រាន់ និងការបង្ខំឱ្យពលករធ្វើការច្រើនម៉ោងជាដើម។ លោក លឹង សុផុន៖ «ក្នុងករណីបែបហ្នឹងខ្ញុំឃើញចំនួនច្រើនហើយកន្លងមក ដោយពួកគាត់(ពលករទូកនេសាទ) ទៅអ្នកខ្លះគាត់អត់មានលុយចាយប្រចាំថ្ងៃពេលខ្លះចេញ គាត់ឈប់ពីកន្លែងហ្នឹងទៅរកកន្លែងផ្សេង ធ្វើឱ្យគាត់ហានិភ័យរងគ្រោះពីមួយទៅកន្លែងអ៊ីចឹង ពួកគាត់នៅតែប្រឈម នៅតែមានបញ្ហារហូត»។

កាលពីថ្មីៗនេះ អង្គការការពារសិទ្ធិពលករសង់ត្រាល់ បានធ្វើវីដេអូឯកសារ ស្តីពីអតីតពលករខ្មែរធ្វើការងារទូកនេសាទ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតយកទៅលក់ឱ្យថៅកែទូកនេសាទនៅប្រទេសថៃ។ ពួកគាត់ធ្វើការជាច្រើនឆ្នាំ មិនទទួលបានប្រាក់ឈ្នួលឡើយ មិនត្រឹមតែប៉ុណ្ណោះត្រូវរងអំពើហិង្សាគ្រប់បែបយ៉ាង និងធ្វើការលើសកម្លាំងជាទម្ងន់។ រយៈពេលបីឆ្នាំចុងក្រោយនេះ គិតពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ យ៉ាងហោចណាស់ពលករខ្មែរជិត៧.០០០នាក់ (៦.៩៩១) ក្នុងនោះស្ត្រីជាង ៤.០០០នាក់ ត្រូវបានអង្គការសង់ត្រាល់ជួយសង្គ្រោះ។ ពលករទាំងនោះ ចាញ់បោកមេខ្យល់ រងការរំលោភសិទ្ធិការងារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងរងការជួញដូរជាដើម។

ធនាគារពិភពលោករាយការណ៍ថា កាលពីឆ្នាំ២០១៥ ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត ៤លាននាក់ (៣.៧៦)ក្នុងនោះ ៥៣ ភាគរយមកពីប្រទេសភូមា ២៦ភាគរយមកពីប្រទេសឡាវ និង ២១ភាគរយមកពីកម្ពុជា។ ចំណែកទិន្នន័យរបស់រដ្ឋាភិបាលថៃវិញ បង្ហាញថា កម្មករចំណាកស្រុកកម្ពុជា ឡាវ និងភូមាដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ៕

## លោក Anwar នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ៖ ជនរងគ្រោះពីការឆបោកការងារ ១២នាក់ទៀតនៅកម្ពុជាត្រូវបានជួយសង្គ្រោះ

https://www.khmertimeskh.com/501263597/-anwar-/ March 28, 2023

លោកបាននិយាយថា ស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា នឹងសម្របសម្រួលនីតិវិធីជួយដល់បុគ្គលទាំង ១២ នាក់នៅថ្ងៃនេះ។ លោកបានថ្លែងក្នុងសន្និសីទសារព័ត៌មាននៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចផ្លូវការរយៈពេលមួយថ្ងៃរបស់លោកមកកាន់ប្រទេសកម្ពុជាកាលពីយប់មិញថា "នេះគឺជាព័ត៌មានចុងក្រោយបំផុតដែលទទួលបាន ពាក់ព័ន្ធនឹងចំនួនដែលបានប្រកាសកាលពីពេលមុន"។ នៅក្នុងសន្និសីទសារព័ត៌មានជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីម្សិលមិញ លោក Anwar បានលើកឡើងថា ជនជាតិម៉ាឡេស៊ីសរុប ចំនួន ២៨៧នាក់ ដែលជាជនរងគ្រោះនៃក្រុមឆបោកនេះ ត្រូវបាននាំយកត្រឡប់ទៅប្រទេសវិញ។

ជាមួយគ្នានេះ ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim បានប្រាប់ Bernama ថា ផ្អែកលើព័ត៌មានដែលទទួលបាន បុគ្គលទាំង ១២នាក់ ស្ថិតក្នុងបញ្ជីមនុស្សដែលត្រូវបានរាយការណ៍ថាបានបាត់ខ្លួន។ លោកបានបន្តថា បុគ្គលិកស្ថានទូតនឹងធ្វើដំណើរទៅកន្លែងជនរងគ្រោះនៅថ្ងៃស្អែក ដើម្បីចាប់ផ្តើមដំណើរការធ្វើមាតុភូមិនិវត្តន៍។ លោកបានបន្ថែមទៀតថា "ប្រសិនបើសមាជិកគ្រួសាររបស់ពួកគេបានបំពេញឯកសាររួចរាល់ រួមទាំងសំបុត្រយន្តហោះត្រឡប់ទៅវិញ ប្រហែលជាជនរងគ្រោះទាំងអស់នឹងអាចត្រឡប់ទៅផ្ទះវិញនៅ

ថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ” ដោយបន្ថែមថា ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានេះនឹងត្រូវបានផ្តល់ជូននៅពេលក្រោយ។ Bernama

## លោកនាយករដ្ឋមន្ត្រី Anwar ថ្លែងអំណរគុណ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការជួយនាំយកជនរងគ្រោះនៃការបោកប្រាស់ការងារត្រលប់ទៅប្រទេសម៉ាឡេស៊ីវិញ

https://www.khmertimeskh.com/501263716/-anwar-/?p=1263716 Khmer Times March 28, 2023

លោក Anwar ដែលកំពុងបំពេញទស្សនកិច្ចផ្លូវការចំនួនមួយថ្ងៃនៅកម្ពុជា បានលើកឡើងពីការដឹកនាំរបស់លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ថាលោកជាថ្នាក់ដឹកនាំ«ឆ្នើម» ក្នុងការផ្តល់ការគាំទ្រ និងសហការយ៉ាងពេញលេញក្នុងការដោះស្រាយបញ្ហាឆបោកការងារ។ “ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផងដែរ ពីព្រោះកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ដែលឆ្លើយតបបានលឿន នៅពេលដែលយើងត្រូវដោះស្រាយបញ្ហាបោកប្រាស់ការងារដែលប៉ះពាល់ដល់ប្រជាពលរដ្ឋ បន្ទាប់មកអ្នកកម្ពុជាក៏បានជួយយើងក្នុងការជួយនាំជនរងគ្រោះម៉ាឡេស៊ី ចំនួន ២៨៧នាក់ មកប្រទេសវិញ។ លោកបានថ្លែងក្នុងសន្និសីទសារព័ត៌មានរួមគ្នាបន្ទាប់ពីជំនួបទ្វេភាគីជាមួយលោក ហ៊ុន សែន នៅវិមានសន្តិភាពកាលពីម្សិលមិញថា “ខ្ញុំសូមអរគុណច្រើន ” ហើយវាមានអត្ថន័យខ្លាំងណាស់ដល់គ្រួសាររាប់រយដែលរងផលប៉ះពាល់ដោយការឆបោកនេះ។

មានសេចក្តីរាយការណ៍ថា ក្រសួងការបរទេសបានទទួលរបាយការណ៍ចំនួន ៥៧២ ពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ី ដែលជាជនរងគ្រោះនៃក្រុមឆបោកការងារនៅបរទេសគិតត្រឹមថ្ងៃទី២០ ខែកុម្ភៈ។ របាយការណ៍នេះត្រូវបានទទួលតាមរយៈស្ថានទូតម៉ាឡេស៊ីនៅទីក្រុងបាងកក រាជធានីភ្នំពេញ ទីក្រុងវៀងចន្ទន៍ និងយ៉ាំងហ្គោន។ ទន្ទឹមនឹងនោះ លោកបានបន្តថា លោកកំពុងទន្ទឹងរង់ចាំទទួលស្តាប់នូវការចូលរួមចំណែកជាគំនិតរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកក្រោយ ទាក់ទងនឹងក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយវិបត្តិមីយ៉ាន់ម៉ាដែលមានក្នុងពេលបច្ចុប្បន្ន។

លោក Anwar បានលើកឡើងថា វិបត្តិនៅប្រទេសមីយ៉ាន់ម៉ាលែងជាបញ្ហាផ្ទៃក្នុងទៀតហើយ ខណៈដែលជនភៀសខ្លួនរ៉ូហ៊ីងយ៉ាជាង ២០០,០០០នាក់ បានភៀសខ្លួនចេញពីប្រទេសមីយ៉ាន់ម៉ាទៅកាន់ប្រទេសម៉ាឡេស៊ី។ លោកបានបន្ថែមថា សហគមន៍អាស៊ានយល់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសមីយ៉ាន់ម៉ា ប៉ុន្តែរបបយោធារបស់ប្រទេសនេះក៏ត្រូវតែយល់ដែរថា បញ្ហានេះមិនមែននៅតែមិនអាចដោះស្រាយបានទេ។ លោកក៏បានសម្តែងការជឿជាក់លើភាពឆ្លាតវៃរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ក្នុងការធានាបានសន្តិភាពនៅ នៅកម្ពុជា បើប្រៀបធៀបទៅនឹងវិបត្តិនៅប្រទេសមីយ៉ាន់ម៉ានាពេលបច្ចុប្បន្ន។ លោកបានបន្ថែមថា “នេះគឺជាឧទាហរណ៍ដ៏អស្ចារ្យមួយអំពីរបៀបដែលប្រទេសដែលត្រូវបានឡោមព័ទ្ធដោយសង្គ្រាមស៊ីវិល និងអំពើហិង្សា ដែលទីបំផុតក៏ទទួលបានសន្តិភាព។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមួយនឹងបទពិសោធន៍ដ៏ច្រើនសន្ធឹកសន្ធាប់របស់លោក ពិតណាស់គឺមានសារៈប្រយោជន៍ក្នុងការពិភាក្សាលើបញ្ហាស្មុគស្មាញជាច្រើន ដូចជាប្រទេសមីយ៉ាន់ម៉ា។

លោកក៏បានគូសបញ្ជាក់ថា ប្រទេសម៉ាឡេស៊ី និងកម្ពុជាបានចែករំលែកទស្សនៈស្រដៀងគ្នាអំពីបញ្ហាសមុទ្រចិនខាងត្បូង រុស្ស៊ី-អ៊ុយក្រែន ឧបទ្វីបកូរ៉េ និងបញ្ហាតៃវ៉ាន់-ចិន។ លោកក៏បានថ្លែងអំណរគុណចំពោះលោក ហ៊ុន សែន ដែលបានរៀបចំពិធីស្រាយបួសជាមួយអ្នកកាន់សាសនាឥស្លាមរាប់ពាន់នាក់ក្នុងប្រទេសកម្ពុជានៅយប់នេះ។ លោកបានបន្តថា នេះគឺជាការឆ្លុះបញ្ចាំងពីការយល់ដឹងរបស់លោក ហ៊ុន សែន ចំពោះភាពអត់ឱន និងការគោរពចំពោះក្រុមជនជាតិភាគតិចដែលនេះជាលក្ខណៈសម្បត្តិមួយដែលពិភពលោកខ្វះសម្រាប់ក្នុងពេលបច្ចុប្បន្ន។

លោកបានបន្ថែមថា "មានការស្អប់ ការយល់ច្រលំ និងការមិនអត់ឱនច្រើន ប៉ុន្តែ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមនុស្សមានសណ្តានចិត្តល្អ ដោយលោកបានអញ្ជើញខ្ញុំចូលរួមនៅក្នុងពិធីបុណ្យដ៏អស្ចារ្យនេះ"។ លោកបានបន្តថា លោកទន្ទឹងរង់ចាំដំណើរទស្សនកិច្ចរបស់លោក ហ៊ុន សែន ទៅកាន់ទីក្រុងគូឡាឡាំពួ។

លោកAnwar និងលោក ហ៊ុន សែន បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួនពីរស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករការងារផ្ទះ និងអនុស្សារណយោគយល់គ្នាស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។ កាលពីម្សិលមិញ លោក Anwar បានចូលគាល់ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហមុនី នៅព្រះបរមរាជវាំង ហើយបានចូលជួបសម្តែងការគួរសមជាមួយប្រធានព្រឹទ្ធសភាកម្ពុជា លោក សាយ ឈុំ និងប្រធានរដ្ឋសភា លោក ហេង សំរិន។ នៅក្នុងពិធីស្រាយបួសជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អ្នកសិក្សា និងសហគមន៍ឥស្លាមនៅកម្ពុជា លោកAnwar បានបរិច្ចាគគម្ពីគូរ៉ាន់ចំនួន ១៥,០០០ច្បាប់ ដែលត្រូវបានបកប្រែជាភាសាខ្មែរ និងភាសាអង់គ្លេស ពីប្រទេសម៉ាឡេស៊ីដល់សហគមន៍ឥស្លាម។ គាត់បានធ្វើការអធិស្ឋាននៅព្រះវិហារ Al-Masjid Al-Serkal មុនពេលត្រឡប់ទៅប្រទេសវិញ។ *Bernama*

# ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០២៣

## សម្តេច ស ខេង ណែនាំអាជ្ញាធរ និងពលរដ្ឋ ចូលរួមប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://dap-news.com/national/2023/03/30/322222/ ByPH104Posted on March 30, 2023

**ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំអាជ្ញាធរ និងប្រជាពលរដ្ឋទាំងអស់ចូលរួមប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស។**

ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា នៅវត្តពោធិ៍អណ្តែត ហៅវត្តទួលតាណាល ស្ថិតនៅឃុំព្រៃស្មៀត ស្រុកពារាំង ខេត្តព្រៃវែង នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣នេះ សម្តេច ស ខេង បានបញ្ជាក់ថា «អាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់ ដល់ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់ និង លើកកម្ពស់ការចូលរួម របស់ប្រជាពលរដ្ឋក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានានៅមូលដ្ឋាន ពិសេសសកម្មភាពជួញដូរចែកចាយ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បទល្មើសលួច ឆក់ ប្លន់ ល្បែងស៊ីសងខុសច្បាប់នៅតាមមូលដ្ឋាន អំពើ ហិង្សាក្នុងគ្រួសារ ក្រុមក្មេងទំនើង និងបទល្មើសនានានៅមូលដ្ឋាន ទូទាំងខេត្ត»។

សម្តេច បានស្នើអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់ដល់ការផ្តល់សេវា រដ្ឋបាលជូនប្រជាពលរដ្ឋ ដូចជាការបញ្ជាក់សំបុត្រកំណើត ការធ្វើអត្តសញ្ញាណប័ណ្ណ សំបុត្រអាពាហ៍ពិពាហ៍ និងឯកសារនានាដែលប្រជាពលរដ្ឋចាំបាច់ត្រូវការសេវាពីអាជ្ញាធរមូលដ្ឋាន គឺត្រូវតែអនុវត្ត និងផ្តល់ជូនប្រជាពលរដ្ឋ ឱ្យទាន់ពេលវេលា និង ប្រសិទ្ធភាពខ្ពស់ និងត្រូវបន្តខិតខំរួមគ្នា ជំរុញអនុវត្តឲ្យសកម្មផុលផុស ជាប់ជាប្រចាំនូវផែនការ យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយត្រូវលើកកម្ពស់ការអនុវត្តវិធានការសំខាន់ៗ « បីកុំ មួយរាយការណ៍»៕

# សមត្ថកិច្ចខេត្តកំពង់ឆ្នាំងឃាត់ប្រធានក្រុមហ៊ុនរាជ្យ សុផាន់គួង ខូអិលធីឌី និងបក្សពួក

https://kohsantepheapdaily.com.kh/article/1712505.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram កំពង់ឆ្នាំង៣០ ខែ មីនា ឆ្នាំ ២០២៣ ម៉ោង ១៦:១៥

ខេត្តកំពង់ឆ្នាំង ៖ ប្រធានក្រុមហ៊ុនរាជ្យសុផាន់គួង ខូអិលធីឌីម្នាក់ និងបក្សពួក៣នាក់ទៀត ត្រូវបានសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំងបញ្ជូនខ្លួនទៅតុលាការ កាលពីរសៀលថ្ងៃទី២៩ មីនា ឆ្នាំ២០២៣ បន្ទាប់ពីបានធ្វើការឃាត់ខ្លួន កាលពីថ្ងៃទី២៧ មីនា ឆ្នាំ២០២៣ នៅទីស្នាក់ការក្រុមហ៊ុន ស្ថិតក្នុងភូមិទី៣ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង បន្ទាប់ពីពលករចំនួន២៣នាក់ បានដាក់ពាក្យបណ្ដឹងថា បានឆបោកប្រាក់ពលករជាង១៤ម៉ឺនដុល្លារ ។

ក្រុមពលករជាជនរងគ្រោះ នៅរសៀលថ្ងៃទី២៩ មីនា នេះ បានឱ្យអ្នកយកព័ត៌មានយើងដឹងថា ជនឆបោកដែលត្រូវសមត្ថកិច្ចឃាត់ខ្លួនក្នុងករណីខាងលើនេះ ១-ឈ្មោះ រាជ សុផាន់គួង ភេទស្រី មានទីលំនៅក្នុងខេត្ត ព្រះវិហារ ជាប្រធានក្រុមហ៊ុនរាជសុផាន់គួង, ២-ឈ្មោះ សែន ទីន ភេទប្រុស ជាប្តី មានទីលំនៅខេត្តតាកែវ, ៣-ឈ្មោះអ៊ុល ចន្នី ភេទស្រី មានទីលំនៅខេត្តកណ្ដាល ជានាយក រងក្រុមហ៊ុន និងជាគណនេយ្យទទួលប្រាក់ពីពលករ, ៤-ឈ្មោះនុត ណារិន ភេទប្រុស ជាប្តី ។

ជនរងគ្រោះជាពលករបានឲ្យដឹងទៀតថា នៅក្នុងការឃាត់ខ្លួនជនឆបោកទាំង៤នាក់ខាងលើនេះ សមត្ថកិច្ចនគរបាលបានខ្សឹបប្រាប់ថា សមត្ថកិច្ចដកហូតបានថវិកាចំនួនជាង៤ពាន់ដុល្លារ និងលុយខ្មែរជាង២លានរៀល និងរថយន្ត Ford ពណ៌ខ្មៅមួយគ្រឿង ពាក់ស្លាកលេខកម្ពុជា KKK.1230 របស់ប្រធានក្រុមហ៊ុន ។ ក្រុមពលករជាជនរងគ្រោះសំណូមពរផងដែរដល់ស្ថាប័នតុលាការខេត្តកំពង់ឆ្នាំង មេត្តាជួយកាត់ សេចក្ដីទាវថវិកាជាង ១៤ ម៉ឺនដុល្លារដែលជនឆបោកខាងលើនេះបោកប្រាស់យកមកជូនពលករទាំង ២៣ នាក់វិញ។ ក្នុងករណីនេះដែរ បើរឹបអូសយករថយន្ត Ford របស់ប្រធានក្រុមហ៊ុន ដែលមានតម្លៃប្រមាណជាង៧ម៉ឺនដុល្លារ មកលក់សងពលករវិញក៏អាចបានពាក់កណ្ដាលផងដែរ។

ករណីនេះដែរ លោក ពេជ រ៉ី ស្នងការរងនគរបាលខេត្តកំពង់ឆ្នាំង ទទួលផែននគរបាលព្រហ្មទណ្ឌកម្រិតស្រាលបានឲ្យដឹងថា ជនសង្ស័យទាំងបួននាក់ខាងលើនេះ បានឆរបោកប្រាក់ពីពលករចំនួន ២៣នាក់ ដែលបានដាក់ពាក្យបណ្ដឹងសរុបចំនួន ១៤៧.៥០០ដុល្លារ និងតាមការស្រាវជ្រាវបានឲ្យដឹងថាក្រុមហ៊ុនមួយនេះកន្លងមកមិនដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសណា មួយឡើយ។ ហើយនៅរសៀលថ្ងៃទី ២៩ ខែមីនានេះជនសង្ស័យទាំង៤ នាក់ ត្រូវបានសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅកាន់តុលាការរួចហើយដើម្បីចាត់ការបន្តតាមផ្លូវច្បាប់។ ប៉ុន្តែនៅម៉ោង៥ល្ងាច ថ្ងៃទី២៩ ខែមីនានេះ តុលាការបានផ្ញើ ជនសង្ស័យទាំង៤នាក់ជាមួយសមត្ថកិច្ចនគរបាលខេត្តមួយយប់ទៀត ព្រោះតែតុលាការពិនិត្យសំណុំរឿងមិនទាន់ចប់ ព្រោះតែមានដើមបណ្ដឹងច្រើននាក់ ។ ហើយនៅថ្ងៃស្អែកថ្ងៃ ទី៣០ សមត្ថកិច្ចនិងបញ្ជូនជនសង្ស័យទាំង៤នាក់ទៅកាន់តុលា ការខេត្តវិញចំណាត់ការបន្ត។

សូមបញ្ជាក់ថា ករណីខាងលើនេះប្រធានក្រុមហ៊ុន រាជ្យ សុផាន់គួង ដែលមានទីស្នាក់ការនៅក្នុងភូមិទី៣ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង បានទទួលប្រាក់ពីពលករ ២៣ នាក់ ដែលមកពីតាមបណ្ដាខេត្តនានាសរុបចំនួន ១៤៧.៥០០ ដុល្លារ នៅអំឡុ ងខែធ្នូ ឆ្នាំ២០២២ និងក្នុងខែមករាឆ្នាំ ២០២៣ ដោយសន្យាថា នឹងបញ្ជូនពលករខាងលើនេះ ទៅធ្វើការនៅប្រទេសអូស្ត្រាលីនៅក្នុងខែកុម្ភៈ និងខែមីនាឆ្នាំ២០២៣នេះ ។ ប៉ុន្តែដល់ពេលសន្យាមិនឃើញក្រុមហ៊ុនបញ្ជូនពួកខ្លួនទៅធ្វើការនៅប្រទេសអូស្ត្រាលី ទើបបងប្អូនពលករបានដាក់ពាក្យប្ដឹងទៅស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំងដើម្បីចំណាត់ការរឿងឆរបោកនេះតាមផ្លូវច្បាប់ ។

## ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា សន្យាពន្លឿនការធ្វើមាតុភូមិនិវត្តន៍ ជនជាតិម៉ាឡេស៊ី ដែលបានធ្លាក់ខ្លួនជាជនរងគ្រោះនៃការងារឆបោកនៅកម្ពុជា

https://www.khmertimeskh.com/501265033// Khmer Times March 30, 2023

ស្ថានទូតម៉ាឡេស៊ី នឹងពន្លឿនដំណើរការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋម៉ាឡេស៊ី ចំនួន១២នាក់ ដែលបានធ្លាក់ខ្លួនជាជនរងគ្រោះនៃការងារឆបោកនៅកម្ពុជា។ ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim បាននិយាយថា ក្រុមការងាររបស់លោកបានពិភាក្សាជាមួយនគរបាល និងនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា ទាក់ទងនឹងការដោះលែងបុគ្គលចំនួន ១២នាក់ ដែលរួមមាន ១១នាក់នៅខេត្តព្រះសីហនុ និងម្នាក់នៅទីនេះ។ លោកបានអោយដឹងទៀតថា ជនជាតិម៉ាឡេស៊ីទាំង ១២ នាក់ដែលមានបុរស ១១ នាក់ និងស្ត្រីម្នាក់អាយុចន្លោះពី ២០ ទៅ ២៥ ឆ្នាំ ត្រូវបានអាជ្ញាធរកម្ពុជាជួយសង្គ្រោះនៅថ្ងៃទី ២៥ ខែមីនា មុននឹងត្រូវបានរក្សាទុកបណ្តោះអាសន្នរហូតដល់នីតិវិធីពាក់ព័ន្ធនឹងការដោះលែងពួកគេត្រូវបានបញ្ចប់។

លោកបានប្រាប់ Bernama នៅថ្ងៃនេះថា "ប្រសិនបើអ្វីៗដំណើរការទៅដោយរលូន បុគ្គលទាំង១២នាក់នឹងត្រូវបានបញ្ជូនទៅវិញនៅចុងសប្តាហ៍នេះ ឬដើមសប្តាហ៍ក្រោយ អាស្រ័យលើដំណើរការរៀបចំឯកសារ" ។ លោកបានបន្តទៀតថា ជនរងគ្រោះភាគច្រើនដែលត្រូវបានជួយសង្គ្រោះលើកនេះបានមកកម្ពុជាកាលពីឆ្នាំមុន ជាក់ស្តែងពួកគេបានដឹងថាខ្លួនត្រូវបានចាញ់បោកដោយការផ្តល់ការងារក្លែងក្លាយ។ លោកបានបន្ថែមទៀតថា ក្រុមការងាររបស់លោកបានជួបជនរងគ្រោះ និងបានផ្តល់ការប្រឹក្សា ក៏ដូចជាជំនួយក្នុងការទទួលបានព័ត៌មានលំអិតទាក់ទងនឹងឧប្បត្តិហេតុជាក់ស្តែង រួមទាំងការទទួលបានព័ត៌មានដើម្បីតាមដានមេក្លោងរបស់ក្រុមនេះ។ស្ថានទូតម៉ាឡេស៊ីបានរៀបចំឯកសារសម្រាប់ការដោះលែង និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះម៉ាឡេស៊ីទាំងអស់។ "ប្រសិនបើពួកគេមានលិខិតឆ្លងដែន (នីតិវិធីធម្មតាត្រូវបានអនុវត្ត) (ប្រសិនបើមិនមាន) យើងនឹងចេញវិញ្ញាបនបត្របន្ទាន់ ហើយនឹងរៀបចំដំណើរការទិដ្ឋាការ និងទិញសំបុត្រយន្តហោះសម្រាប់ពួកគេត្រឡប់ទៅម៉ាឡេស៊ីវិញ។

លោកបានអោយដឹងទៀតថា "យើងបានទាក់ទងក្រុមគ្រួសារជនរងគ្រោះ ដើម្បីជូនដំណឹងដល់ពួកគេថាពួកគេ (ជនរងគ្រោះ) មានសុវត្ថិភាព ហើយបានផ្តល់ឱកាសឱ្យក្រុមគ្រួសារពួកគេបាននិយាយជាមួយពួកគេផងដែរ" ។ លោកបានបន្តថាបច្ចុប្បន្នស្ថានទូតម៉ាឡេស៊ីកំពុងសហការជាមួយអាជ្ញាធរកម្ពុជាដើម្បីស្វែងរកពលរដ្ឋម៉ាឡេស៊ីចំនួន ១២ នាក់បន្ថែមទៀតដែលបានធ្លាក់ខ្លួនជាជនរងគ្រោះដោយសារក្រុមឆបោកការងារនៅទីនេះ។

ក្នុងសន្និសីទសារព័ត៌មានជាមួយលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា លោក Anwar Ibrahim នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលបានមកបំពេញទស្សនកិច្ចផ្លូវការរយៈពេលមួយថ្ងៃនៅកម្ពុជា បាននិយាយថា ពលរដ្ឋម៉ាឡេស៊ីសរុបចំនួន ២៨៧នាក់ ដែលបានរងគ្រោះដោយសារក្រុមនេះ ត្រូវបានបញ្ជូនទៅកាន់ប្រទេសម៉ាឡេស៊ីវិញដោយជោគជ័យ៕ *Bernama*

## កិច្ចព្រមព្រៀងពលករធ្វើការតាមផ្ទះម៉ាឡេស៊ី-កម្ពុជា គួរតែដាក់បញ្ចូលប្រាក់ឈ្នួលអប្បបរមា

https://www.khmertimeskh.com/501265118// Khmer Times March 30, 2023

ក្រុមសិទ្ធិមនុស្សពលករចំណាកស្រុក បានចោទសួរពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការបញ្ចប់ការកេងប្រវ័ញ្ចលើពលករធ្វើការតាមផ្ទះ បន្ទាប់ពីកិច្ចព្រមព្រៀងទ្វេភាគីចុងក្រោយ ដែលបានចុះហត្ថលេខាជាមួយប្រទេសកម្ពុជា ដែលមិនបាននិយាយអំពីប្រាក់ឈ្នួលអប្បបរមា។

នៅពេលទាក់ទង នាយកប្រតិបត្តិអង្គការ Tenaganita លោកស្រី Glorene A Das បាននិយាយថា ខណៈដែលម៉ាឡេស៊ីបានចូលរួមក្នុងបញ្ជីប្រទេសជាច្រើនដែលមានច្បាប់ការងារដែលមិនរាប់បញ្ចូលពលករធ្វើការតាមផ្ទះ

ពីការទទួលបានប្រាក់ឈ្នួលអប្បបរមា ការផ្តល់បែបនេះគួរតែត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋាភិបាល។ "ប្រាក់ឈ្នួលអប្បបរមាមានសារៈសំខាន់ព្រោះវាការពារក្រុមពលករដែលងាយរងគ្រោះបំផុតដូចជាពលករតាមផ្ទះពីការកេងប្រវ័ញ្ច និងត្រូវបានជាប់ក្នុងស្ថានភាពទាសករដែលអាចកើតមាន។ "ការរួមបញ្ចូលប្រាក់ឈ្នួលអប្បបរមានៅក្នុងកិច្ចព្រមព្រៀងដូចជា MOU រវាងប្រទេសប្រភពដើម និងប្រទេសគោលដៅបង្ហាញយ៉ាងសាមញ្ញថាប្រទេសទាំងពីរទទួលស្គាល់ការរួមចំណែកយ៉ាងច្រើនរបស់ពលករធ្វើការតាមផ្ទះ ទៅដល់មាតុភូមិ និងសង្គម។ លោកស្រី Glorene បានប្រាប់ Malaysiakini ថា "វាគឺជាវិធានការសំខាន់មួយដើម្បីធានានូវគោលការណ៍នៃប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា" ។

រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស លោក V Sivakumar កាលពីម្សិលមិញបានបញ្ជាក់ពី MOU រយៈពេលប្រាំឆ្នាំចុងក្រោយនេះ មិនបានបញ្ជាក់ពីប្រាក់ឈ្នួលអប្បបរមាប្រចាំខែ ដែលកំណត់ដោយប្រទេសកម្ពុជា ឬផ្អែកលើអត្រាបច្ចុប្បន្នរបស់ប្រទេសម៉ាឡេស៊ីចំនួន១,៥០០រីងហ្គីតជាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករពេញសិទ្ធទាំងអស់។ ផ្ទុយទៅវិញ Malaysiakini យល់ថា និយោជកដែលកំពុងស្វែងរកជួលពលករតាមផ្ទះពីប្រទេសកម្ពុជា ត្រូវតែផ្តល់ប្រាក់ឈ្នួលប្រចាំខែដែលកំណត់ដោយ "កម្លាំងទីផ្សារ" នៅក្នុងប្រទេសម៉ាឡេស៊ី ហើយបានយល់ព្រមជាផ្នែកនៃលក្ខខណ្ឌនៃកិច្ចសន្យាការងារ។ លើសពីនេះ លោកស្រី Glorene បានលើកឡើងពីប្រាក់ឈ្នួលអប្បបរមាដែលនិយោជកម៉ាឡេស៊ីបានបង់ដល់ពលករធ្វើការតាមផ្ទះមកពីប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ដែលជាប្រទេសប្រភពដើមពេញនិយមបំផុតពីរ និងរបៀបដែលរដ្ឋាភិបាលកំពុងលើកទឹកចិត្តឱ្យមានការរើសអើងដោយមិនមានការចុះហត្ថលេខាជាមួយកម្ពុជា។

ជាមួយគ្នានេះ លោកស្រីបាននិយាយថា រដ្ឋាភិបាលនៃប្រទេសប្រភពដើមនានា ត្រូវតែបង្ហាញពីការប្តេជ្ញាចិត្តផ្នែកនយោបាយដើម្បីការពារជនជាតិរបស់ពួកគេ ជាពិសេសក្រុមដែលងាយរងគ្រោះនៃអ្នកធ្វើការតាមផ្ទះ។ « ប្រទេសនានាមិនអាចគ្រាន់តែចាប់អារម្មណ៍លើគោលនយោបាយនាំចេញកម្លាំងពលកម្មរបស់ខ្លួន និងការផ្ញើប្រាក់នោះទេ។ អ្នកស្រីបាននិយាយថា "រដ្ឋាភិបាលត្រូវតែការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលករធ្វើការតាមផ្ទះ" ដោយបន្ថែមថា អង្គការ Tenaganita នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការតស៊ូមតិសម្រាប់ច្បាប់ពលករធ្វើការតាមផ្ទះដាច់ដោយឡែក។

មុនពេលកិច្ចព្រមព្រៀងថ្មីនេះ ប្រទេសម៉ាឡេស៊ីបានចុះហត្ថលេខាលើ MOU រយៈពេលប្រាំឆ្នាំដំបូងរបស់ខ្លួនជាមួយប្រទេសកម្ពុជានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ បន្ទាប់មកការជ្រើសរើសបុគ្គលិកទាំងអស់ត្រូវបានផ្អាកភាគច្រើនដោយសារការបិទខ្ទប់ជាសកលលោក នៃជំងឺរាតត្បាតកូវីដ-១៩។ MOU ឆ្នាំ២០១៥ បានលើកលែងការហាមប្រាមរយៈពេលប្រាំឆ្នាំដែលដាក់ដោយរដ្ឋាភិបាលកម្ពុជាលើភ្នាក់ងារជ្រើសរើសពលករពីការបញ្ជូនពលករធ្វើការតាមផ្ទះទៅប្រទេសម៉ាឡេស៊ី ដោយសារករណីជាច្រើនត្រូវបានរាយការណ៍ថាមានការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត។ កាលពីមុន ខ្លឹមសារពេញលេញនៃកិច្ចព្រមព្រៀងការងារដែលសម្រេចបានជាមួយប្រទេសប្រភពដើមផ្សេងៗត្រូវបានរក្សាស្រដៀងគ្នា ស្ថិតក្នុងភាពមន្ទិល ដោយមានការចោទជាសំណួរអំពីតម្លាភាពនៃដំណើរការ៕ *Malaysiakini*

# សមត្ថកិច្ចកំពុងសាកសួរបុរសម្នាក់ ទាក់ទងករណីគំរាមចែកចាយរូបភាពអាសអាភាសរបស់ក្មេងស្រីអាយុ ១៤ ឆ្នាំ

https://www.postkhmer.com/national/2023-03-29-1948-248554.html គីម សារុំ | Publication date 29 March 2023 | 19:48 ICT

**បន្ទាយមានជ័យៈ** នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី ២៩ មីនា កំពុងសាកសួរបុរសម្នាក់ ពាក់ព័ន្ធនឹងការគំរាមចែកចាយរូបភាពអាសអាភាសរបស់ក្មេងស្រីអាយុ ១៤ ឆ្នាំម្នាក់ ប្រព្រឹត្តកាលពីដើមខែមីនា ឆ្នាំ ២០២៣។

លោកស្រី រស់ សុជាតិ ស្នងការរងទទួលផែននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានឱ្យដឹងនៅថ្ងៃទី ២៩ មីនាថា បុរសសង្ស័យម្នាក់កំពុងត្រូវបានសមត្ថកិច្ចជំនាញរបស់លោកស្រី សាកសួរពាក់ព័ន្ធនឹងការគំរាមចែកចាយរូបភាពអាសអាភាស របស់ក្មេងស្រីម្នាក់អាយុ១៤ឆ្នាំ។ ប៉ុន្តែលោកស្រីមិនអាចប្រាប់ពីអត្តសញ្ញាណរបស់ជនសង្ស័យបានទេ ព្រោះស្ថិតនៅក្នុងនីតិវិធីកំពុងស៊ើបសួរនៅឡើយ។ លោកស្រីប្រាប់ថា៖ «រឿងនេះស្ថិតក្នុងនីតិវិធីស៊ើបអង្កេត ដូច្នេះខ្ញុំមិនអាចផ្តល់ឈ្មោះរបស់ជនសង្ស័យបានទេ។ម៉្យាងរឿងនេះ ទាក់ទងនឹងក្មេងស្រីជាអនីតិជនផង»។

ចំណែកលោកឧត្តមសេនីយ៍ឯក ង៉េង ជួ ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី២៩មីនាថា សមត្ថកិច្ចជំនាញព្រហ្មទណ្ឌរបស់លោក បានឃាត់ខ្លួនបុរសម្នាក់កាលពីយប់ថ្ងៃទី២៨មីនា នៅក្នុងរាជធានីភ្នំពេញ ទីដែលជនសង្ស័យកំពុងរស់នៅ។ ប៉ុន្តែទោះយ៉ាងណា លោកមិនបានប្រាប់ពីអត្តសញ្ញាណរបស់បុរសសង្ស័យនោះទេ ហើយលោកថា បានប្រគល់ជនសង្ស័យឱ្យទៅនគរបាលខេត្តបន្ទាយមានជ័យហើយនៅថ្ងៃទី២៩មីនា ដោយសារតែក្មេងស្រីរងគ្រោះរស់នៅទីនោះ។ លោកប្រាប់យ៉ាងខ្លីថា៖« កម្លាំងជំនាញព្រហ្មទណ្ឌរបស់ យើងបានឃាត់ខ្លួនបុរសនោះហើយ យើងប្រគល់គាត់ទៅឱ្យនគរបាលខេត្តបន្ទាយមាន ជ័យវិញ ព្រោះជាខេត្តសាមីដែលជនរងគ្រោះរស់នៅ»។

ពាក់ព័ន្ធករណីនេះដែរបើតាមកញ្ញា សោម វឌ្ឍនា មន្ត្រីនៃអង្គភាពការពារកុមារ Child ProtectionUnit (CPU) បានឱ្យដឹងនៅថ្ងៃទី២៩មីនាថា ករណីនេះក្មេងស្រីរងគ្រោះមានអាយុ១៤ឆ្នាំ រស់នៅខេត្តបន្ទាយមានជ័យ រីឯបុរសសង្ស័យរស់នៅក្នុងរាជធានីភ្នំពេញ។ ទោះយ៉ាងណា កញ្ញាសោម វឌ្ឍនា មិនបានបញ្ជាក់ពីអត្តសញ្ញាណក្មេងស្រីរងគ្រោះ និងជនសង្ស័យដល់ភ្នំពេញប៉ុស្តិ៍ឡើយ។ បើយោងតាមផេកហ្វេប៊ុករបស់អង្គភាពការពារកុមារ(CPU) បានសរសេរថា កាលពីវេលាម៉ោងប្រហែល៨និង៣០នាទីយប់ ថ្ងៃទី២៨មីនា នគរបាលនាយកដ្ឋានព្រហ្មទណ្ឌនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអង្គភាពការពារកុមារ(CPU) បានឃាត់ខ្លួនបុរសអាយុ៣០ឆ្នាំម្នាក់ នៅក្នុងរាជធានីភ្នំពេញ ពាក់ព័ន្ធករណីប៉ុនប៉ងគំរាមបង្ហោះរូបភាពអាសអាភាសរបស់ក្មេងស្រីអាយុ១៤ឆ្នាំ រស់នៅខេត្តបន្ទាយមានជ័យ។

បទល្មើសខាងលើនេះ បានកើតឡើងនៅខេត្តបន្ទាយមានជ័យ កាលពីដើមខែមីនា ឆ្នាំ២០២៣។ នៅក្នុងផេកហ្វេប៊ុកដដែលនេះ បានដកស្រង់សម្តីរបស់លោក James McCabe ប្រធានអង្គភាពការពារកុមារថា៖«ខ្ញុំចង់អបអរសាទរ ដល់ភ្នាក់ងារទាំងអស់ ដែលពាក់ព័ន្ធនឹងការចាប់ខ្លួន។ នេះជាការបង្ហាញនិងព្រមានយ៉ាងច្បាស់ ដល់ជនដែលបញ្ជូនរូបភាពអាសអាភាស ប៉ុនប៉ងគំរាមកំហែង និងបង្កាច់បង្ខូចកុមារ។ អ្នកនឹងត្រូវបានរកឃើញ ហើយអ្នកនឹងត្រូវចាប់ខ្លួន។ កិច្ចសហប្រតិបត្តិការដ៏ល្អនៅទូទាំងស្ថាប័ន និងខេត្តមួយចំនួនបានឈានដល់ការចាប់ខ្លួននេះ»៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១០នាក់

https://freshnewsasia.com/index.php/en/localnews/284473-2023-03-30-04-03-26.html 2023-03-30 11:03am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១០នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨១៨ករណី មានមនុស្ស ២,០៧២នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៧៣សំណើ និងបិទសំណុំរឿង ២៦៣សំណើ (រកឃើញមនុស្ស ១,១៧៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៥ករណី៕

## សម្តេចក្រឡាហោម ស ខេង ជំរុញឱ្យអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់យកចិត្តទុកដាក់ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់

https://www.information.gov.kh/articles/100890 ចេញផ្សាយ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានជំរុញឱ្យអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់ដល់ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់ និង លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានានៅមូលដ្ឋាន។ ការជំរុញរបស់សម្តេចក្រឡាហោម បែបនេះ ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា នៅវត្តពោធិ៍អណ្តែត ហៅវត្តទួលតាណាល ស្ថិតនៅឃុំព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង នាព្រឹកថ្ងៃព្រហស្បតិ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២៣។

សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវបន្តយកចិត្តទុកដាក់ចំពោះសកម្មភាពជួញដូរចែកចាយ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បទល្មើសលួច ឆក់ ប្លន់ ល្បែងស៊ីសងខុសច្បាប់នៅតាមមូលដ្ឋាន អំពើហិង្សាក្នុងគ្រួសារ ក្រុមក្មេងទំនើង និងបទល្មើសនានានៅមូលដ្ឋានទូទាំងខេត្ត។ សម្តេចក្រឡាហោមក៏បានស្នើអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់ដល់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ដូចជាការបញ្ជាក់សំបុត្រកំណើត ការធ្វើអត្តសញ្ញាណប័ណ្ណ សំបុត្រអាពាហ៍ពិពាហ៍ និងឯកសារនានាដែលប្រជាពលរដ្ឋចាំបាច់ត្រូវការសេវាពីអាជ្ញាធរមូលដ្ឋាន គឺត្រូវតែអនុវត្តន៍ និងផ្តល់ជូនប្រជាពលរដ្ឋឱ្យទាន់ពេលវេលា និងប្រសិទ្ធភាពខ្ពស់។ ត្រូវបន្តខិតខំរួមគ្នាជំរុញអនុវត្តន៍ឱ្យសកម្មផុលផុសជាប់ជាប្រចាំនូវផែនការយុទ្ធនាការប្រ យុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយត្រូវលើកកម្ពស់ការអនុវត្តវិធានការសំខាន់ៗ « បីកុំ មួយរាយការណ៍»។

ក្នុងឱកាសនោះដែរ សម្តេចក្រឡាហោមក៏បានរម្លឹកអាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋទាំងអស់ចូលរួមប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីលើកស្ទួយសិទ្ធិមនុស្ស ដោយសហការយ៉ាងមានប្រសិទ្ធ

ភាពជាមួយកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ក្រាបនឹងទប់ស្កាត់បានទាន់ពេលវេលា។ ជាមួយគ្នានេះ ត្រូវបន្តខិតខំពង្រឹងកម្លាំងប្រជាការពារឱ្យមានចំនួនសមស្របតាមភូមិសាស្ត្រ និងប្រជាសាស្ត្រនៃមូលដ្ឋាននីមួយៗ ដោយត្រូវបំផុសលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងចលនាប្រជាការពារ និងបំផុសចលនាឱ្យមានការចូលរួម ជួយឧបត្ថម្ភគាំទ្រទាំងខាងមធ្យោបាយ សម្ភារ ថវិកា និងការគាំទ្រខាងស្មារតីដល់ប្រជាការពារនៅគ្រប់មូលដ្ឋានឱ្យមាននិរន្តរភាព។ សម្តេចក្រឡាហោម ស ខេង បានថ្លែងបញ្ជាក់ថា សមិទ្ធផលទាំងអស់ដែលប្រទេសជាតិសម្រេចបានរហូតមកទល់ពេលនេះ ពិតជាកើតឡើងដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញយ៉ាងត្រឹមត្រូវនូវកម្មវិធីនយោបាយ គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានាជាមួយការចាត់តាំងអនុវត្តន៍ ដោយមានការគាំទ្រ និងការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាននៅទូទាំងប្រទេស។

សម្តេចក្រឡាហោមក៏បានអំពាវនាវអាជ្ញាធរមានសមត្ថកិច្ច កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋរួមគ្នាថែរក្សាការពារសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិ ការពារព្រះមហាក្សត្រ ការពាររបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់កើតចេញពីការបោះឆ្នោត។ លើសពីនេះទៀត បន្តលើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការពារ និងលើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងការពង្រឹងនីតិរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា៕ ចាន់ សុធីវង្ស

---